- **ប្រើប្រាស់បច្ចេកទេសប្រតិបត្តិការត្រឹមត្រូវ**
  - ដើម្បីកាត់បន្ថយសំណឹកច្រវាក់ ចូរចៀសវាការរអិល និងរបារក្រឡាកង់កោសលើផ្ទៃរឹង។
  - ប្រុងប្រយ័ត្ននៅពេលបើកបរឆ្លងកាត់ប្រឡាយទឹក ឬប្លរលេខនៅពេលបត់។ ការបើកបរកាត់បញ្ចិតប្រឡាយទឹកបណ្តាលឲ្យច្រវាក់ជាប់បង់ទម្រ ដែលបណ្តាលឲ្យជាប់បង់តំណឹងភ្លាមៗ និងមានហានិភ័យខ្ពស់ក្នុងការបូតច្រវាក់នៅពេលបត់។
  - កុំឲ្យហួសពីជម្រាលប្រតិបត្តិការចំហៀង 10° ឬជម្រាលប្រតិបត្តិការមុខ/ក្រោយ 22°។
- **រក្សាតំណឹងច្រវាក់ត្រឹមត្រូវ**
  - ច្រវាក់ជូបណ្តាលឲ្យឆាប់សឹកច្រវាក់ និងផ្ទៃខាងក្នុងខ្សែពានដោយសារតែការរអិល និងអាចបណ្តាលឲ្យមានកំណសម្ភារ។
  - ច្រវាក់តឹងខ្លាំងបន្ថែមបន្ទុកនិងតំណឹងដល់ជាដាងគ្រឿងក្រោម ខ្សែកាប់ច្រវាក់ខាងក្នុង និងគ្រោងច្រវាក់។
- **ការពារមិនឲ្យសម្ភារខុសប្រក្រតីចូលក្នុងច្រវាក់**
  សម្ភារមុតស្រួច ឬរឹតនៅខាងក្នុងច្រវាក់គឺជាមូលហេតុចម្បងនៃការដាច់ច្រវាក់ និងជាចំណុចចូលសំណើមទៅក្នុងគ្រោងច្រវាក់ជាបន្តបន្ទាប់។

OUO6075,0004F5F-KM-04NOV20-1/1

ល្បឿនធ្វើដំណើរតាមផ្លូវ

កំណត់ចំណាំ៖ ពេលវេលាធ្វើដំណើរលើដងផ្លូវដែលអនុញ្ញាតជាអតិបរមាដើម្បីបង្កើនអាយុកាលខ្សែពានកៅស៊ូ/កង់ជាអតិបរមា។

មិនភ្ជាប់ក្បាលឧបករណ៍កាត់ (ទទឹងខ្សែពានទាំងអស់)

សីតុណ្ហភាពជុំវិញ		ល្បឿន				
		25	30	35	40	គម/ម៉ោង
°C	°F	15	18	21	25	ម៉ាយល៍/ម៉ោង
0	32	>5.0				ម៉ោង
5	41					
10	50					
15	59					
20	68	>5.0			4.5	
25	77	>5.0	4.5		4.0	
30	86	4.0		3.5		
35	95	3.5		3.0		
40	104	3.0	2.5		2.0	

ដោយភ្ជាប់ក្បាលឧបករណ៍កាត់ (ច្រវាក់ប្រវែង 60.9 ស.ម (24 អ៊ីញ))

សីតុណ្ហភាពជុំវិញ		ល្បឿន				
		25	30	35	40	គម/ម៉ោង
°C	°F	15	18	21	25	ម៉ាយល៍/ម៉ោង
0	32	>5.0			1.5	ម៉ោង
5	41					
10	50					
15	59	>5.0	4.5		1.0	
20	68	4.5	4.0			
25	77	4.0	3.5			
30	86	3.5	3.0			
35	95	3.0	2.5			
40	104	2.5	2.0	1.5		

ដែលភ្ជាប់ក្បាលឧបករណ៍កាត់ (ច្រវាក់ប្រវែង 76.2 ស.ម (30 អ៊ីញ) និងច្រវាក់ប្រវែង 91.4 ស.ម (36 អ៊ីញ))

សីតុណ្ហភាពជុំវិញ		ល្បឿន				
		25	30	35	40	គម/ម៉ោង
°C	°F	15	18	21	25	ម៉ាយល៍/ម៉ោង
0	32	>5.0			1.0	ម៉ោង
5	41	>5.0		4.5		
10	50			1.0		
15	59	>5.0	4.5			
20	68	4.5	4.0		.5	
25	77	4.0	3.5			
30	86	3.5	3.0			
35	95	3.0	2.5			
40	104	2.5	1.5			

OUO6075,0004872-KM-14JUN18-1/1

ប្រព័ន្ធបន្ទឹងច្រវាក់

តទៅទំព័របន្ទាប់

OUO6041,0000C31-KM-10MAY18-1/2

សំខាន់៖ ពិនិត្យមើលសម្ពាធស៊ីឡាំងតំណឹងមុននឹងប្រើប្រាស់គ្រឿងចក្រ។


សម្ពាធនីត្រូសែន

សម្ពាធអ៊ីដ្រូលីកមានអង្គបណ្តុំនីត្រូសែនខាងក្នុងដែលសាកជាមុនពីរោងចក្រ។ មិនចាំបាច់ត្រូវការពិនិត្យសម្ពាធឡើយ លុះណាតែមានការធ្លាក់ចុះសម្ពាធអ៊ីដ្រូលីកភ្លាមៗដោយមិនមានសញ្ញាបាត់បង់សារធាតុរាវ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់លោកអ្នក។

សម្ពាធអ៊ីដ្រូលីក

ប្រដាប់វាស់សម្ពាធអ៊ីដ្រូលីសុចិតនៅពីលើកង់ខាងមុខនៅត្រង់ទីតាំងដែលបានបង្ហាញ។ ប្រដាប់វាស់ប្រើដើម្បីផ្តល់ការពិនិត្យដោយក្អែកឆាប់រហ័សដើម្បីពិនិត្យមើលថាសម្ពាធស្ថិតនៅក្នុងកម្រិតប្រតិបត្តិការណែនាំដែរឬទេ។

ប្រសិនបើសម្ពាធស្ថិតនៅក្រៅកម្រិតទាំងនេះ គេត្រូវតែលៃតម្រូវ។ ប្រសិនបើសម្ពាធទាបពេក នេះបង្ហាញថាមានការលេចធ្លាយនៅត្រង់កន្លែងណាមួយនៅក្នុងប្រព័ន្ធអ៊ីដ្រូលីក និងត្រូវតែ



H122229—UN—15AUG17

ពិនិត្យមើលឲ្យបានជិតដល់ជាងនេះ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere របស់លោកអ្នក។

OUO6041,0000C31-KM-10MAY18-2/2


ការសម្អាតច្រវាក់

OUO6041,0000C32-KM-15AUG17-1/2

សំខាន់៖ ត្រូវតែសម្អាតច្រវាក់ជាបន្ទាន់បន្ទាប់ពីប្រតិបត្តិការនៅក្នុងលក្ខខណ្ឌសើមនិងមានភក់។

ជានិច្ចកាល ចូររក្សាកង់អូសទាញ និងគ្រោងមេកុំឲ្យមានកម្ទេចកម្ទីនិងដី។

តំបន់គ្រោងមេ និងកង់ត្រូវតែសម្អាតតាមកាលកំណត់ដើម្បីបង្ការកំណប់ដី និងកម្ទេចកម្ទី។ កំណកម្ទេចកម្ទីដីអាចបណ្តាលឲ្យឆាប់សឹកខ្សែពានច្រវាក់កៅស៊ូ កង់ប៊ូហ្គី និងកង់។




H122230—UN—15AUG17

OUO6041,0000C32-KM-15AUG17-2/2


តំបន់លាងសម្អាតច្រវាក់

តទៅទំព័របន្ទាប់

OUO6041,0000C33-KM-16AUG17-1/2



ទិដ្ឋភាពខាងក្រៅ



ទិដ្ឋភាពខាងក្នុង

A—តំបន់គ្រោងមេ និងកង់

តំបន់គ្រោងមេ និងកង់ (A) ត្រូវតែសម្អាតតាមកាលកំណត់ ដើម្បីបង្ការកំណឺ និងកម្ទេចកម្ទី។ កំណកម្ទេចកម្ទីដែលអាចបណ្តាលឱ្យឆាប់សឹកខ្សែពានច្រវាក់កៅស៊ូ កង់ប៊ូហ្គី និងកង់។

OUO6041,0000C33-KM-16AUG17-2/2

តារាងចន្លោះពេលថែទាំសេវា

សំខាន់៖ ពេលវេលាថែទាំគឺសម្រាប់លក្ខខណ្ឌមធ្យម។ ចូរផ្តល់សេវាថែទាំញឹកញាប់ ប្រសិនបើគ្រឿងចក្របំពេញការងារនៅក្នុងស្ថានភាពហួសហេតុ។

សេវាថែទាំ	10 ម៉ោង ដំបូង	រាល់ 10 ម៉ោង	100 ម៉ោង ដំបូង	រាល់ 400 ដំបូង	រាល់ 1000 ដំបូង	រាល់ 2000 ដំបូង
សម្អាតកម្ទេចកម្ទីដែចេញពីកង់អូសទាញ		•				
សម្អាតកម្ទេចកម្ទីដែចេញពីគ្រោងមេ		•				
ពិនិត្យមើលកម្រិតប្រេងដុំអូសទាញខាងចុង				•		
ពិនិត្យមើលកម្រិតប្រេងដុំកង់ប៊ូហ្គី				•		
ពិនិត្យមើលកម្រិតប្រេងដុំកង់				•		
ពិនិត្យមើលការកំណត់សម្ពាធ			•	•		
ពិនិត្យមើលខ្សែពានច្រវាក់			•	•		
ពិនិត្យមើលតំណឹងប៊ូឡុង	•		•	•		
ពិនិត្យមើលតំណឹងកង់ និងតំណឹងប៊ូឡុងកង់មានធ្មេញ	•		•	•		
ប្តូរប្រេងរំអិលដុំកង់ប៊ូហ្គី					•	
ប្តូរប្រេងរំអិលដុំកង់					•	
ប្តូរប្រេងដុំអូសទាញខាងចុង						•
ប្តូរខ្សែពានឆ្វេង/ស្តាំ [a]					•	

[a] ត្រូវការប្តូរខ្សែពានដោយផ្អែកលើសំណឹកកង់ទំនាញប៉ុណ្ណោះ

OUO6075,1684949837493-KM-20JUN23-1/1

ការថែទាំខ្សែពាន និងការកំណត់លក្ខខណ្ឌរ៉ូដាស់

តទៅទំព័របន្ទាប់

OUO6041,0000C34-KM-11OCT17-1/2

⚠ ប្រយ័ត្ន៖ ចូរពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។

កំណត់ចំណាំ៖ ទម្រង់ការរ៉ូដាស់ដូចតទៅនេះគឺសម្រាប់ប្រព័ន្ធច្រវាក់ម៉ូឌុលបន្ទាប់ពីដំឡើងប្រព័ន្ធច្រវាក់ថ្មី ឬដំឡើងខ្សែពានច្រវាក់ថ្មីរួច។ មុននឹងប្រតិបត្តិការគ្រឿងចក្រ ត្រូវតែលាបប្រេងសួតលើកង់បញ្ចេញកម្លាំងនៃខ្សែពានច្រវាក់កៅស៊ូដើម្បីជួយកំណត់លក្ខខណ្ឌខ្សែពានឲ្យបានត្រឹមត្រូវ។

ចាក់ប្រេងរំអិលសួតមួយពែងលើតំបន់កង់បញ្ចេញកម្លាំងមុខ និងក្រោយ (A) ដូចក្នុងរូបភាព។


បើកបរគ្រឿងចក្រទៅមុខ ឬថយក្រោយដើម្បីពង្រាយប្រេងរំអិលសួតលើធ្មេញកង់បញ្ចេញកម្លាំង។

ពិនិត្យមើលកង់នាំផ្លូវកង់បញ្ចេញកម្លាំងក្រែងលោមិនមានប្រេងរំអិលសួតនៅលើផ្ទៃទាំងអស់។

ជានិច្ចកាល ចូរហាលច្រវាក់ថ្មី ឬស្អាតឲ្យស្អុត និងលក្ខខណ្ឌដីហុយតាមដែលអាចធ្វើទៅបាន។

ដំណើរការគ្រឿងចក្រប្រហែល 10 ម៉ោងបន្ទាប់ពីដំឡើងរួច។

ពិនិត្យមើលសម្ពាធអ៊ីដ្រូលីកនៅលើប្រព័ន្ធបន្តឹងច្រវាក់ និងលៃតម្រូវវាតាមចាំបាច់។



A—តំបន់កង់បញ្ចេញកម្លាំងមុខ និងក្រោយ

ពិនិត្យមើលតំណឹងគ្រឿងខ្ចៅម៉ូឌុលច្រវាក់ និងរឹតបន្តឹងឡើងវិញតាមចាំបាច់។


OUO6041,0000C34-KM-11OCT17-2/2

លក្ខណៈវិនិច្ឆ័យផ្លាស់ប្តូរច្រវាក់

OUO6041,0000D63-KM-15JUN18-1/2

ដើម្បីបង្ការការខូចខាត និង/ឬបាត់បង់ប្រសិទ្ធពល ត្រូវតែប្តូរច្រវាក់ចេញនៅពេលឈានដល់លក្ខខណ្ឌមួយដូចខាងក្រោមនេះ៖

- កម្ពស់របារក្រឡាកង់ (A) គឺតិចជាង 12 ម.ម (0.5 អ៊ីញ) សម្រាប់ច្រវាក់ទំនាញ។
- បាត់បង់របារក្រឡាកង់លើសពីបីក្នុងមួយជុរ
- បាត់បង់កង់បញ្ចេញកម្លាំង (B) បន្តបន្ទាប់លើសពីបី
- សំណឹកនៅលើកង់បញ្ចេញកម្លាំងច្រើនជាង 50%
- ការធ្លាក់ច្រវាក់កើតឡើងដោយសារសំណឹក ឬបាត់បង់កង់បញ្ចេញកម្លាំង
- ខ្សែកាបមេដាច់នៅលើទទឹងច្រវាក់លើសពីមួយភាគបី (1/3)
- ខ្សែកាបមេអាចមើលឃើញនៅលើផ្ទៃច្រវាក់ផ្នែកខាងក្នុង
- កង់មានធ្មេញគឺជាកង់រអិលដោយសារបាត់បង់/សឹកកង់បញ្ចេញកម្លាំង



A—របារក្រឡាកង់ **B—កង់បញ្ចេញកម្លាំង**

OUO6041,0000D63-KM-15JUN18-2/2

ប្រេងអ៊ីដ្រូលីក

តទៅទំព័របន្ទាប់

OUCC002,0005875-KM-13JUN18-1/2


ប្រើកម្រិតភាពស្អិតខាប់ដោយផ្អែកលើលំដាប់សីតុណ្ហភាពខ្យល់ដែលបានរំពឹងទុកនៅអំឡុងចន្លោះពេលនៃការផ្លាស់ប្តូរប្រេងម៉ាស៊ីនម្តងៗ។

គួរប្រើប្រេងម៉ាស៊ីនខាងក្រោមនេះ៖

- John Deere Hy-Gard™
- John Deere Low Viscosity Hy-Gard™

ប្រេងផ្សេងៗទៀតអាចប្រើប្រាស់បាន ប្រសិនបើវាឆ្លើយតបនឹងចំណុចណាមួយខាងក្រោម៖

- John Deere Standard JDM J20C
- John Deere Standard JDM J20D




OUCC002,0005875-KM-13JUN18-2/2

ពិនិត្យមើលប្រេងដុំអូសទាញខាងចុង

OUO6075,1684946740954-KM-24MAY23-1/2

1. ពិនិត្យកម្រិតប្រេងនៅកញ្ចក់មើលឃើញ (A) ។ កម្រិតប្រេងគួរតែស្ថិតនៅផ្នែកខាងលើកញ្ចក់មើលឃើញ។
2. បន្ថែមប្រេងតាមចាំបាច់។

A—កញ្ចក់មើលឃើញ



OUO6075,1684946740954-KM-24MAY23-2/2

ពិនិត្យមើលប្រេងរំអិល

តទៅទំព័របន្ទាប់

OUO6075,000503E-KM-14MAY21-1/3


⚠ ប្រយ័ត្ន៖ ប្រយ័ត្នរងរបួសឆេះរលាក ពាក់ស្រោមដៃការពារ ឬទុកពេលឲ្យសមាសភាគគ្រឿងចុះត្រជាក់។ កង់ប៊ូហ្គី កង់ និងខ្សែពានច្រវាក់កៅស៊ូជាធម្មតាប្រតិបត្តិការនៅសីតុណ្ហភាពខ្ពស់ និងអាចក្តៅប៉ះមិនបាន។

កំណត់ចំណាំ៖ ពិនិត្យមើលប្រេងរំអិលតែនៅលើដុំកង់ខាងក្រៅពីព្រោះចង្អូរប្រេងធម្មតានៅចន្លោះដុំកង់ខាងក្រៅនិងខាងក្នុង។

សម្អាតតំបន់នៅជុំវិញឆ្នុកបង្ហូរមុននឹងដោះចេញ។

ត្រងប្រេងដាក់នៅក្នុងធុងស្អាត។

1. បើកបរគ្រឿងចក្រទៅមុខឬថយក្រោយដើម្បីឲ្យឆ្នុកបង្ហូរ (A) ដែលស្ថិតនៅលើដុំកង់ខាងក្រៅ (B) ស្ថិតនៅក្នុងទីតាំងម៉ោងបី ឬម៉ោងប្រាំបួន។
2. ដោះឆ្នុកបង្ហូរចេញ ហើយពិនិត្យមើលក្រែងលោកម្រិតប្រេងមិនស្ថិតនៅបាត់រន្ធ។ បន្ថែមប្រេងចូលតាមការចាំបាច់។
3. ដំឡើងឆ្នុកបង្ហូរប្រេង។
4. អនុវត្តជំហានដដែលសម្រាប់ដុំកង់ម្ខាងទៀត។




A—ឆ្នុកបង្ហូរ **B—ដុំកង់ (ប្រើ 2)**

OUO6075,000503E-KM-14MAY21-2/3

កំណត់ចំណាំ៖ ពិនិត្យមើលប្រេងរំអិលតែនៅលើដុំកង់ប៊ូហ្គីខាងក្រៅពីព្រោះចង្អូរប្រេងធម្មតានៅចន្លោះដុំកង់ប៊ូហ្គីខាងក្រៅនិងខាងក្នុង។

5. បើកបរគ្រឿងចក្រទៅមុខឬថយក្រោយដើម្បីឲ្យឆ្នុកបង្ហូរ (A) ដែលស្ថិតនៅលើដុំកង់ប៊ូហ្គីខាងក្រៅ (B) ស្ថិតនៅក្នុងទីតាំងម៉ោងបី ឬម៉ោងប្រាំបួន។
6. ដោះឆ្នុកបង្ហូរចេញ ហើយពិនិត្យមើលក្រែងលោកម្រិតប្រេងមិនស្ថិតនៅបាត់រន្ធ។ បន្ថែមប្រេងចូលតាមការចាំបាច់។
7. ដំឡើងឆ្នុកបង្ហូរប្រេង។
8. អនុវត្តជំហានដដែលសម្រាប់ដុំកង់ប៊ូហ្គីម្ខាងទៀត។



A—ឆ្នុកបង្ហូរ **B—ដុំកង់ប៊ូហ្គី (ប្រើ 3)**

OUO6075,000503E-KM-14MAY21-3/3


ប្តូរប្រេងដុំអូសទាញខាងចុង

តទៅទំព័របន្ទាប់

OUO6075,1684946748826-KM-24MAY23-1/2

1. ដកឆ្នុកបង្ហូរប្រេងចេញ (A) ។
2. ទុកឲ្យប្រេងដុំអូសទាញខាងចុងហូរ។
3. ដាក់ឆ្នុកបង្ហូរចូលនៅពេលបង្ហូរប្រេងអស់។
4. ដោះឆ្នុកចាក់បំពេញ (B) ពីដុំអូសទាញខាងចុង។
5. ថែមប្រេងចូលរហូតទាល់តែកម្រិតប្រេងស្ថិតនៅត្រង់ផ្នែកខាងលើកញ្ចក់មើលឃើញ (C)។
6. ដាក់ឆ្នុកចាក់បំពេញដែលបានដោះចេញកន្លងមកចូលវិញ។

A—ឆ្នុកបង្ហូរ
B—ឆ្នុកចាក់បំពេញ
C—កញ្ចក់មើលឃើញ



H136510—UN—24MAY23

OUO6075,1684946748826-KM-24MAY23-2/2

ប្តូរប្រេង

OUO6075,000503F-KM-14MAY21-1/3

⚠ ប្រយ័ត្ន៖ ប្រយ័ត្នរងរបួសឆេះរលាក ពាក់ស្រោមដៃការពារ ឬទុកពេលឲ្យសមាសភាគគ្រឿងចុះត្រជាក់។ កង់ប៊ូហ្គី កង់ និងខ្សែពានច្រវាក់កៅស៊ូជាធម្មតាប្រតិបត្តិការនៅសីតុណ្ហភាពខ្ពស់ និងអាចក្តៅប៉ះមិនបាន។

កំណត់ចំណាំ៖ ប្តូរប្រេងរំអិលតែនៅលើដុំកង់ខាងក្រៅពីព្រោះចង្ហូរប្រេងធម្មតានៅចន្លោះដុំកង់ខាងក្រៅនិងខាងក្នុង។

សម្អាតតំបន់នៅជុំវិញឆ្នុកបង្ហូរមុននឹងដោះចេញ។


ត្រងប្រេងដាក់នៅក្នុងធុងស្អាត។

1. បើកបរគ្រឿងចក្រទៅមុខឬថយក្រោយដើម្បីឲ្យឆ្នុកបង្ហូរ (A) ដែលស្ថិតនៅលើដុំកង់ខាងក្រៅ (B) ស្ថិតនៅផ្នែកខាងក្រោម។
2. ដកឆ្នុកបង្ហូរ ហើយបង្ហូរប្រេងចេញ។
3. បើកបរគ្រឿងចក្រទៅមុខឬថយក្រោយដើម្បីឲ្យឆ្នុកបង្ហូរដដែលស្ថិតនៅក្នុងទីតាំងម៉ោង៦ បី ឬម៉ោងប្រាំបួន។
4. ចាក់បំពេញតាមលក្ខណៈបច្ចេកទេសដោយប្រើប្រេង Hy-Gard™ ។

លក្ខណៈបច្ចេកទេស

ដុំកង់—ចំណុះ	0.8 ល (0.85 ខ្វត)

Hy-Gard គឺជាពាណិជ្ជសញ្ញារបស់ *Deere & Company*



H122234—UN—24OCT17

A—ឆ្នុកបង្ហូរ
B—ដុំកង់ (ប្រើ 2)

5. ដំឡើងឆ្នុកបង្ហូរប្រេង។
6. អនុវត្តដំហានដដែលសម្រាប់ដុំកង់ម្ខាងទៀត។

តទៅទំព័របន្ទាប់

OUO6075,000503F-KM-14MAY21-2/3

កំណត់ចំណាំ៖ ប្តូរប្រេងតែនៅលើដុំកង់ប៊ូហ្គីខាងក្រៅប៉ុណ្ណោះ ពីព្រោះចង្អូរប្រេងធម្មតានៅចន្លោះដុំកង់ប៊ូហ្គីខាងក្រៅនិងខាងក្នុង។


7. បើកបរគ្រឿងចក្រទៅមុខឬថយក្រោយដើម្បីឲ្យឆ្នុកបង្ហូរ (A) ដែលស្ថិតនៅលើដុំកង់ប៊ូហ្គីខាងក្រៅ (B) ស្ថិតនៅផ្នែកខាងក្រោម។
8. ដកឆ្នុកបង្ហូរ ហើយបង្ហូរប្រេងចេញ។
9. បើកបរគ្រឿងចក្រទៅមុខឬថយក្រោយដើម្បីឲ្យឆ្នុកបង្ហូរដដែលស្ថិតនៅក្នុងទីតាំងម៉ោងបី ឬម៉ោងប្រាំបួន។
10. ចាក់បំពេញតាមលក្ខណៈបច្ចេកទេសដោយប្រើប្រេង Hy-Gard™ ។

លក្ខណៈបច្ចេកទេស

ដុំកង់ប៊ូហ្គី—ចំណុះ. . . . . 0.8 ល (0.85 ខ្វត)

11. ដំឡើងឆ្នុកបង្ហូរប្រេង។
12. អនុវត្តជំហានដដែលសម្រាប់ដុំកង់ប៊ូហ្គីម្ខាងទៀត។

Hy-Gard គឺជាពាណិជ្ជសញ្ញារបស់ *Deere & Company*



A—ឆ្នុកបង្ហូរ **B—ដុំកង់ប៊ូហ្គី (ប្រើ 3)**

OUO6075,000503F-KM-14MAY21-3/3

លក្ខណៈបច្ចេកទេស

លក្ខណៈបច្ចេកទេសច្រវាក់		
ចំណុះបន្ទុក	22 650 គ.ក (49 935 ផោន)	
ដុំទម្ងន់	60.9 សម (24 អ៊ីញ)	2710 គ.ក (5975 ផោន)
	76.2 សម (30 អ៊ីញ)	2840 គ.ក (6262 ផោន)
	91.4 សម (36 អ៊ីញ)	3000 គ.ក (6615 ផោន)
ទំហំរង្វិលអតិបរមា	6032 mm (238 in)	


ចំណុះ	
ដុំអូសទាញខាងចុង	19 ល (20.09 ខ្វត)
ដុំកង់	.8 លីត្រ (.85 ខ្វត)
ដុំកង់ប៊ូហ្គី	0.8 ល (0.85 ខ្វត)
ប្រភេទប្រេង (ដុំអូសទាញខាងចុង)	John Deere GL-5 Gear Lubricant 80W/90
ប្រភេទប្រេង (ដុំកង់ និងដុំបូគី)	Hy-Gard ប្រេងដែលឆ្លើយតបនឹង John Deere Standard JDM J20C

OUO6075,1684963869532-KM-13JUN23-1/1

ទំហំម៉ូឌុលច្រវាក់

តទៅទំព័របន្ទាប់

OUO6041,0000CF8-KM-05DEC17-1/2



H122256—UN—19OCT17

មាត្រដ្ឋាន	ទំហំ
A	60.9 សម (24 អ៊ីញ) 76.2 សម (30 អ៊ីញ) 91.4 សម (36 អ៊ីញ)
B	1165 មម (46 អ៊ីញ)
C	18 111 ម.ម (71 អ៊ីញ)
D	2767 mm (109 in)

OUO6041,0000CF8-KM-05DEC17-2/2

ទំហំគ្រឿងចក្រច្រូត

កំណត់ចំណាំ៖ ទំហំប្រហាក់ប្រហែលនិងអាចមានការកែប្រែដោយ
ពុំមានការជូនដំណឹងឡើយ។

មាត្រដ្ឋាន	ទំហំ
A	11.02 ម (36 ហ្វីត 2 អ៊ីញ) ដែលមានប្រដាប់បួងទម្លាក់រឹងមាំនិងប្រើថាមពលប្រវែង 6.9 ម (22 ហ្វីត 6 អ៊ីញ) 11.72 ម៉ែត្រ (38 ហ្វីត 5 អ៊ីញ) ដែលមានប្រដាប់បួងទម្លាក់រឹងប្រវែង 7.9 ម៉ែត្រ (26 ហ្វីត 0 អ៊ីញ) 11.98 ម៉ែត្រ (39 ហ្វីត 4 អ៊ីញ) ដែលមានប្រដាប់បួងទម្លាក់ប្រើថាមពលប្រវែង 7.9 ម៉ែត្រ (26 ហ្វីត 0 អ៊ីញ) 12.46 ម៉ែត្រ (40 ហ្វីត 11 អ៊ីញ) ដែលមានប្រដាប់បួងទម្លាក់រឹងប្រវែង 8.7 ម៉ែត្រ (28 ហ្វីត 6 អ៊ីញ)
B	ប្រដាប់បួងរមូរដោយថាមពល 9.14 m (30 ft 0 in) ជាមួយ 6.9 m (22 ft 6 in) ប្រដាប់បួងរមូរដោយថាមពល 9.93 m (32 ft 7 in) ជាមួយ 7.9 m (26 ft 0 in)
C	8.52 ម (27 ហ្វីត 11 អ៊ីញ)
D	4.91—4.99 ម (16 ហ្វីត 1 អ៊ីញ—16 ហ្វីត 5 អ៊ីញ) ជាមួយគម្រប 10 572 ល (300 bu) 3.92—3.99 ម (12 ហ្វីត 10 អ៊ីញ—13 ហ្វីត 1 អ៊ីញ) ជាមួយគម្រប 14 096 ល (400 bu)
E	ប្រដាប់បួងផ្គុកគ្រាប់ធញ្ញជាតិស្អាត ប្រវែង 4.61—4.84 ម (15 ហ្វីត 2 អ៊ីញ—15 ហ្វីត 11 អ៊ីញ) ដែលមានធុងពន្លាចំណុះ 10 572 ល (300 bu) ប្រដាប់បួងផ្គុកគ្រាប់ធញ្ញជាតិស្អាត ប្រវែង 4.77—4.85 ម (15 ហ្វីត 8 អ៊ីញ—15 ហ្វីត 11 អ៊ីញ) ដែលមានធុងពន្លាចំណុះ 14 096 ល (400 bu)
F	ប្រវែង 4.30—4.39 ម (14 ហ្វីត 1 អ៊ីញ—14 ហ្វីត 5 អ៊ីញ) ដែលមានធុងបន្លាយទំហំ 10 572 ល (300 bu) ប្រវែង 4.57—4.65 ម (15 ហ្វីត 0 អ៊ីញ—15 ហ្វីត 3 អ៊ីញ) ដែលមានធុងបន្លាយទំហំ 14 096 ល (400 bu)
G	4.04—4.13 m (13 ft 3 in—13 ft 7 in)
H	3.96—4.04 m (13 ft 0 in—13 ft 3 in)
I	.63—.76 ម (2 ហ្វីត 1 អ៊ីញ—2 ហ្វីត 6 អ៊ីញ)
J	3.53 ម (11 ហ្វីត 7 អ៊ីញ)
K	7.66 ម៉ែត្រ (25 ហ្វីត 2 អ៊ីញ) ដែលមានប្រដាប់បួងទម្លាក់រឹងប្រវែង 6.9 ម៉ែត្រ (22 ហ្វីត 6 អ៊ីញ) 7.67 ម៉ែត្រ (25 ហ្វីត 2 អ៊ីញ) ដែលមានប្រដាប់បួងទម្លាក់ប្រើថាមពលប្រវែង 6.9 ម៉ែត្រ (22 ហ្វីត 6 អ៊ីញ) 8.97 ម៉ែត្រ (29 ហ្វីត 5 អ៊ីញ) ដែលមានប្រដាប់បួងទម្លាក់រឹងប្រវែង 7.9 ម៉ែត្រ (26 ហ្វីត 0 អ៊ីញ) 8.72 ម៉ែត្រ (28 ហ្វីត 7 អ៊ីញ) ដែលមានប្រដាប់បួងទម្លាក់ប្រើថាមពលប្រវែង 7.9 ម៉ែត្រ (26 ហ្វីត 0 អ៊ីញ) 9.42 ម៉ែត្រ (30 ហ្វីត 11 អ៊ីញ) ដែលមានប្រដាប់បួងទម្លាក់រឹងប្រវែង 8.7 ម៉ែត្រ (28 ហ្វីត 6 អ៊ីញ)
L	5.23—5.33 ម (17 ហ្វីត 2 អ៊ីញ—17 ហ្វីត 6 អ៊ីញ)ដែលមានប្រដាប់បួងទម្លាក់រឹងមាំនិងប្រើថាមពលប្រវែង 6.9 ម (22 ហ្វីត 6 អ៊ីញ) 5.48—5.58 ម (18 ហ្វីត 0 អ៊ីញ—18 ហ្វីត 4 អ៊ីញ)ដែលមានប្រដាប់បួងទម្លាក់រឹងប្រវែង 7.9 ម៉ែត្រ (26 ហ្វីត 0 អ៊ីញ) 5.42—5.52 m (17 ហ្វីត 9 អ៊ីញ—18 ហ្វីត 1 អ៊ីញ) ដែលមានប្រដាប់បួងទម្លាក់ប្រើថាមពលប្រវែង 7.9 ម៉ែត្រ (26 ហ្វីត 0 អ៊ីញ) 5.59—5.69 ម (18 ហ្វីត 4 អ៊ីញ—18 ហ្វីត 8 អ៊ីញ)ដែលមានប្រដាប់បួងទម្លាក់រឹងប្រវែង 8.7 ម៉ែត្រ (28 ហ្វីត 6 អ៊ីញ)
M	4.51—4.62 ម (14 ហ្វីត 10 អ៊ីញ—15 ហ្វីត 2 អ៊ីញ)ដែលមានប្រដាប់បួងទម្លាក់រឹងមាំនិងប្រើថាមពលប្រវែង 6.9 ម (22 ហ្វីត 6 អ៊ីញ) 4.61—4.71 ម (15 ហ្វីត 2 អ៊ីញ—15 ហ្វីត 5 អ៊ីញ)ដែលមានប្រដាប់បួងទម្លាក់រឹងប្រវែង 7.9 ម៉ែត្រ (26 ហ្វីត 0 អ៊ីញ) 4.32—4.65 ម (14 ហ្វីត 2 អ៊ីញ—15 ហ្វីត 3 អ៊ីញ) ដែលមានប្រដាប់បួងទម្លាក់ប្រើថាមពលប្រវែង 7.9 ម៉ែត្រ (26 ហ្វីត 0 អ៊ីញ) 4.72—4.82 ម (15 ហ្វីត 6 អ៊ីញ—15 ហ្វីត 10 អ៊ីញ) ជាមួយប្រដាប់បួងទម្លាក់ 8.7 ម (28 ហ្វីត 6 អ៊ីញ)
N [a]	4.58—4.69 ម (15 ហ្វីត 0 អ៊ីញ—15 ហ្វីត 5 អ៊ីញ)ដែលមានប្រដាប់បួងទម្លាក់រឹងមាំនិងប្រើថាមពលប្រវែង 6.9 ម (22 ហ្វីត 6 អ៊ីញ) 4.91—5.01 ម (16 ហ្វីត 1 អ៊ីញ—16 ហ្វីត 5 អ៊ីញ)ដែលមានប្រដាប់បួងទម្លាក់រឹងប្រវែង 7.9 ម៉ែត្រ (26 ហ្វីត 0 អ៊ីញ) 4.84—4.95 ម (15 ហ្វីត 11 អ៊ីញ—16 ហ្វីត 3 អ៊ីញ) ដែលមានប្រដាប់បួងទម្លាក់ប្រើថាមពលប្រវែង 7.9 ម៉ែត្រ (26 ហ្វីត 0 អ៊ីញ) 5.02—5.12 ម (16 ហ្វីត 6 អ៊ីញ—16 ហ្វីត 10 អ៊ីញ)ដែលមានប្រដាប់បួងទម្លាក់រឹងប្រវែង 8.7 ម៉ែត្រ (28 ហ្វីត 6 អ៊ីញ)
O [b]	3.70—4.14 m (12 ft 1 in—13 ft 6 in) សំបកកង់ខាងក្រោយ
P [b]	3.46 ម (11 ហ្វីត 4 អ៊ីញ) ដែលមិនមានដុំបន្លាយស្មៅ ច្រវាក់ប្រវែង 60.9 ស.ម (24 អ៊ីញ) 3.59 ម (11 ហ្វីត 7 អ៊ីញ) ដែលមានដុំបន្លាយស្មៅប្រវែង 65 ម.ម (2-1/2 អ៊ីញ) ច្រវាក់ប្រវែង 60.9 ស.ម (24 អ៊ីញ) 3.75 ម (12 ហ្វីត 3 អ៊ីញ) ដែលមានដុំបន្លាយស្មៅប្រវែង 65 ម.ម (2-1/2 អ៊ីញ) ច្រវាក់ប្រវែង 76.2 ស.ម (30 អ៊ីញ) 4.40 ម (14 ហ្វីត 4 អ៊ីញ) ដែលមានដុំបន្លាយស្មៅប្រវែង 394 ម.ម (15-1/2 អ៊ីញ) ច្រវាក់ប្រវែង 76.2 ស.ម (30 អ៊ីញ) 4.54 ម (14 ហ្វីត 9 អ៊ីញ) ដែលមានដុំបន្លាយស្មៅប្រវែង 394 ម.ម (15-1/2 អ៊ីញ) ច្រវាក់ប្រវែង 91.4 ស.ម (36 អ៊ីញ)

[a] ទំហំត្រូវបានវាស់ *1.22 m (4 ft)* ពីចំណុចកំពប់។ ប្រការនេះតំណាងឲ្យប្រដាប់បួងទម្លាក់នៅពេលដាក់ចំកណ្តាលរទេះគ្រាប់ធញ្ញជាតិ។


[b] ដោយសារតែការកំណត់រចនាសម្ព័ន្ធសម្បកកង់មានលក្ខណៈខុសគ្នា គម្លាតជួរ ការកំណត់រចនាសម្ព័ន្ធស្មៅ ភាពលំនៃកង់ ទីតាំងស្មៅ និងប្រភេទសន្លះបង្ងិល នោះទទឹងគ្រឿងចក្រនឹងប្រែប្រួល។ រង្វាស់ដែលបង្ហាញនៅក្តារងគីសម្រាប់ទទឹងអតិបរមានិងអប្បបរមា។ សម្រាប់ពត៌មានបន្ថែមអំពីទទឹង សូមពិគ្រោះជាមួយអ្នកចែកចាយ *John Deere*។

OUO6075,0004EBC-KM-07JUL20-1/1


ចំណុចយោងទំហំ

តទៅទំព័របន្ទាប់

OUO6041,0000CF5-KM-13JUN18-1/2



H122741—UN—14NOV17



H122742—UN—14NOV17

OUO6041,0000CF5-KM-13JUN18-2/2

សេចក្តីប្រកាស់របស់ EC អំពីទទួលយកគ្រឿងចក្រដែលបញ្ចប់ដោយផ្នែក

សេចក្តីប្រកាស់របស់ EC អំពីទទួលយកគ្រឿងចក្រដែលបញ្ចប់ដោយផ្នែក

សេចក្តីបង្គាប់ 2006/42/EC, ឧបសម្ព័ន្ធ 2, ផ្នែក B

រោងចក្រផលិត៖

Soucy International Inc.
5450 rue St-Roch
Drummondville (Quebec) J2B 6W3
CANADA

ទំនាក់ទំនងបច្ចេកទេស៖


Ryan Black
46 Heralds Close
Wildnes
WA88AS
ប្រទេសអង់គ្លេស

<u>សេចក្តីប្រកាស៖</u>

Soucy International Inc. ក្នុងន័យនេះសូមបញ្ជាក់ថា GTS ប្រព័ន្ធច្រវាក់កសិកម្មរបស់ខ្លួន បំពេញតាមមាត្រាពាក់ព័ន្ធនៃសេចក្តីបង្គាប់អំពីគ្រឿងចក្រលេខ 2006/42/EC ជាគ្រឿងចក្រដែលបញ្ចប់ដោយផ្នែក។ ប្រព័ន្ធអាចមិនត្រូវបានដាក់ឲ្យដំណើរការមុនគ្រឿងចក្រដែលវានឹងត្រូវដាក់បញ្ចូលត្រូវប្រកាសថាបានអនុលោមតាមសេចក្តីបង្គាប់គ្រឿងចក្រលេខ 2006/42/EC, ឧបសម្ព័ន្ធ 2, ផ្នែក A។

បានចុះហត្ថលេខានៅ Drummondville, ថ្ងៃទី 1 កក្កា 2020

OUO6075,0004EB3-KM-06JUL20-1/2



Julie Tremblay

Engineering Manager, Agricultural

H122667—UN—26OCT17

OUO6075,0004EB3-KM-06JUL20-2/2

សេចក្តីប្រកាស់របស់ចក្រភពអង់គ្លេសអំពីទទួលយក គ្រឿងចក្រដែលបញ្ចប់ដោយផ្នែក

OUO6075,0005151-KM-27MAY21-1/2

UK DECLARATION OF INCORPORATION OF PARTLY COMPLETED MACHINERY

MACHINERY DIRECTIVE S.I. 2008/1597

Manufacturer:

Soucy International Inc.
5450 rue St-Roch
Drummondville (Quebec) J2B 6W3
CANADA

Technical Contact:

Ryan Black
46 Heralds Close
Widnes, WA88AS
ENGLAND

Declaration:

Soucy International Inc. hereby certifies that its agricultural track system GTS fulfill all the relevant provisions of the Machinery Directive S.I. 2008/1597 as a partly completed machinery. The system may not be put into service before machinery in which it will be incorporated is declared to comply to the machinery directive S.I. 2008/1597.

Signed at Drummondville, May 27th, 2021

Pierre-Yves Pépin
Engineering manager, Agricultural


H134553—UN—27MAY21

OUO6075,0005151-KM-27MAY21-2/2


ស្លាកសម្គាល់ច្រវាក់

តទៅទំព័របន្ទាប់

OUO6041,0000CFA-KM-05DEC17-1/2



ស្លាកសម្គាល់គំរូ (ច្រវាក់ខាងឆ្វេងដៃ)



ស្លាកសម្គាល់គំរូ (ច្រវាក់ខាងស្តាំដៃ)

កំណត់ចំណាំ៖ បានបង្ហាញស្លាកលេខស៊េរីច្រវាក់ *76.2* ស.ម *(30 អ៊ីញ)*


ស្លាកលេខស៊េរីច្រវាក់ *60.9* ស.ម *(24 អ៊ីញ)* និង *91.4* ស.ម *(36 អ៊ីញ)* គឺដូចគ្នា។

OUO6041,0000CFA-KM-05DEC17-2/2

ទីតាំងស្លាកសម្គាល់

OUO6041,0000C3C-KM-25AUG17-1/2

ស្ថិតនៅផ្នែកខាងក្នុងម៉ូឌុលច្រវាក់នីមួយៗ



OUO6041,0000C3C-KM-25AUG17-2/2

ការបង្ការអគ្គិភ័យ

ការបង្ការអគ្គីភ័យតាមការណែនាំ

លោកអ្នកត្រូវតែធ្វើការត្រួតពិនិត្យគ្រឿងចក្រនេះតាមកាលកំណត់ពេញមួយរដូវកាលប្រមូលផល។ គំនរសម្ភារៈដើមដំណាំ និងកម្ទេចកម្ទីដទៃទៀតត្រូវតែយកចេញ ដើម្បីឲ្យគ្រឿងចក្របំពេញមុខងារបានត្រឹមត្រូវ និងកាត់បន្ថយគ្រោះអគ្គីភ័យ។

ការសម្អាតគ្រឿងចក្របានហ្មត់ចត់និងទៀងទាត់គួបផ្សំនិងទម្រង់ការថែទាំតាមទម្លាប់ដទៃទៀតដែលបានរៀបរាប់នៅក្នុងសៀវភៅណែនាំប្រើប្រាស់នេះ ជួយកាត់បន្ថយគ្រោះអគ្គីភ័យឱកាសខូចខាតដែលនាំឲ្យចំណាយប្រាក់កាសច្រើន ហើយជួយបង្កើនប្រសិទ្ធពលរបស់គ្រឿងចក្រ។

ជានិច្ចកាល ចូរអនុវត្តតាមទម្រង់ការសុវត្ថិភាពទាំងឡាយដែលមានបិទនៅលើគ្រឿងចក្រនិងនៅក្នុងសៀវភៅណែនាំប្រើប្រាស់នេះ។ មុនពេលធ្វើការត្រួតពិនិត្យ ឬសម្អាតគ្រឿងចក្រ ចូរពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ និងដោះសោចេញ។

គ្រឿងចក្ររបស់លោកអ្នកមានបំពាក់បំពង់ពន្លត់អគ្គីភ័យប្រើម្សៅទូទៅ និងបំពង់ពន្លត់ផ្គុកសារធាតុរាវបញ្ចូលសម្ពាធ។ លោកអ្នកត្រូវតែត្រួតពិនិត្យបំពង់ពន្លត់អគ្គីភ័យរាល់ថ្ងៃនៅពេលចូលក្នុង ឬចាកចេញពីកាប៊ីន និងនៅពេលធ្វើការងារជុំវិញគ្រឿងចក្រដើម្បីធានាឲ្យប្រាកដថាបំពង់ពន្លត់ទាំងអស់អាចប្រើការបាន។ ត្រូវតែប្តូរបំពង់ពន្លត់អគ្គីភ័យចេញ ឬត្រូវតែផ្តល់សេវាថែទាំប្រកបដោយជំនាញវិជ្ជាជីវៈបន្ទាប់ពីប្រើប្រាស់រួច។

ដើម្បីជ្រាបនូវព័ត៌មានបន្ថែម ចូរអានផ្នែកលាងសម្អាតគ្រឿងចក្រ។

OUO6075,00042AA-KM-15JUN16-1/1

ប្រតិបត្តិការបំពង់ពន្លត់អគ្គីភ័យ

គ្រឿងចក្ររបស់លោកអ្នកមានបំពាក់បំពង់ពន្លត់អគ្គីភ័យប្រើម្សៅទូទៅ និងបំពង់ពន្លត់ផ្គុកសារធាតុរាវបញ្ចូលសម្ពាធ។ លោកអ្នកត្រូវតែត្រួតពិនិត្យបំពង់ពន្លត់អគ្គីភ័យរាល់ថ្ងៃនៅពេលចូលក្នុង ឬចាកចេញពីកាប៊ីន និងនៅពេលធ្វើការងារជុំវិញគ្រឿងចក្រដើម្បីធានាឲ្យប្រាកដថាបំពង់ពន្លត់ទាំងអស់អាចប្រើការបាន។ ត្រូវតែប្តូរបំពង់ពន្លត់អគ្គីភ័យចេញ ឬត្រូវតែផ្តល់សេវាថែទាំប្រកបដោយជំនាញវិជ្ជាជីវៈបន្ទាប់ពីប្រើប្រាស់រួច។

អនុសាសន៍ស្តីពីបំពង់ពន្លត់អគ្គីភ័យ

សំខាន់៖ ចូរអានស្លាកសញ្ញានៅលើបំពង់ពន្លត់អគ្គីភ័យ និងស្វែងយល់ពីលំណែនាំនិងបំរាមក្នុងការប្រើប្រាស់។

បំពង់ពន្លត់អគ្គីភ័យជាតិម្សៅប្រើប្រាស់ទូទៅ៖


- ប្រើបំពង់ពន្លត់សម្រាប់អគ្គីភ័យដែលបណ្តាលមកពីខ្លាញ់ ប្រេង អគ្គិសនី និងសារធាតុគីមី។

បំពង់ពន្លត់អគ្គីភ័យសារធាតុរាវបញ្ចូលសម្ពាធ៖

- ប្រើចំពោះអគ្គីភ័យឆាបឆេះគំនរសម្ភារៈដើមដំណាំ ឬកម្ទេចកម្ទីដើមដំណាំ។

តទៅទំព័របន្ទាប់

OUO6075,0004F79-KM-12NOV20-1/2



H132365—UN—12NOV20

ការប្រើប្រាស់បំពង់ពន្លត់អគ្គីភ័យ

ដ្យាក្រាមបង្ហាញពីវិធីដែលបានណែនាំក្នុងការពន្លត់អគ្គីភ័យ។ ជានិច្ចកាល ចូរតម្រង់តួក្បាលបាញ់សំដៅបាតកន្លែងឆេះភ្លើងជានិច្ច។

ចំណុចដូចតទៅនេះគឺជាជំហានមូលដ្ឋានក្នុងការប្រើប្រាស់បំពង់ពន្លត់អគ្គីភ័យ៖

1. ដោះបំពង់ពន្លត់អគ្គីភ័យចេញពីកែងទម្រ ហើយយកទៅតំបន់មានភ្លើងឆេះ។
2. ចូលទៅកាន់តំបន់អគ្គីភ័យដោយស្ថិតនៅពីលើខ្យល់។
3. ទាញកន្លាស់សុវត្ថិភាពចេញពីផ្នែកខាងលើបំពង់ពន្លត់អគ្គីភ័យ។
4. កាន់ដងបំពង់ពន្លត់អគ្គីភ័យបញ្ឈរ ហើយតម្រង់ទុយោឲ្យចំ **គូ** នៃអណ្តាតភ្លើង។
5. ច្របាច់ដងដើម្បីបាញ់បំពង់ពន្លត់អគ្គីភ័យ។
6. រំកិលក្បាលបាញ់ទៅមុខនិងទៅក្រោយ ដោយស្រោចពពុះម្សៅលើអណ្តាតភ្លើង។

បញ្ជីឈ្មៀងផ្ទាត់ត្រួតពិនិត្យ

យ៉ាងតិចម្តងក្នុងមួយឆ្នាំ ចូរពិនិត្យបំពង់ពន្លត់អគ្គីភ័យ និងធានានូវចំណុចដូចតទៅ៖

1. តើបំពង់ពន្លត់អគ្គីភ័យដាក់នៅត្រង់ទីតាំងកំណត់នៅលើជណ្តើរកាប៊ីន និងនៅខាងក្រោយគ្រឿងចក្រដែរឬទេ?
2. តើមានអ្វីទើសទែងក្នុងការលូកយក ឬបាំងមើលមិនឃើញទេ?
3. តើលំណែនាំប្រើប្រាស់នៅលើស្លាកឈ្មោះអាចអានដាច់ និងបែរចេញក្រៅទេ?
4. តើហ្វឺតសុវត្ថិភាពមានបែកបាក់ ឬបាត់បង់ទេ?
5. តើបំពង់ពន្លត់អគ្គីភ័យពេញទេ? (កំណត់ដឹងដោយការថ្លឹង ឬ"ថ្លឹងមើល")
6. តើមានការខូចខាតរូបរាង ការសឹករេចរឹល ការលេចធ្លាយ ឬក្បាលបាញ់ស្ទះទេ?
7. តើខ្សែរឹតដែកកែងទម្របំពង់ពន្លត់អគ្គីភ័យមានស្ថានភាពល្អដែរឬទេ?
8. តើខ្សែរឹតដែកកែងទម្របំពង់ពន្លត់អគ្គីភ័យតឹងណែននៅលើបំពង់ពន្លត់អគ្គីភ័យដែរឬទេ?

នៅពេលពិនិត្យបំពង់ពន្លត់អគ្គីភ័យឃើញមានបញ្ហា ចូរផ្តល់សេវាថែទាំ ឬប្តូរចោល។

OUO6075,0004F79-KM-12NOV20-2/2

សាកបញ្ចូលបំពង់ពន្លត់អគ្គីភ័យរាវ (អឺរ៉ុប អូស្ត្រាលី និងណូវែលសេឡង់) (បើចាំបាច់)

តទៅទំព័របន្ទាប់

OUO6075,0004A04-KM-28JUN18-1/2

កំណត់ចំណាំ៖ បំពង់ពន្លត់អគ្គីភ័យរាវអាចដឹកជញ្ជូនដោយមិនបាច់សាកបញ្ចូល។ មុនពេលដឹកគ្រឿងចក្រទៅប្រគល់ជូនអតិថិជន ត្រូវតែសាកបំពង់ពន្លត់អគ្គីភ័យរាវ។

នៅពេលប្រើការសាកបញ្ចូលប្រឆាំងកំណកដើម្បីបង្កកការពារបំពង់ពន្លត់អគ្គីភ័យ តម្រូវឲ្យមានការបញ្ចេញទាំងអស់និងការថែទាំ។

បំពង់អគ្គីភ័យដែលបានបង្ហាញអាចប្រែប្រួលដោយអាស្រ័យទៅលើសេចក្តីតម្រូវរបស់ប្រទេស និងរោងចក្រផលិតបំពង់ពន្លត់អគ្គីភ័យ។

⚠ ប្រយ័ត្ន៖ មុនពេលសាកឡើងវិញ ចូរជ្រាកដថាបំពង់ពន្លត់អគ្គីភ័យអស់សម្ពាធទាំងស្រុង។

1. ចូរអានព័ត៌មានដែលភ្ជាប់មកជាមួយបំពង់ពន្លត់អគ្គីភ័យដើម្បីបំពេញ និងសាកបញ្ចូលឲ្យបានត្រឹមត្រូវ។
2. ដំឡើងបំពង់ពន្លត់អគ្គីភ័យនៅលើគ្រឿងចក្រ។



H117901—UN—28MAR16

OUO6075,0004A04-KM-28JUN18-2/2

គ្រប់គ្រងចាត់ចែងប្រេងដោយសុវត្ថិភាព—ជៀសវាងអគ្គីភ័យ

DX,FIRE1-KM-12OCT11-1/2

ចាត់ចែងប្រេងឥន្ធនៈដោយយកចិត្តទុកដាក់៖ វាងាយឆាបឆេះយ៉ាងខ្លាំង។ កុំចាក់ប្រេងគ្រឿងចក្រខណៈពេលកំពុងជក់បារី ឬពេលស្ថិតនៅជិតអណ្តាតភ្លើង ឬផ្កាភ្លើង។

ជានិច្ចកាល ត្រូវពន្លត់ម៉ាស៊ីនមុនពេលចាក់ប្រេងគ្រឿងចក្រ។ ចាក់បំពេញធុងប្រេងនៅខាងក្រៅអគារ។

បង្ការអគ្គីភ័យដោយរក្សាកុំឲ្យម៉ាស៊ីនមានបណ្តុំសំរាម ខ្លាញ់ និងកំទេចសឹក។ ត្រូវជូតសម្អាតប្រេងដែលហៀរកំពប់ជានិច្ច។

ប្រើប្រាស់តែធុងប្រេងណា ដែលមានការអនុញ្ញាតសម្រាប់ការដឹកជញ្ជូនធាតុរាវដែលអាចឆាបឆេះបានប៉ុណ្ណោះ។

មិនត្រូវចាក់ប្រេងបំពេញធុង នៅក្នុងទ្រុងក្រោយរបស់រថយន្តភិកអាប់ (pickup truck) ដែលមានទ្រនាប់បាតជាដែរផ្លាស្ទិកឡើយ។ ត្រូវដាក់ធុងប្រេងនៅលើដី មុននឹងចាក់ប្រេង គ្រប់ពេលដែលត្រូវចាក់ប្រេងដាក់ធុង ។ មុនពេលបើកគម្របធុងដើម្បីចាក់ប្រេង ត្រូវដាក់ក្បាលទុយោបាញ់បញ្ចូលប្រេងអោយប៉ះធុងប្រេង ជាមុនសិន។ រក្សាអោយក្បាលទុយោបាញ់បញ្ចូលប្រេងប៉ះ ជាមួយនឹងមាត់ធុងប្រេងនៅពេលចាក់ប្រេង។



TS202—UN—23AUG88

កុំទុកដាក់ធុងប្រេងនៅកន្លែងណាដែលមាន អណ្តាតភ្លើង ផ្កាភ្លើង ឬភ្លើងសម្រាប់បញ្ឆេះ ដូចជានៅក្នុងឧបករណ៍ដាំទឹកក្តៅ ឬឧបករណ៍ផ្សេងៗទៀត។

DX,FIRE1-KM-12OCT11-2/2

គ្រឿងសម្រាប់គ្រោះអាសន្ន


តទៅទំព័របន្ទាប់

DX,FIRE2-KM-03MAR93-1/2

ត្រូវមានការត្រៀមខ្លួន ប្រសិនបើអគ្គីភ័យចាប់ផ្តើមឡើង។

រក្សាទុកប្រអប់សង្គ្រោះបឋម និងបំពង់ពន្លត់អគ្គីភ័យនៅជិតខ្លួន។

រក្សាទុកលេខទូរស័ព្ទដែលត្រូវប្រើនៅគ្រាមានអាសន្នដូចជា រថដ្ឋបណ្តិត សេវាថែទាំសង្គ្រោះ មន្ទីរពេទ្យ និងផ្នែកពន្លត់អគ្គីភ័យនៅជិតទូរស័ព្ទរបស់អ្នក។



TS291—UN—15APR13

DX,FIRE2-KM-03MAR93-2/2

គ្រប់គ្រងនិងប្រើប្រាស់ ប្រេងបង្អោះដោយសុវត្ថិភាព

DX,FIRE3-KM-14MAR14-1/2

ប្រេងបង្អោះគឺងាយឆាបឆេះបំផុត។

នៅពេលប្រើប្រាស់វា ត្រូវស្ថិតនៅឆ្ងាយពី ជ្រាភ្លើង និងអណ្តាតភ្លើង។ ទុកប្រេងបង្អោះ អោយឆ្ងាយពីអាគុយ ឬពិល និងខ្សែភ្លើងផ្សេងៗ។

ដើម្បីបង្ការការកំពប់ ឬលិចធ្លាយដោយចៃដន្យ នៅពេលរក្សាទុកកំប៉ុងដែលមានសម្ពាធ ត្រូវគ្របគម្របវា ហើយត្រូវរក្សាទុកនៅក្នុងទីតាំងដែលត្រជាក់ និងមានការការពារ។

កុំដុត ឬចាក់ទម្លុះកំប៉ុងប្រេងបង្អោះអោយសោះ។

កុំប្រើប្រេងបង្អោះ ជាមួយម៉ាស៊ូនដែលមានបំពាក់នូវ ប៊ូស៊ីកំដៅ (glow plugs) ឬឧបករណ៍កម្តៅខ្យល់សម្រាប់ចំហេះម៉ាស៊ូន។



TS1356—UN—18MAR92

DX,FIRE3-KM-14MAR14-2/2

សម្អាតកម្ទេចកម្ទីដើមដំណាំដែលកកកុញ

HX,9010SA,B-KM-23AUG97-1/2

គំនរអំពុកចំបើងនៅក្នុងបន្ទប់ម៉ាស៊ូន នៅលើម៉ាស៊ូន និងនៅជិតគ្រឿងមានចលនាអាចបង្ករជាអគ្គីភ័យ។ ចូរពិនិត្យនិងសម្អាតតំបន់ទាំងនេះឲ្យបានញឹកញាប់។ មុនពេលត្រួតពិនិត្យ និងផ្តល់សេវាថែទាំ ចូរពន្លត់ម៉ាស៊ូន ដាក់ហ្វ្រាំងដៃ និងដកសោចេញ។



TS227—UN—15APR13

HX,9010SA,B-KM-23AUG97-2/2

បំពង់ពន្លត់អគ្គីភ័យ (អឺរ៉ុប)

តទៅទំព័របន្ទាប់

OUO6075,00042F6-KM-20JUN16-1/2

⚠ ប្រយ័ត្ន៖ បំពង់ពន្លត់អគ្គីភ័យត្រូវតែគោរពតាមបទបញ្ជា និងច្បាប់របស់រដ្ឋាភិបាលក្នុងតំបន់៖

- **បំពង់ពន្លត់អគ្គីភ័យប្រើម្សៅទូទៅគឺមានទម្ងន់យ៉ាងហោចណាស់ 6 គ.ក (13 ផោន)**
- **បំពង់ពន្លត់អគ្គីភ័យវត្ថុរាវប្រើសម្ពាធ (បើមាន) មានចំណុះអប្បបរមា 8 ល (2.1 ហ្គាឡុង)**

កំណត់ចំណាំ៖ បំពង់ពន្លត់អគ្គីភ័យដែលបានបង្ហាញអាចខុសគ្នា អាស្រ័យតាមតម្រូវប្រទេស និងក្រុមហ៊ុនផលិតបំពង់ពន្លត់អគ្គីភ័យ។

បំពង់ពន្លត់អគ្គីភ័យប្រើម្សៅទូទៅ និងបំពង់ពន្លត់ផ្ទុកសារធាតុរាវបញ្ចូលសម្ពាធដែលមានដែកកែងទម្របំពាក់ត្រូវដំឡើងនៅលើគ្រឿងចក្ររបស់លោកអ្នក។

ចូរអានស្លាកសញ្ញានៅលើបំពង់ពន្លត់អគ្គីភ័យ និងស្វែងយល់ពីលំណែនាំស្តីពីរបៀបប្រើប្រាស់និងរក្សាទុក។ នៅពេលបំពង់ពន្លត់អគ្គីភ័យប្រើអស់ ទោះជាប្រើរយៈពេលប៉ុណ្ណាក៏ដោយ ត្រូវតែសាកបញ្ចូលវិញ ឬបម្លាស់ថ្មី។

សំខាន់៖ មិនត្រូវដាក់បំពង់ពន្លត់អគ្គីភ័យដែលប្រើសារធាតុរាវបញ្ចូលសម្ពាធឲ្យត្រូវអាកាសធាតុត្រជាក់កកឡើយ ប្រសិនបើមិនបានដាក់អង្គធាតុប្រឆាំងកំណកចូលទេនោះ។ សម្រាប់ព័ត៌មានបន្ថែម ចូរអានរូបសញ្ញាលំណែនាំនៅលើបំពង់ពន្លត់អគ្គីភ័យ។



H92841—UN—16SEP08

បំពង់ពន្លត់អគ្គីភ័យជាតិម្សៅប្រើប្រាស់ទូទៅ/សារធាតុរាវ

OUO6075,00042F6-KM-20JUN16-2/2

បំពង់ពន្លត់អគ្គីភ័យ (នូវែលសេឡង់ និងអូស្ត្រាលី)

OUO6075,00042F7-KM-20JUN16-1/2

⚠ ប្រយ័ត្ន៖ បំពង់ពន្លត់អគ្គីភ័យត្រូវតែគោរពតាមបទបញ្ជា និងច្បាប់របស់រដ្ឋាភិបាលក្នុងតំបន់៖

- **បំពង់ពន្លត់អគ្គីភ័យប្រើម្សៅទូទៅគឺមានទម្ងន់យ៉ាងហោចណាស់ 4 kg (10 lb)**
- **បំពង់ពន្លត់អគ្គីភ័យវត្ថុរាវប្រើសម្ពាធមានចំណុះអប្បបរមា 8 L (2.1 gal)**

កំណត់ចំណាំ៖ បំពង់ពន្លត់អគ្គីភ័យដែលបានបង្ហាញអាចខុសគ្នា អាស្រ័យតាមតម្រូវប្រទេស និងក្រុមហ៊ុនផលិតបំពង់ពន្លត់អគ្គីភ័យ។

បំពង់ពន្លត់អគ្គីភ័យប្រើម្សៅទូទៅ និងបំពង់ពន្លត់ផ្ទុកសារធាតុរាវបញ្ចូលសម្ពាធដែលមានដែកកែងទម្របំពាក់ត្រូវដំឡើងនៅលើគ្រឿងចក្ររបស់លោកអ្នក។

ចូរអានស្លាកសញ្ញានៅលើបំពង់ពន្លត់អគ្គីភ័យ និងស្វែងយល់ពីលំណែនាំស្តីពីរបៀបប្រើប្រាស់និងរក្សាទុក។ នៅពេលបំពង់ពន្លត់អគ្គីភ័យប្រើអស់ ទោះជាប្រើរយៈពេលប៉ុណ្ណាក៏ដោយ ត្រូវតែសាកបញ្ចូលវិញ ឬបម្លាស់ថ្មី។

សំខាន់៖ មិនត្រូវដាក់បំពង់ពន្លត់អគ្គីភ័យដែលប្រើសារធាតុរាវបញ្ចូលសម្ពាធឲ្យត្រូវអាកាសធាតុត្រជាក់កកឡើយ ប្រសិនបើមិនបានដាក់អង្គធាតុប្រឆាំងកំណកចូលទេនោះ។ សម្រាប់ព័ត៌មានបន្ថែម ចូរអានរូបសញ្ញាលំណែនាំនៅលើបំពង់ពន្លត់អគ្គីភ័យ។



H117754—UN—17MAR16

បំពង់ពន្លត់អគ្គីភ័យជាតិម្សៅប្រើប្រាស់ទូទៅ/សារធាតុរាវ

OUO6075,00042F7-KM-20JUN16-2/2

បំពង់ពន្លត់អគ្គីភ័យ (សហភាពសេដ្ឋកិច្ចអាស៊ីអឺរ៉ុប)

តទៅទំព័របន្ទាប់

OUO6075,00049FE-KM-28JUN18-1/2

⚠ ប្រយ័ត្ន៖ បំពង់ពន្លត់អគ្គីភ័យត្រូវតែគោរពតាមបទបញ្ជា និងច្បាប់របស់រដ្ឋាភិបាលក្នុងតំបន់៖

- **បំពង់ពន្លត់អគ្គីភ័យប្រើម្សៅទូទៅគឺមានទម្ងន់យ៉ាងហោចណាស់ 6 គ.ក (13 ផោន)**
- **បំពង់ពន្លត់អគ្គីភ័យបន្សំសារធាតុរាវនិងពពុះប្រើសម្ពាធមានចំណុះអប្បបរមា 8 ល (2.1 ហ្គាឡុង)**

កំណត់ចំណាំ៖ បំពង់ពន្លត់អគ្គីភ័យដែលបានបង្ហាញអាចខុសគ្នា អាស្រ័យតាមតម្រូវប្រទេស និងក្រុមហ៊ុនផលិតបំពង់ពន្លត់អគ្គីភ័យ។

បំពង់ពន្លត់អគ្គីភ័យប្រើម្សៅទូទៅ និងបំពង់ពន្លត់អគ្គីភ័យបន្សំសារធាតុរាវបញ្ចូលសម្ពាធនិងពពុះដែលមានដែកកែងទម្របំពាក់ត្រូវដំឡើងនៅលើគ្រឿងចក្ររបស់លោកអ្នក។

ចូរអានស្លាកសញ្ញានៅលើបំពង់ពន្លត់អគ្គីភ័យ និងស្វែងយល់ពីលំណែនាំស្តីពីរបៀបប្រើប្រាស់និងរក្សាទុក។ នៅពេលបំពង់ពន្លត់អគ្គីភ័យប្រើអស់ ទោះជាប្រើរយៈពេលប៉ុណ្ណាក៏ដោយ ត្រូវតែសាកបញ្ចូលវិញ ឬប្តូរថ្មី។

សំខាន់៖ មិនត្រូវដាក់បំពង់ពន្លត់អគ្គីភ័យសារធាតុរាវបញ្ចូលសម្ពាធនិងពពុះឲ្យត្រូវអាកាសធាតុត្រជាក់កកឡើយ។ សម្រាប់ព័ត៌មានបន្ថែម ចូរអានរូបសញ្ញាលំណែនានៅលើបំពង់ពន្លត់អគ្គីភ័យ។



H117754—UN—17MAR16

បំពង់ពន្លត់អគ្គីភ័យជាតិម្សៅប្រើប្រាស់ទូទៅ/បន្សំសារធាតុរាវនិងពពុះ

OUO6075,00049FE-KM-28JUN18-2/2

ទីតាំងបំពង់ពន្លត់អគ្គីភ័យ

OUO6075,0004911-KM-02MAR18-1/2



H123653—UN—02MAR18

ទីតាំងបំពង់ពន្លត់អគ្គីភ័យខាងមុខ

កំណត់ចំណាំ៖ បំពង់ពន្លត់អគ្គីភ័យដែលបានបង្ហាញអាចខុសគ្នា អាស្រ័យតាមតម្រូវប្រទេស និងក្រុមហ៊ុនផលិតបំពង់ពន្លត់អគ្គីភ័យ។



H123654—UN—02MAR18

ទីតាំងបំពង់ពន្លត់អគ្គីភ័យខាងក្រោយ

បំពង់ពន្លត់អគ្គីភ័យប្រើទូទៅស្ថិតនៅលើផ្លែតហ្វមជណ្តើរខាងខ។

បំពង់ពន្លត់អគ្គីភ័យសារធាតុរាវប្រើសម្ពាធ (បើមាន) ស្ថិតនៅខាងក្នុងទ្វារចូលម៉ាស៊ីនខាងក្រោយផ្នែកខាងស្តាំ។

OUO6075,0004911-KM-02MAR18-2/2

ករណីមានអគ្គីភ័យ

តទៅទំព័របន្ទាប់

DX,FIRE4-KM-22AUG13-1/2

⚠ ប្រយ័ត្ន៖ ជៀសវាងគ្រោះថ្នាក់ដល់ខ្លួនឯងនិង មនុស្សដទៃ។

ត្រូវពន្លត់ម៉ាស៊ីនជាបន្ទាន់ នៅពេលឃើញមានសញ្ញាដំបូងនៃអគ្គីភ័យ។ អគ្គីភ័យអាចសម្គាល់ដោយក្លិនឈ្ងៀមឆ្ងែង ឬឃើញមានអណ្តាតភ្លើង។ ដោយសារតែភ្លើងឆេះ និងរាលដាលឆាប់រហ័ស ត្រូវចុះពីគ្រាក់ទ័រជាបន្ទាន់ ហើយរត់ទៅទីសុវត្ថិភាពចេញពីអគ្គីភ័យ។ កុំត្រឡប់ទៅរកគ្រាក់ទ័រវិញ! អាទិភាពជាចម្បងគឺ សុវត្ថិភាព។

ហៅទូរស័ព្ទទៅកាន់អ្នកពន្លត់អគ្គីភ័យ។ បំពង់ពន្លត់អគ្គីភ័យខ្នាតតូច (យកតាមខ្លួនបាន) អាចពន្លត់ភ្លើងដែលឆេះតិចតួច ឬបង្ក្រាបអគ្គីភ័យរហូតដល់ពេលអ្នកពន្លត់អគ្គីភ័យមកដល់; ប៉ុន្តែសមត្ថភាពបំពង់ពន្លត់អគ្គីភ័យខ្នាតតូចគឺមានកម្រិត។ ជានិច្ចកាលត្រូវផ្តល់អាទិភាពជាចម្បងទៅលើសុវត្ថិភាពអ្នកបើកបរ និងអ្នកនៅក្បែរ។ ប្រសិនបើព្យាយាមពន្លត់អគ្គីភ័យ អ្នកត្រូវឈរនៅលើខ្សល់ ហើយត្រូវមានផ្លូវសម្រាប់រត់គេចដែលគ្មានឧបសគ្គ ដើម្បីឲ្យអ្នកអាចរត់ចេញបានឆាប់រហ័ស ប្រសិនបើពុំអាចពន្លត់អគ្គីភ័យបាន។

សូមអានសេចក្តីណែនាំអំពីបំពង់ពន្លត់អគ្គីភ័យ និងដឹងច្បាស់អំពីទីតាំងទុកបំពង់ និងរបៀបប្រើប្រាស់វាឲ្យបានមុនពេល ដែលមានអគ្គីភ័យ។ នាយកដ្ឋានពន្លត់អគ្គីភ័យ ឬអ្នកចែកចាយឧបករណ៍ពន្លត់អគ្គីភ័យក្នុងមូលដ្ឋាន អាចផ្តល់ការបណ្តុះបណ្តាល និងការណែនាំអំពីរបៀបប្រើប្រាស់បំពង់ពន្លត់អគ្គីភ័យ។



TS227—UN—15APR13

ប្រសិនបើបំពង់ពន្លត់អគ្គីភ័យរបស់អ្នកពុំមានសេចក្តីណែនាំទេនោះ សូមគោរពតាមគោលការណ៍ទូទៅទាំងនេះ៖


1. ទាញមួលគន្លឹះ។ កាន់បំពង់ពន្លត់អគ្គីភ័យ ដោយក្បាលទុយោពន្លត់តម្រង់ចេញឆ្ងាយពីអ្នក ហើយដកគន្លឹះសោរ។
2. តម្រង់ឲ្យទាប។ តម្រង់ក្បាលពន្លត់អគ្គីភ័យឲ្យចំនុចឆេះភ្លើង។
3. ច្របាច់ដៃជាញ់របស់បំពង់ យឺតៗនិងឲ្យស្មើដៃ។
4. រេក្បាលទុយោពន្លត់ពីម្ខាងទៅម្ខាង។

DX,FIRE4-KM-22AUG13-2/2

សម្អាតថតម៉ាស៊ីន

OUO6075,0000575-KM-17MAR10-1/2

⚠ ប្រយ័ត្ន៖ ចូរកុំសម្អាតម៉ាស៊ីន ឬបន្ទប់ម៉ាស៊ីននៅពេលម៉ាស៊ីនកំពុងដំណើរការ។ ឌី ប្រេង និងកម្ទេចកម្ទីដើមដំណាំនៅក្នុងបន្ទប់ម៉ាស៊ីន និងនៅលើម៉ាស៊ីនអាចឆាបឆេះ។ ទិសដៅខ្សល់ ប្រភេទដើមដំណាំ និងចំណុះសំណើម អាចមានឥទ្ធិពលលើទីកន្លែងនិងបរិមាណដែលអំពុកចង់បើងនិងកម្ទេចកម្ទីកកកុញលើគ្រឿងចក្រ។ ចូរពិនិត្យនិងសម្អាតតំបន់នេះឲ្យបានញឹកញាប់។



H95319—UN—11FEB10

OUO6075,0000575-KM-17MAR10-2/2

ការសម្អាតគ្រឿងចក្រ

ល់ណែនាំពីការសម្អាតទូទៅ

លោកអ្នកត្រូវតែធ្វើការត្រួតពិនិត្យគ្រឿងចក្រនេះតាមកាលកំណត់ពេញមួយថ្ងៃធ្វើការ។ គំនរសម្ភារដើមដំណាំ និងកម្ទេចកម្ទីដទៃទៀតត្រូវតែយកចេញ ដើម្បីឲ្យគ្រឿងចក្របំពេញមុខងារបានត្រឹមត្រូវ និងកាត់បន្ថយគ្រោះអគ្គីភ័យ។ ភាពញឹកញាប់នៃការត្រួតពិនិត្យនិងការសម្អាតនឹងប្រែប្រួលអាស្រ័យទៅលើកត្តាមួយចំនួន ដែលរួមមានលក្ខខណ្ឌប្រតិបត្តិការ ការកំណត់គ្រឿងចក្រ លក្ខខណ្ឌដើមដំណាំ ល្បឿនប្រតិបត្តិការ និងលក្ខខណ្ឌអាកាសធាតុ។ ការត្រួតពិនិត្យនិងការសម្អាតអាចត្រូវការធ្វើឡើងច្រើនដងនៅក្នុងរដូវប្រមូលផល ជាពិសេសនៅពេលអាកាសធាតុស្ងួត ក្តៅ ហើយមានខ្យល់។

សំខាន់៖ ការសម្អាតគ្រឿងចក្របានហ្មត់ចត់និងទៀងទាត់ គួបផ្សំនិងទម្រង់ការថែទាំតាមទម្លាប់ដទៃទៀតដែលបានរៀបរាប់នៅក្នុងសៀវភៅណែនាំប្រើប្រាស់នេះ ជួយកាត់បន្ថយគ្រោះអគ្គីភ័យ ឱកាសខូចខាតដែលនាំឲ្យចំណាយប្រាក់កាសច្រើន ហើយជួយបង្កើនប្រសិទ្ធពលរបស់គ្រឿងចក្រ។

សម្ភារដើមដំណាំនិងកម្ទេចកម្ទីដទៃទៀតអាចកកនៅក្នុងកន្លែងផ្សេងៗ។ ទិសដៅខ្យល់ ប្រភេទដើមដំណាំ និងចំណុះសំណើមដើមដំណាំ អាចប៉ះពាល់ដល់ទីកន្លែងនិងបរិមាណដែលសម្ភារដើមដំណាំនិងកម្ទេចកម្ទីអាចកកកុញលើគ្រឿងចក្រ។ ចូរស្វែងយល់ពីលក្ខខណ្ឌប្រមូលផលនិងលៃតម្រូវកាលវិភាគសម្អាតរបស់លោកអ្នក ដើម្បីឲ្យគ្រឿងចក្របំពេញមុខងារបានត្រឹមត្រូវ និងកាត់បន្ថយគ្រោះអគ្គីភ័យ។ ចូរពិនិត្យនិងសម្អាតតំបន់ទាំងនេះតាមចាំបាច់ពេញមួយថ្ងៃធ្វើការ។

ការច្រូតកាត់ដំណាំមួយចំនួនអាចបណ្តាលឲ្យមានបញ្ហាពិសេស។ ដំណាំខ្លះ"ស្អិត" ហើយពេលច្រូតកាត់ដំណាំប្រភេទនេះ វាមានការលំបាកក្នុងការសម្អាតគ្រឿងចក្រ។ ដំណាំប្រភេទនេះមានដើមដង្កាឈូកវ័ត្ត ដើមកាណូឡា និងដើមដង្កាសារ (safflower)។ ពេលច្រូតកាត់ដំណាំប្រភេទនេះ ត្រូវតែសម្អាតគ្រឿងចក្រដោយយកចិត្តទុកដាក់ជាពិសេស។

ជានិច្ចកាល ចូរអនុវត្តតាមទម្រង់ការសុវត្ថិភាពទាំងឡាយដែលមានបិទនៅលើគ្រឿងចក្រនិងនៅក្នុងសៀវភៅណែនាំប្រើប្រាស់នេះ។ មុនពេលធ្វើការត្រួតពិនិត្យ ឬសម្អាតគ្រឿងចក្រ ចូរពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ និងដោះសោចេញ។

OUO6075,0001167-KM-21JUN12-1/1

កូដឆ្លើយតប (QR) រហ័ស

តទៅទំព័របន្ទាប់

OUO6075,0004DE7-KM-01APR20-1/2

H129714—UN—01APR20

កូដ *QR* ភាសាអង់គ្លេស

H129715—UN—01APR20

កូដ *QR* ភាសាបារាំង

H129716—UN—01APR20

កូដ *QR* ភាសាអាល្លឺម៉ង់

H129717—UN—01APR20

កូដ *QR* ភាសាអេស្ប៉ាញ

នៅផ្នែកខាងលើនៃមគ្គុទេសក៍សម្អាតគឺជាកូដឆ្លើយតប (QR) រហ័សដែលភ្ជាប់ទៅនឹងវីដេអូណែនាំពីការសម្អាតខ្លីមួយ។

ចូលមើលខ្លឹមសារពីកូដ QR ដោយទាញយកកម្មវិធីស្កេន QR ដាក់ក្នុងទូរសព្ទដៃរបស់អ្នក។ បើកកម្មវិធីនេះ ហើយតម្រង់ការមេរ៉ាទូរសព្ទរបស់អ្នកឲ្យចំលេខកូដដើម្បីភ្ជាប់ទៅនឹងមេឌៀ។

OUO6075,0004DE7-KM-01APR20-2/2

តទៅទំព័របន្ទាប់

OUO6075,0004DE7-KM-01APR20-3/2

ការសម្អាតគ្រឿងចក្រ (ការសម្អាតតាមពេលកំណត់)

រូបថតនៅក្នុងផ្នែកនេះ បង្ហាញតំបន់គ្រឿងចក្រដែលតម្រូវឲ្យត្រួតពិនិត្យយ៉ាងទៀងទាត់ និងសម្អាត។ នៅពេលមានផ្នែកផ្សេងដែលតម្រូវឲ្យសម្អាតយ៉ាងទៀងទាត់ ជារឿយៗយកចិត្តទុកលើតំបន់ទាំងនេះដែលផ្តល់ផលប៉ះពាល់ធំបំផុតអំពីការពារអគ្គីភ័យ។

រូបថតមួយចំនួនក្នុងចំណោមរូបថតទាំងនេះបង្ហាញការគណនាធាតុដំណាំ និងកម្ទេចកម្ទីផ្សេងៗទៀតមុនពេលសម្អាត។ ការគណនាប្រភេទនេះមិនធម្មតាទេ ប្រសិនបើត្រូវបានអនុញ្ញាតសម្រាប់តែគោលបំណងបង្ហាញប៉ុណ្ណោះ។

សំខាន់៖ តំបន់ទាំងនេះអាចតម្រូវឲ្យសម្អាតញឹកញាប់ សូម្បីតែច្រើនដងក្នុងមួយថ្ងៃក៏ដោយ ដោយអាស្រ័យលើស្ថានភាពច្រូតកាត់។ សូមយល់ដឹងពីស្ថានភាពច្រូតកាត់ និងកែតម្រូវកាលវិភាគសម្អាតរបស់អ្នក ដើម្បីប្រាកដថាមុខងារគ្រឿងចក្រដំណើរការត្រឹមត្រូវ និងដើម្បីកាត់បន្ថយពីហានិភ័យដោយអគ្គីភ័យ។

តំបន់ផ្សេងៗទៀតដែលមិនមាននៅក្នុងផ្នែកនេះក៏អាចប្រមូលកម្ទេចកម្ទីដំណាំបានផងដែរ ហើយត្រូវតែសម្អាតតាមពេលកំណត់ ដើម្បីមុខងារ និងរូបរាងគ្រឿងចក្រ។ ត្រួតពិនិត្យដោយយកចិត្តទុកដាក់ចំពោះគ្រឿងចក្រទាំងមូលតាមមូលដ្ឋានទៀងទាត់ពេញមួយរដូវច្រូតកាត់។

ត្រូវគោរពតាមនីតិវិធីសុវត្ថិភាពទាំងអស់ ដែលបានបិទនៅលើគ្រឿងចក្រ និងរៀបរាប់ក្នុងសៀវភៅណែនាំ។ មុនពេលធ្វើការត្រួតពិនិត្យ ឬសម្អាតគ្រឿងចក្រ ចូរពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ និងដោះសោចេញ។


សម្អាតគ្រឿងចក្រដោយយកចិត្តទុកដាក់ពីខាងលើដល់ខាងក្រោមដោយប្រើឧបករណ៍បិតខ្យល់។ មុនដំបូង សម្អាតតំបន់ទាំងអស់ដែលអាចលូកចូលបានពីឃ្លប់ម៉ាស៊ីន។ ចាប់ផ្តើមពីថតម៉ាស៊ីន និងធ្វើចេញទៅខាងក្រៅ ហើយច្រាសទ្រនិចនាឡិកាទៅតំបន់នៅជុំវិញថតម៉ាស៊ីន បាតខាងក្រោមម៉ាស៊ីន ផ្នែកខាងលើបំផុតនៃរ៉ូទ័រ និងបន្ទប់ខាងក្រោយ រួមមានតំបន់ជុំវិញឃ្លបប្រព្រឹត្តកម្មបញ្ចេញ (បើមាន)។ នៅពេលតំបន់ខាងលើរបស់គ្រឿងចក្រស្អាតហើយ បន្តសម្អាតតំបន់ដែលអាចចូលពីដី។


ពីតំបន់ដែលអាចចូលពីដីបាន សម្អាតខាងក្រោយនៅក្រោមតំបន់ធុងសាំង និងផ្នែកខាងលើខាងក្រោយកន្ទុយនៃប្រព័ន្ធបំផ្លាញសំណល់។ តំបន់ឃ្លបប្រព្រឹត្តកម្មបញ្ចេញ (បើមាន) ក៏នឹងត្រូវសម្អាតដែរពីដី។ នៅពេលសម្អាតពីតំបន់ដែលអាចចូលពីដីបានរួចរាល់ហើយ ពិនិត្យមើលបន្ទប់ម៉ាស៊ីនឡើងវិញក្រែងលោមានកម្ទេចកម្ទីកសិផល ដែលអាចហើរចូលពេលសម្អាតដែលចូលពីដីបាន។

កំណត់ចំណាំ៖ រថាំងមួយចំនួនត្រូវបានដោះចេញដើម្បីថតរូបច្បាស់។

បន្ទប់ម៉ាស៊ីន (តំបន់ខាងលើ)

OUO6075,0005121-KM-19MAY21-1/16






(1) — តំបន់ខាងលើម៉ាស៊ីន និងប្រដាប់សាកទែបូ

បន្ទប់ម៉ាស៊ីន (តំបន់ខាងលើ)


តទៅទំព័របន្ទាប់

OUO6075,0005121-KM-19MAY21-2/16



(2) — បំពង់បញ្ចេញប្រេងពីបំពង់ស៊ីមុាំង និងរបាំងបញ្ចេញប្រេង បំពង់អន្តរជំហានទែបូ បំពង់បញ្ចូលកម្តៅចលនាវិលរលំហ្គាសបំពង់ស៊ីមុាំង (EGR)

(3) — ជុំវិញម៉ាស៊ីន



បន្ទប់ម៉ាស៊ីន (តំបន់ខាងលើ)


OUO6075,0005121-KM-19MAY21-3/16



(4) — ខាងក្រោមម៉ាស៊ីន


(5) — ផ្នែកខាងលើខាងក្រោយរ៉ូទ័ឬ និងតំបន់ជុំវិញដ្រាយរ៉ូទ័រ


តទៅទំព័របន្ទាប់



បន្ទប់ម៉ាស៊ីន (តំបន់ខាងលើ)

OUO6075,0005121-KM-19MAY21-4/16







(6) — ប្រអប់ហ្គែរម៉ាស៊ីនមេ


(7) — តំបន់ជុំវិញ និងខាងក្រោមប្រព្រឹត្តកម្មបញ្ចេញ ឬ ប្រដាប់ខ្ទប់សំឡេង (បើមាន)

បន្ទប់ម៉ាស៊ីន (តំបន់ខាងលើ)



OUO6075,0005121-KM-19MAY21-5/16





(8) — នៅផ្នែកខាងលើធុងប្រេងឥន្ធនៈ


(9) — កញ្ចប់បញ្ជរកម្តៅម៉ាស៊ីន

ដែលអាចចូលពីដីបាន (តំបន់បាតក្រោម)

តទៅទំព័របន្ទាប់

OUO6075,0005121-KM-19MAY21-6/16





(1) — ខាងក្រោមធុងប្រេងឥន្ធនៈ

(2) — តំបន់នៅជុំវិញបាដាង និងរបាំងការពារបាដាង (ទីតាំងផ្សេងៗ)

OUO6075,0005121-KM-19MAY21-7/16

ដែលអាចចូលពីនីបាន (តំបន់បាតក្រោម)





មណ្ឌលហ្វ៊ីយស៊ីប (រចនាប័ទ្ម A)

សំខាន់៖ សញ្ញាដាក់ប្រេងបង្ហាញទីតាំងផ្សេងៗនៃចំណុចដាក់ខ្លាញ់ជុំវិញគ្រឿងចក្រ។ អនុវត្តពេលវេលាដាក់ប្រេងបានផ្តល់នៅលើសញ្ញា ហើយយោងតាមចន្លោះម៉ោងបានបញ្ជាក់នៅក្នុងផ្នែកការដាក់ប្រេង និងថែទាំ សម្រាប់ព័ត៌មានបន្ថែម។

ទម្រង់ងិលខូច ឬឡើងកម្តៅអាចបង្ករឲ្យមានអគ្គីភ័យ។ ដើម្បីកាត់បន្ថយការខូចបាដាង និងក្តៅខ្លាំង សូមយោងតាមសញ្ញាដាក់ប្រេងជានិច្ចនៅលើគ្រឿងចក្រ។

(3) — មណ្ឌលហ្វ៊ីយស៊ីប និងតំបន់ប្រអប់អាគុយ

(4) — សម្អាតជ្រាយឧបករណ៍លើកគ្រាប់ធញ្ញជាតិ


ដែលអាចចូលពីនីបាន (តំបន់បាតក្រោម)

តទៅទំព័របន្ទាប់

OUO6075,0005121-KM-19MAY21-8/16



(5) — តំបន់ដណ្តើរសេវាចំហៀងខាងស្តាំ



(6) — ផ្នែកខាងស្តាំរបាំងភក់

ដែលអាចចូលពីដីបាន (តំបន់បាតក្រោម)

OUO6075,0005121-KM-19MAY21-9/16



(7) — ផ្នែកខាងស្តាំរបាំងសំបកហ្វីដឺរ



(8) — ផ្នែកខាងឆ្វេងរបាំងសំបកហ្វីដឺរ

ដែលអាចចូលពីដីបាន (តំបន់បាតក្រោម)

OUO6075,0005121-KM-19MAY21-10/16



(9) — ប្រអប់លេខ





(10) — ដណ្តើរសេវា ចង្វាយខ្សែក្តឹង បន្ទះចំហៀង និងតំបន់គ្រឿងបំបែក

ដែលអាចចូលពីដីបាន (តំបន់បាតក្រោម)

តទៅទំព័របន្ទាប់

OUO6075,0005121-KM-19MAY21-11/16





មណ្ឌលហ្វ៊ីយស៊ីប *(រចនាប័ទ្ម B)*

(11) — មណ្ឌលហ្វ៊ីយស៊ីប និងតំបន់ប្រអប់អាគុយ

(12) —ដ្រាយឧបករណ៍សម្អាតការបញ្ចេញ

ដែលអាចចូលពីនីបាន (តំបន់បាតក្រោម)

OUO6075,0005121-KM-19MAY21-12/16


(13) — ផ្នែកខាងឆ្វេងតំបន់រ៉ូទ័រ


ដែលអាចចូលពីនីបាន (តំបន់បាតក្រោម)



តទៅទំព័របន្ទាប់

OUO6075,0005121-KM-19MAY21-13/16





(14) —ដ្រាយរ៉ូទ័រ


(15) — តំបន់បន្ទះចំហៀងខាងឆ្វេង

ដែលអាចចូលពីដីបាន (តំបន់ជាតក្រោម)

OUO6075,0005121-KM-19MAY21-14/16

(16) —ដ្រាយបំផ្លាញកាកសំណល់


ដែលអាចចូលពីដីបាន (តំបន់ជាតក្រោម)



តទៅទំព័របន្ទាប់

OUO6075,0005121-KM-19MAY21-15/16

(17) — តំបន់ជុំវិញ និងខាងក្រោមឃ្លុបប្រព្រឹត្តកម្មបញ្ចេញ (បើមាន)



OUO6075,0005121-KM-19MAY21-16/16

ការសម្អាតគ្រឿងចក្រ (ការសម្អាតប្រចាំឆ្នាំ និងដំណាំពិសេស)

OUO6075,0004D3C-KM-29JUN20-1/33

⚠ ប្រយ័ត្ន៖ ដើម្បីបង្ការការរងរបួស កុំសម្អាតគ្រឿងចក្រពេលម៉ាស៊ីនកំពុងដំណើរការ និងបានភ្ជាប់តម្រងចម្រោះ។ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។

ការណែនាំដូចខាងក្រោមត្រូវបានណែនាំ នៅពេលសម្អាតគ្រឿងចក្រសម្រាប់គ្រាប់កិសផលដែលបានបញ្ចាក់ ឬនៅពេលដឹកជញ្ជូនគ្រឿងចក្រឆ្លងរដ្ឋ។


⚠ ប្រយ័ត្ន៖ ដាក់កំណល់ឧបករណ៍ក្បាលកាត់សុវត្ថិភាពដូច្នេះវាមិនរំកិលទេ។ ប្រដាប់ការពារសុវត្ថិភាពកង់រកខាងក្រោម

1. ដោះក្បាលឧបករណ៍កាត់ចេញពីគ្រឿងចក្រ។
2. បើកបរគ្រឿងចក្រលើចុងដួរ ឬប៉ុម ដើម្បីឲ្យញ័រ និងក្រឡុកធូលីដែលធូរ។
3. ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។
4. បើក ឬដោះទ្វារចេញទាំងអស់ និងទុយោបង្ហូរ។

⚠ ប្រយ័ត្ន៖ សំឡេងស៊ីផ្លេ (A) ដើម្បីកុំឲ្យមនុស្សនៅជិត។ មិនត្រូវឲ្យមានមនុស្សនៅជិតគ្រឿងចក្រពេលបញ្ចេញសំរាម។

5. កាត់កុងតាក់សោ (B) ដើម្បីបញ្ឆោះម៉ាស៊ីន។
6. ភ្ជាប់គ្រឿងបំបែករហូតដល់ចំបើងឈប់ចេញពីខាងក្រោយគ្រឿងចក្រ។
7. បន្តយឈ្មើនជុំ/នាទីម៉ាស៊ីនមកឈ្មើនទាប ហើយភ្ជាប់គ្រឿង

តទៅទំព័របន្ទាប់



A—ស៊ីផ្លេ **B—កុងតាក់សោ**

បំបែកច្រើនដង។ ដំណើរការគ្រឿងបំបែកក្នុងឈ្មើនទាប ដើម្បីសម្អាតកម្ទេចកម្ទីចេញពីខាងក្នុងរ៉ូទ័រ។

⚠ ប្រយ័ត្ន៖ កុំឲ្យអ្នកឈរមើលនៅជិតគ្រឿងចក្រនៅពេលបញ្ចេញសំរាម។


8. ប្តូរហ្គែរទៅឈ្មើនជុំ/នាទីខ្ពស់ ហើយដំណើរការពីរ ឬបីនាទី។ បង្ហិលដដែលរហូតដល់សំរាមលែងចេញពីខាងក្រោយគ្រឿងចក្រ។

OUO6075,0004D3C-KM-29JUN20-2/33

⚠ ប្រយ័ត្ន៖ ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ ដាក់កំណល់កង់ និងបន្ទាបទំនប់សុវត្ថិភាពមាត់ច្រកបួងចូល។

នៅពេលធ្វើការជាមួយឧបករណ៍បាញ់ខ្យល់ក្នុងស្ថានភាពមានធូលីច្រើន អ្នកត្រូវតែពាក់វ៉ែនតា និងម៉ាស់ការពារធូលីសម្រាប់ជាការការពារផ្ទាល់ខ្លួន។

9. ចាប់ផ្តើមនៅផ្នែកខាងលើគ្រឿងចក្រ ហើយធ្វើការចុះក្រោម។




H39607—UN—11OCT88

OUO6075,0004D3C-KM-29JUN20-3/33


10. បើកទ្វារលូកសម្អាត (A—C) នៅផ្នែកខាងឆ្វេងគ្រឿងចក្រ។

A—ទ្វារលូកសម្អាត
B—ទ្វារលូកសម្អាត
C—ទ្វារលូកសម្អាត



H125413—UN—30NOV18

រចនាប័ទ្ម *A*



H125414—UN—30NOV18


រចនាប័ទ្ម *B*

តទៅទំព័របន្ទាប់

OUO6075,0004D3C-KM-29JUN20-4/33

11. បន្ទូរគន្លឹះ (A) និងបើកទ្វារលូកសម្អាត (B) គឺស្ថិតនៅចុងខាងស្តាំប្រដាប់បួងកាត់ធុងគ្រាប់ធញ្ញជាតិទាំងពីរ។
12. សម្អាតគ្រាប់ធញ្ញជាតិពីខាងក្រោមប្រដាប់បួងកាត់ធុងគ្រាប់ធញ្ញជាតិ។
13. សម្អាតគ្រាប់ធញ្ញជាតិពីតែមគម្របប្រអប់ប្រដាប់បួងទម្លាក់រហូតដល់ទៅដល់បាត។ ត្រូវតែសម្អាតគ្រាប់ធញ្ញជាតិចេញពីទ្វារពេលឈរនៅលើដី។

A—គន្លឹះ (ប្រើ 2) **B—ទ្វារលូកសម្អាត (ប្រើ 2)**



H125415—UN—30NOV18

OUO6075,0004D3C-KM-29JUN20-5/33


14. ចូរសម្អាតប្រដាប់បួងផ្តុំកធុងគ្រាប់ធញ្ញជាតិ ដោយផ្អែកលើដម្រើសគ្រឿងចក្រ។

ប្រដាប់បួងផ្តុំកធុងគ្រាប់ធញ្ញជាតិ (ពង្រីកធុងគ្រាប់ធញ្ញជាតិ)

1. លែងតង្កៀប (A) ហើយបន្ទាបប្រដាប់បួង។
2. សម្អាតតំបន់ខាងលើ ហើយចុះក្រោមទៅដល់ប្រដាប់យោងគ្រាប់ធញ្ញជាតិស្អាតទៅដល់ច្រវាក់ប្រដាប់យោងគ្រាប់ធញ្ញជាតិស្អាត។ សម្អាតគ្រាប់ផ្អែក។

ប្រដាប់បួងផ្តុំកធុងគ្រាប់ធញ្ញជាតិ (គម្របធុងគ្រាប់ធញ្ញជាតិ)

A—ក្រចាប់រឹត



H123557—UN—21FEB18

តទៅទំព័របន្ទាប់


OUO6075,0004D3C-KM-29JUN20-6/33

ប្រយ័ត្ន៖ កុំទាញ ឬដោះកន្លាស់ចេញ (A) ដើម្បីបន្ទាបប្រដាប់បួងផ្តុំកធុងគ្រាប់ធញ្ញជាតិ។ ការដោះកន្លាស់ចេញអាចបង្ករឲ្យរងបួស ឬខូចគ្រឿងចក្រ។

ប្រដាប់បួងផ្តុំកធុងគ្រាប់ធញ្ញជាតិគឺធ្ងន់។ ប្រើដោយយកចិត្តទុកដាក់បន្ថែមនៅពេលលើក ឬដាក់ប្រដាប់បួង។

1. ដោះកន្លាស់ចាក់សោរហ័ស (B) និងកន្លាស់ (C) ពីក្បាលរីង (D) ។
2. ប្រើដង (E) ដើម្បីជួយដាក់ប្រដាប់បួងផ្តុំកធុងគ្រាប់ធញ្ញជាតិ (F) ។
3. សម្អាតតំបន់ខាងលើ ហើយចុះក្រោមទៅដល់ប្រដាប់យោងគ្រាប់ធញ្ញជាតិស្អាតទៅដល់ច្រវាក់ប្រដាប់យោងគ្រាប់ធញ្ញជាតិស្អាត។ សម្អាតគ្រប់ផ្នែក។

A—កន្លាស់ស៊ក
B—កន្លាស់ស៊កចាក់ខ្ទាស់រហ័ស
C—កន្លាស់ស៊ក
D—តម្កក់មួលរីត
E—ដង
F—ប្រដាប់បួង




H123561—UN—21FEB18

OUO6075,0004D3C-KM-29JUN20-7/33

15. បន្ធូរតង្កៀប (A) ហើយយោលរីនដូធុងគ្រាប់ធញ្ញជាតិ (B) ឡើងលើ។
16. សម្អាតតំបន់ខាងក្រោយកាប៊ីន ជុំវិញឡាបមេ និងលើតម្រងចម្រោះ។

A—ក្រចាប់រឹត (ប្រើ 2)
B—បង្អួចគ្រាប់ធញ្ញជាតិ




H76204—UN—28APR03

OUO6075,0004D3C-KM-29JUN20-8/33

17. ដោះទ្វារច្រកចូល (A) (បើមាន) នៅខាងមុខធុងគ្រាប់ធញ្ញជាតិ។
18. សម្អាតសម្ភារៈនៅជុំវិញប្រអប់ស្តីអូសមាត់ច្រកបួងចូលពហុល្បឿន (បើមាន) ។

A—ទ្វារច្រកលូកចូល




H113138—UN—06MAR15

តទៅទំព័របន្ទាប់

OUO6075,0004D3C-KM-29JUN20-9/33

19. ទាញកន្ទាស់ចាក់សោ (A) ហើយបង្វិលបង្ហាន់ដៃជណ្តើរ (B) ឡើងលើរហូតដល់សោបង្ហាន់ដៃជណ្តើរត្រូវកន្លែង។
20. បើកគម្របចូលម៉ាស៊ីន (C) ហើយសម្អាតផ្នែកខាងលើតំបន់បន្ទប់ម៉ាស៊ីន និងជុំវិញតម្រងចម្រោះ (នៅផ្នែកខាងមុខម៉ាស៊ីន)។
21. សម្អាតតំបន់បន្ទប់ម៉ាស៊ីនទាំងមូល ជាពិសេសក្រោមម៉ាស៊ីន។
22. ជូតសម្អាតប្រេង ឬខ្លាញ់ដែលមាននៅលើតំបន់ម៉ាស៊ីន។

A—កន្ទាស់ចាក់ខ្ទាស់
B—បង្ហាន់ដៃ
C—គម្របទ្វារម៉ាស៊ីន




H118329—UN—04MAY16

OUO6075,0004D3C-KM-29JUN20-10/33

23. ទាញកន្ទាស់ចាក់សោ (A) ហើយបង្វិលជណ្តើរ (B) ឡើងលើរហូតដល់ការចាក់សោជណ្តើរត្រូវកន្លែង។
24. ទាញគម្របចូលតម្រង (C) បើក ដើម្បីលែងពីមេដែក។
25. សម្អាតផ្នែកខាងក្រោយតំបន់បន្ទប់ម៉ាស៊ីន។
26. សម្អាតតំបន់បន្ទប់ម៉ាស៊ីនទាំងមូល ជាពិសេសក្រោមម៉ាស៊ីន។
27. ជូតសម្អាតប្រេង ឬខ្លាញ់ដែលមាននៅលើតំបន់ម៉ាស៊ីន។

A—កន្ទាស់ចាក់ខ្ទាស់
B—ជណ្តើរ
C—គម្រប



H95353—UN—25AUG10

OUO6075,0004D3C-KM-29JUN20-11/33

28. សម្អាតតំបន់ធុងទឹកគ្រឿងចក្រនិងតំបន់ផ្សេងៗទៀតដោយអាស្រ័យលើជម្រើសគ្រឿងចក្រ។


ចំណាត់ថ្នាក់ 2/ដំណាក់កាល II (បែប A)

កំណត់ចំណាំ៖ សម្អាតបរិវេណមានខ្យល់ពេញ ផ្លុំខ្យល់ចេញពីក្នុងទៅក្រៅ។

1. បើកទ្វារអេក្រង់វិល។
2. សម្អាតតំបន់ដូចខាងក្រោមពីខាងក្នុងចេញក្រៅ។
   - រ៉ាឌីយ៉ាទ័រ (A)
   - កុងដង់សាទ័រ
   - ឧបករណ៍បញ្ចោះកម្តៅប្រេង
   - សាកឧបករណ៍បញ្ចោះកម្តៅខ្យល់
3. សម្អាតធូលីចេញពីបំពង់បូមផ្នែកខាងក្រោម (B) និងបំពង់ផ្សេរ (C) ។

ចំណាត់ថ្នាក់ 2/ដំណាក់កាល II (រចនាប័ទ្ម B) និង
ចំណាត់ថ្នាក់ចុងក្រោយ 4/ដំណាក់កាល V


A—ធុងទឹកម៉ាស៊ីន
B—បំពង់បូម
C—បំពង់ផ្សេរ



H106852—UN—08FEB13


តទៅទំព័របន្ទាប់

OUO6075,0004D3C-KM-29JUN20-12/33



H106853—UN—08FEB13

A—កន្លាស់ចាក់ខ្ចាស់
B—គ្រឿងបន្ថយកម្តៅប្រេងឥន្ធនៈ
C—ធុងទឹកម៉ាស៊ីន
D—បំពង់បូម



H106854—UN—08FEB13

E—កុងដង់សាទ័រ
F—ទ្វារសំណាញ់វិល
G—បំពង់ផ្ទេរ

កំណត់ចំណាំ៖ សម្អាតបរិវេណមានខ្យល់ពេញ ផ្លុំខ្យល់ចេញពីក្នុងទៅក្រៅ។


1. បើកទ្វារអេក្រង់វិល។
2. ទាញកន្លាស់ចាក់សោ (A) ហើយបង្វិលឧបករណ៍បញ្ចោះកម្តៅប្រេងឥន្ធនៈ (B) ដើម្បីសម្អាត។
3. សម្អាតតំបន់ដូចខាងក្រោមពីខាងក្នុងចេញក្រៅ។
   - វ៉ាឌីយ៉ាទ័រ (C)
   - ឧបករណ៍បញ្ចោះកម្តៅប្រេង
   - សាកឧបករណ៍បញ្ចោះកម្តៅខ្យល់
4. សម្អាតធូលីពីបំពង់បូមផ្នែកខាងក្រោម (D) ។
5. សម្អាតកង់ដង់សាទ័រ (E) នៅលើទ្វេរអេក្រង់វិល (F) ។
6. សម្អាតធូលីពីបំពង់ផ្ទេរ (G) ។

OUO6075,0004D3C-KM-29JUN20-13/33

29. ដោយអាស្រ័យលើជម្រើសគ្រឿងចក្រ, ចូរសម្អាតតំបន់ប្រដាប់យោងគ្រាប់ធញ្ញជាតិស្អាតនិងតំបន់ប្រដាប់យោងកាកសំណល់។

សម្អាតប្រដាប់យោងគ្រាប់ធញ្ញជាតិ និងប្រដាប់យោងកាកសំណល់ (រចនាប័ទ្ម A)


1. បើកទ្វារប្រដាប់យោងកាកសំណល់ខាងក្រោម (A) ហើយសម្អាតទ្វារប្រដាប់យោងគ្រាប់ធញ្ញជាតិ (B)។
2. ដោះឡោស៊ីមានស្លាប (C) ហើយដោះទ្វារនៅចុងខាងលើនៃប្រដាប់យោងកាកសំណល់។
3. ដោះសម្ភារៈតាមការចាំបាច់ ហើយសម្អាតផ្នែកនៃឧបករណ៍លើក។



H62232—UN—19JAN00

សម្អាតប្រដាប់យោងគ្រាប់ធញ្ញជាតិ និងប្រដាប់យោងកាកសំណល់ (រចនាប័ទ្ម B)

A—ទ្វារប្រដាប់យោងគ្រាប់ធញ្ញជាតិ
B—សម្អាតទ្វារប្រដាប់យោងគ្រាប់ធញ្ញជាតិ
C—ឡោស៊ីស្លាប




H62233—UN—19JAN00

តទៅទំព័របន្ទាប់

OUO6075,0004D3C-KM-29JUN20-14/33

1. ប្រើដង (A) ដើម្បីបើកទ្វារសម្អាតប្រដាប់យោងគ្រាប់ធញ្ញជាតិ (B) និងទ្វារប្រដាប់យោងកាកសំណល់ (C) ។
2. ដោះសម្ភារៈតាមការចាំបាច់ ហើយសម្អាតផ្នែកនៃឧបករណ៍លើក។

A—ដង
B—សម្អាតទ្វារប្រដាប់យោងគ្រាប់ធញ្ញជាតិ
C—ទ្វារឧបករណ៍លើកប្រព័ន្ធកាកសំណល់




H97193—UN—30JUN10

OUO6075,0004D3C-KM-29JUN20-15/33

3. ប្រើដង (A) ដើម្បីបើកទ្វារប្រដាប់បួងប្រព័ន្ធកន្ទុយ (B) ។
4. ដោះសម្ភារៈតាមការចាំបាច់ ហើយសម្អាតផ្នែកនៃឧបករណ៍លើក។


A—ដង
B—ទ្វារប្រដាប់បួងប្រព័ន្ធកាកសំណល់



H97194—UN—30JUN10

OUO6075,0004D3C-KM-29JUN20-16/33

30. សម្អាតសំរាមនៅចន្លោះតម្រងចម្រោះ និងផ្នែកចំហៀងនៃគ្រឿងចក្រ។




H100541—UN—02MAR11

តទៅទំព័របន្ទាប់


OUO6075,0004D3C-KM-29JUN20-17/33

31. បន្ទរឡោស៊ុ (A) នៅចំហៀងទ្វារសំបកហ្វីឌីរនីមួយៗ ហើយរុញឡោស៊ុទៅមុខកណ្តាលសំបកហ្វីឌីរ។
32. ទាញទ្វារថយក្រោយ ដើម្បីដោះចេញ។
33. សម្អាតសំបកហ្វីឌីរកាត់តាមទ្វារផ្នែកខាងលើ (B) និង (C)។
34. លើកច្រវាក់រណេល ហើយឲ្យច្រវាក់ខ្ជាស់ថយក្រោយច្រើនដងពេលសម្អាត។

A—ក្បាលឡោស៊ុ
B—ទ្វារមាត់ច្រកបួងចូល
C—ទ្វារមាត់ច្រកបួងចូល



H100486—UN—28FEB11



H90905—UN—27FEB08

OUO6075,0004D3C-KM-29JUN20-18/33


35. អាស្រ័យលើជម្រើសគ្រឿងចក្រ ចូរសម្អាតតំបន់បន្ទះច្រកបញ្ចូល។

បន្ទះច្រកបញ្ចូល (បែប A)

1. ដោះកន្លាស់ចាក់សោរហ័ស ហើយរំកិលចង្កឹះ (A) ចុះក្រោម និងថយក្រោយ ដើម្បីបើកបន្ទះហ្វីដ។
2. សម្អាតតំបន់បន្ទះហ្វីដ។
3. រុញចង្កឹះទៅមុខ ហើយឡើងលើ ដើម្បីបិទបន្ទះហ្វីដ។ រឹតជាមួយកន្លាស់ចាក់សោរហ័សដែលបានដោះចេញពីមុន។

បន្ទះច្រកបញ្ចូល (បែប B)

A—ដៃបញ្ជា




H52761—UN—17MAY99

តទៅទំព័របន្ទាប់

OUO6075,0004D3C-KM-29JUN20-19/33

1. ដោះឡោស៊ី (A) និងប៊ូឡុងក្បាលមូល (B) នៅលើផ្នែកទាំងសងខាងរបស់គ្រឿងចក្រ។
2. ដោះកន្ត្រាស់ចាក់សោរហ័ស (C) ហើយរំកិលចង្កឹះ (D) ចុះក្រោម និងថយក្រោយ ដើម្បីបើកបន្ទះហ្វីដ។
3. សម្អាតតំបន់បន្ទះហ្វីដ។
4. រុញចង្កឹះទៅមុខ ហើយឡើងលើ ដើម្បីបិទបន្ទះហ្វីដ។ រឹតជាមួយកន្ត្រាស់ចាក់សោរហ័សដែលបានដោះចេញពីមុន។
5. ដាក់ប៊ូឡុងក្បាលមូល (B) និងឡោស៊ី (A) ដែលបានដោះចេញកន្លងមកនៅចំហៀងសងខាងគ្រឿងចក្រ។

A—ក្បាលឡោស៊ី
B—ប៊ូឡុងក្បាលមូល
C—កន្ត្រាស់ស៊ីកចាក់ខ្ទាស់រហ័ស
D—ដែបញ្ជា




H120113—UN—29NOV16

OUO6075,0004D3C-KM-29JUN20-20/33

36. ដោះកន្ត្រាស់ចាក់សោរហ័ស (A) ហើយរំកិលចង្កឹះ (B) ឡើងលើ ដើម្បីបើកតម្រងតម្រោះថ្ម។
37. សម្អាតតំបន់តម្រងចម្រោះថ្ម។
38. រំកិលចង្កឹះចុះក្រោម ដើម្បីបិទតម្រងចម្រោះថ្ម។ ខ្ទាស់ជាមួយកន្ត្រាស់ចាក់សោរហ័ស។

A—កន្ត្រាស់ស៊ីកចាក់ខ្ទាស់រហ័ស
B—ដែបញ្ជា



H99239—UN—01DEC10

OUO6075,0004D3C-KM-29JUN20-21/33


39. អាស្រ័យលើជម្រើសគ្រឿងចក្រ ចូរសម្អាតតំបន់ស្តីហ្គែរប្រដាប់បួងស្បែកជើងសម្អាត។

ស្តីប្រដាប់បួងស្បែកជើងសម្អាត (រចនាបថ A)

1. ដើម្បីសម្អាតតំបន់នេះ ចូរដោះប៊ូឡុងចេញពីទ្វារលូកសម្អាត (A)។
2. ដាក់ទ្វារសម្អាត និងប៊ូឡុងនៅពេលសម្អាតហើយ។

ស្តីប្រដាប់បួងស្បែកជើងសម្អាត (រចនាបថ B)

A—ទ្វារលូកសម្អាត




H102538—UN—29JUN11

តទៅទំព័របន្ទាប់

OUO6075,0004D3C-KM-29JUN20-22/33

1. ទាញកន្លាស់ស៊ីកចាក់សោ (A) និងរំកិលដង (B) ឡើងលើ ដើម្បីចាក់ទ្វារលូកសម្អាត (C)។
2. រុញដងចុះក្រោមដើម្បីបិទនិងចាក់សោទ្វារសម្អាត។

A—កន្លាស់ចាក់ខ្ជាស់
B—ដង
C—ទ្វារលូកសម្អាត




H91139—UN—15APR08

OUO6075,0004D3C-KM-29JUN20-23/33


40. ដោះកន្លាស់ចាក់សោរហ័ស (A) និងគម្របត្រួតពិនិត្យ (B) ចេញ។ ប្រើប្រដាប់កៀរដើម្បីបន្ធូរសម្ពារៈ និងសម្អាតកាត់ផ្នែកនៃគ្រឿងចក្រ។

A—កន្លាស់ស៊ីកចាក់ខ្ជាស់រហ័ស
B—គម្របត្រួតពិនិត្យ




H111240—UN—13MAY14

គម្របត្រួតពិនិត្យ *(រចនាប័ទ្ម A)*



H111241—UN—13MAY14

គម្របត្រួតពិនិត្យ *(រចនាប័ទ្ម B)*




H52708—UN—23MAR99

តទៅទំព័របន្ទាប់

OUO6075,0004D3C-KM-29JUN20-24/33

41. សម្អាតផ្នែកខាងលើនៃស្តៅ និងប្រអប់លេខ។




H99165—UN—22NOV10

គ្រឿងចក្រប្លូរដោយប្រើការរុញប៊ូតុងដូចបានបង្ហាញ

OUO6075,0004D3C-KM-29JUN20-25/33

42. បើកន្ត្រង និងឧបករណ៍ជោសសំរាមឲ្យបានឆ្ងាយតាមដែលអាចធ្វើបាន ហើយសម្អាតវា។



H115550—UN—20AUG15

OUO6075,0004D3C-KM-29JUN20-26/33

43. សម្អាតតំបន់ស្តៅខាងក្រោយ។




H115551—UN—20AUG15

តទៅទំព័របន្ទាប់

OUO6075,0004D3C-KM-29JUN20-27/33

44. ដោះកន្លាស់ចាក់សោរហ័ស (A) ហើយបើករបាំង (B) ។
45. ដោះកន្លាស់ចាក់សោរហ័ស (C) ហើយបង្វិលក្បាលគន្លឹះ (D) ដើម្បីដោះសោ។
46. លើក និងដោះរបាំងខាងក្រោយ (B) និងរបាំងកង្ហារកណ្តាល (E)ចេញ ។
47. សម្អាតតំបន់កង្ហារ។

A—កន្លាស់ស៊កចាក់ខ្ចាស់រហ័ស
B—របាំងការពារ
C—កន្លាស់ស៊កចាក់ខ្ចាស់រហ័ស
D—គន្លឹះ
E—របាំងការពារ




H96806—UN—09JUN10

OUO6075,0004D3C-KM-29JUN20-28/33

48. ដោះកន្លាស់ចាក់សោរហ័ស (A) ហើយបង្វិលក្បាលគន្លឹះ (B) ដើម្បីដោះរបាំង(C) ចេញ។
49. តំបន់សម្អាត។


A—កន្លាស់ស៊កចាក់ខ្ចាស់រហ័ស
B—គន្លឹះ
C—របាំងការពារ



H96803—UN—09JUN10

OUO6075,0004D3C-KM-29JUN20-29/33

50. តំបន់សម្អាតជុំវិញកង្ហារ




H123359—UN—08FEB18

តទៅទំព័របន្ទាប់

OUO6075,0004D3C-KM-29JUN20-30/33

51. លើកប្រដាប់ចិញ្ច្រាំឡើងលើ (បើមាន) ដោយចុចកុងតាក់ (A) ។


A—កុងតាក់



OUO6075,0004D3C-KM-29JUN20-31/33

52. ការលៃតម្រូវអាងកាំបិតដោយដៃ៖ បន្ធូរឡោស៊ីស្លាប (A) ហើយប្រើដង(B) ដើម្បីផ្គាច់អាងកាំបិត និងសម្អាតប្រដាប់ចិញ្ច្រាំ។


A—ឡោស៊ីស្លាប **B—ដង**



OUO6075,0004D3C-KM-29JUN20-32/33

53. សម្អាតកម្ទេចកម្ទីចំបើងចេញពីតំបន់អូសប្រដាប់ពង្រាយ (បើមាន)និងគម្របប្រដាប់ពង្រាយ។

54. ដំឡើងរបាំងទាំងអស់ដែលបានដោះចេញកន្លងមក រួចហើយបិទទ្វារទាំងអស់មុននឹងប្រតិបត្តិការគ្រឿងចក្រ។



OUO6075,0004D3C-KM-29JUN20-33/33

គ្រប់គ្រងចាត់ចែងប្រេងដោយសុវត្ថិភាព—ជៀសវាងអគ្គីភ័យ

DX,FIRE1-KM-12OCT11-1/2

ចាត់ចែងប្រេងឥន្ធនៈដោយយកចិត្តទុកដាក់៖ វាងាយឆាបឆេះយ៉ាងខ្លាំង។ កុំចាក់ប្រេងគ្រឿងចក្រខណៈពេលកំពុងជក់បារី ឬពេលស្ថិតនៅជិតអណ្តាតភ្លើង ឬផ្កាភ្លើង។

ជានិច្ចកាល ត្រូវពន្លត់ម៉ាស៊ីនមុនពេលចាក់ប្រេងគ្រឿងចក្រ។ ចាក់បំពេញធុងប្រេងនៅខាងក្រៅអគារ។

បង្ការអគ្គីភ័យដោយរក្សាកុំឲ្យម៉ាស៊ីនមានបណ្តុំសំរាម ខ្លាញ់ និងកំទេចសឹក។ ត្រូវជូតសម្អាតប្រេងដែលហៀរកំពប់ជានិច្ច។

ប្រើប្រាស់តែធុងប្រេងណា ដែលមានការអនុញ្ញាតសម្រាប់ការដឹកជញ្ជូនជាតុរាវដែលអាចឆាបឆេះបានប៉ុណ្ណោះ។

មិនត្រូវចាក់ប្រេងបំពេញធុង នៅក្នុងទ្រុងក្រោយរបស់រថយន្តភិកអាប់ (pickup truck) ដែលមានទ្រនាប់បាតជាជ័រផ្លាស្ទិកឡើយ។ ត្រូវដាក់ធុងប្រេងនៅលើដី មុននឹងចាក់ប្រេង គ្រប់ពេលដែលត្រូវចាក់ប្រេងដាក់ធុង ។ មុនពេលបើកគម្របធុងដើម្បីចាក់ប្រេង ត្រូវដាក់ក្បាលទុយោបាញ់បញ្ចូលប្រេងអោយប៉ះធុងប្រេង ជាមុនសិន។ រក្សាអោយក្បាលទុយោបាញ់បញ្ចូលប្រេងប៉ះ ជាមួយនឹងមាត់ធុងប្រេងនៅពេលចាក់ប្រេង។



TS202—UN—23AUG88

កុំទុកដាក់ធុងប្រេងនៅកន្លែងណាដែលមាន អណ្តាតភ្លើង ផ្កាភ្លើង ឬភ្លើងសម្រាប់បញ្ឆេះ ដូចជានៅក្នុងឧបករណ៍ដាំទឹកក្តៅ ឬឧបករណ៍ផ្សេងៗទៀត។

DX,FIRE1-KM-12OCT11-2/2

ជៀសវាងហានិភ័យអគ្គិសនីស្ថាទិចនៅពេលចាក់ប្រេងឥន្ធនៈ

DX,FUEL,STATIC,ELEC-KM-12JUL13-1/2

ការដកចេញជាតិស្ពាន់ធ័រ និងសមាសធាតុផ្សេងៗនៅក្នុងប្រេងម៉ាស៊ូតដែលមានជាតិស្ពាន់ធ័រទាបខ្លាំង (ULSD) កាត់បន្ថយសមត្ថភាពចម្លងកំដៅរបស់វា ហើយបានបង្កើនសមត្ថភាពក្នុងការរក្សាទុកបន្ទុកស្ថាទិច។


ការចម្រាញ់ប្រេង អាចមានបញ្ហូលការធ្វើប្រព្រឹត្តកម្ម ឥន្ធនៈជាមួយធាតុបន្ថែមដើម្បីបន្ថយបន្ទុកស្ថាទិច។ ទោះជាយ៉ាងណា មានកត្តាជាច្រើនដែលអាចកាត់បន្ថយប្រសិទ្ធភាពនៃធាតុបន្ថែម ក្នុងរយៈពេលរក្សាទុកប្រេង។

បន្ទុកស្ថាទិច អាចកើនឡើងនៅក្នុងប្រេង ULSD ខណៈពេលវាហូរកាត់តាមប្រព័ន្ធចែកចាយប្រេង។ បន្ទើរនៃអគ្គិសនីស្ថាទិច នៅពេលមានវត្តមានចំហាយប្រេងដែលងាយឆេះ អាចបណ្តាលឲ្យមានអគ្គីភ័យ ឬការផ្ទុះ។

ដូច្នេះ វាជាការសំខាន់ដែលត្រូវធ្វើឲ្យប្រាកដថា ប្រព័ន្ធទាំងមូលសម្រាប់ប្រើប្រាស់ក្នុងការចាក់បំពេញប្រេងគ្រាក់ទ័ររបស់អ្នក (ធុងប្រេង ឧបករណ៍បូមប្រេង ទុយោប្រេង ក្បាលទុយោ និងឧបករណ៍ផ្សេងៗទៀត) ត្រូវបានភ្ជាប់ខ្សែដី និងប៉ះជាប់គ្នាទាំងអស់ ឲ្យបានត្រឹមត្រូវ។ សូមប្រឹក្សាជាមួយអ្នកផ្គត់ផ្គង់ប្រេងឥន្ធនៈ ឬអ្នកផ្គត់ផ្គង់ប្រព័ន្ធចាក់ប្រេងរបស់អ្នក ដើម្បីប្រាកដថាប្រព័ន្ធចាក់ប្រេងរបស់អ្នក ត្រឹមត្រូវតាមបទដ្ឋាននានានៃការចាក់ប្រេង ហើយការភ្ជាប់ម៉ាស់ដី និងការប៉ះជាប់គ្នា គឺអនុវត្តន៍បានត្រឹមត្រូវ។



RG22142—UN—17MAR14



RG21992—UN—21AUG13

DX,FUEL,STATIC,ELEC-KM-12JUL13-2/2


ធុងប្រេងឥន្ធនៈ—ការថែទាំ

OUO6075,0004E1B-KM-30APR20-1/2

⚠ ប្រយ័ត្ន៖ គ្រប់គ្រង និងចាត់ចែងប្រេងឥន្ធនៈដោយប្រុងប្រយ័ត្ន។ ហាមជក់បារី នៅពេលចាក់ប្រេងចូលគ្រឿងចក្រ។ ចូរពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ មុនពេលចាក់ប្រេងឥន្ធនៈចូលធុង។


ចូរកុំចាក់ឲ្យពេញហៀរ។ អាចរងរបួសរាងកាយដោយសារតែប្រេងខ្ចាតចេញ។ អាចមានការលេចជ្រាបដោយសារតែការកំពប់ប្រេងឥន្ធនៈ ប្រសិនបើធុងប្រេងឥន្ធនៈពេញពេក ពេលនោះដោយសារទុកចោលក្រោមពន្លឺថ្ងៃ ឬប្រសិនបើស៊ីតុណ្ហភាពក្តៅពេក ប្រេងនឹងហៀរចេញពីធុង។

សំខាន់៖ ម៉ាស៊ីនចំណាត់ថ្នាក់ចុងក្រោយទី 4/ដំណាក់កាលទី V៖ ចូរប្រើតែប្រេងម៉ាស៊ូតដែលមានជាតិស្ពាន់ធ័រទាបបំផុត ប៉ុណ្ណោះ។ ដើម្បីជ្រាបនូវព័ត៌មានបន្ថែម ចូរអានអំពីប្រេងម៉ាស៊ូត និងប្រេងជីវៈម៉ាស៊ូតនៅក្នុងផ្នែកនេះ។



H125474—UN—10DEC18

គម្របធុងឥន្ធនៈ: (មិនអាចចាក់ខ្ជាស់បាន)



H130126—UN—30APR20

គម្របធុងឥន្ធនៈ: (ចាក់ខ្ជាស់បាន)

ចាក់បំពេញធុងប្រេង (A) នៅពេលចប់ប្រតិបត្តិការក្នុងថ្ងៃនីមួយៗ។ វាការពារកំណនៅក្នុងធុងប្រេងដូចជាខ្យល់សើមជាដើម។

A—ធុងប្រេងឥន្ធនៈ

OUO6075,0004E1B-KM-30APR20-2/2

ការប្រើប្រាស់ និងរក្សាទុកប្រេងម៉ាស៊ូត

⚠ ប្រយ័ត្ន៖ កាត់បន្ថយហានិភ័យអគ្គិភ័យ។ គ្រប់គ្រង និងចាត់ចែងប្រេងឥន្ធនៈដោយប្រុងប្រយ័ត្ន។ កុំចាក់បំពេញធុងប្រេងនៅពេលម៉ាស៊ីនកំពុងដំណើរការ។ កុំជក់បារីនៅពេលអ្នកចាក់បំពេញធុងប្រេង ឬផ្តល់សេវាជួសជុលប្រព័ន្ធប្រេង។

ចាក់បំពេញធុងប្រេងនៅពេលចប់បើកបរក្នុងថ្ងៃនីមួយៗ ដើម្បីបង្ការកុំឲ្យមានញើស ឬកកជាដំណក់ទឹកនៅអំឡុងពេលអាកាសធាតុត្រជាក់។

រក្សាឲ្យធុងស្តុកទាំងអស់ពេញតាមដែលអាចធ្វើទៅបាន ដើម្បីកាត់បន្ថយការកកជាញើស។

ធានាថា គម្រប និងរបាំងធុងប្រេងទាំងអស់ត្រូវបានដំឡើងត្រឹមត្រូវដើម្បីបង្ការកុំឲ្យសំណើមចូល។ ត្រួតពិនិត្យចំណុះទឹកនៃប្រេងឥន្ធនៈឲ្យបានទៀងទាត់។

នៅពេលប្រើជីវៈម៉ាស៊ូត គម្រងប្រេងអាចត្រូវការផ្លាស់ប្តូរឲ្យបានញឹកញាប់ជាងមុនដោយសារវាឆាប់ខូចមុនអាយុកាល។

ត្រួតពិនិត្យកម្រិតប្រេងម៉ាស៊ីនប្រចាំថ្ងៃ មុនពេលបញ្ឆេះម៉ាស៊ីន។ កម្រិតប្រេងដែលឡើង អាចបង្ហាញនូវកម្រិតឌីលុយស្បូងឥន្ធនៈនៃប្រេងម៉ាស៊ីន។

នៅពេលរក្សាទុកប្រេងឥន្ធនៈក្នុងរយៈពេលយូរ ឬប្រសិនបើមានការផ្លាស់ប្តូរយឺតយ៉ាវនៃប្រេងឥន្ធនៈ សូមបន្ថែមជាតុសម្រួលប្រេងឥន្ធនៈដើម្បីរក្សាស្ថេរភាពប្រេងឥន្ធនៈ និងបង្ការកំណកញើស។ សូមទាក់ទងអ្នកផ្គត់ផ្គង់ប្រេងឥន្ធនៈ ឬភ្នាក់ងារចែកចាយ John Deere របស់អ្នកដើម្បីសុំការណែនាំ។

OUO6075,000163E-KM-06SEP13-1/1

ប្រេងម៉ាស៊ូត

ប្រឹក្សាជាមួយភ្នាក់ងារចែកចាយប្រេងឥន្ធនៈក្នុងស្រុករបស់អ្នក សម្រាប់លក្ខណៈសម្បត្តិនៃប្រេងម៉ាស៊ូតដែលអាចរកបាននៅក្នុងតំបន់របស់អ្នក។

ជាទូទៅ ប្រេងម៉ាស៊ូតត្រូវបានលាយដើម្បីបំពេញតាមតម្រូវការសីតុណ្ហភាពទាបនៃតំបន់ភូមិសាស្ត្រដែលត្រូវដាក់លក់។

គួរប្រើប្រេងម៉ាស៊ូតដែលមានលក្ខណៈបច្ចេកទេស EN 590 ឬ ASTM D975។ ប្រេងម៉ាស៊ូតដែលអាចបង្កើតឡើងវិញ ដែលផលិតឡើងដោយការធ្វើប្រព្រឹត្តកម្មបន្សុទ្ធខ្លាញ់សត្វ ហើយប្រេងឆាមានលក្ខណៈដូចគ្នាបេះបិទទៅនឹងប្រេងឥន្ធនៈម៉ាស៊ូត។ ប្រេងម៉ាស៊ូតដែលអាចបង្កើតឡើងវិញបាន ដែលបំពេញតាមតម្រូវការ EN 590, ASTM D975 ឬ EN 15940 សុទ្ធតែអាចទទួលយកបានសម្រាប់ការប្រើប្រាស់នៅកម្រិតល្បាយភាគរយទាំងអស់។

លក្ខណៈសម្បត្តិប្រេងឥន្ធនៈដែលត្រូវការ

គ្រប់ករណីទាំងអស់ ប្រេងឥន្ធនៈត្រូវមានគុណភាពដូចតទៅៈ

ចំនួនសេតានអប្បបរមា 40 ។ ចំនួនសេតានដែលធំជាង 47 រឺតែល្អថែមទៀត ជាពិសេសសម្រាប់សីតុណ្ហភាពក្រោម –20 °C (–4 °F) ឬកម្ពស់លើសពី 1675 ម (5500 ហ្វីត)។

ចំណុចពពក គួរតែនៅក្រោមសីតុណ្ហភាពជុំវិញទាបបំផុតដែលរំពឹងទុកឬ **ចំណុចស្ទះតម្រងត្រជាក់** (CFPP) គួរតែមានអតិបរមា 10 អង្សាសេ (18 ° F) ខាងក្រោមចំណុចពពកឥន្ធនៈ។

ភាពរំអិលនៃប្រេងឥន្ធនៈ: គួរឆ្លងផុតអង្គត់ផ្ចិតសម្លាកអតិបរមា .52 មម តាមការវាស់វែងដោយ ASTM D6079 ឬ ISO 12156-1។ យកល្អគួរប្រើអង្គត់ផ្ចិតសម្លាកអតិបរមា .45 មម។

គុណភាព និងចំណុះ: ស្ពាន់ធ័ររបស់ប្រេងម៉ាស៊ូត ត្រូវតែអនុលោមតាមបទបញ្ជាត្រួបំភាយឧស្ម័នជាធរមានសម្រាប់តំបន់ដែលម៉ាស៊ីនដំណើរការ។ កុំប្រើប្រេងម៉ាស៊ូតដែលមានចំណុះស្ពាន់ធ័រធំជាង 10 000 មក្រ/គក្រ (10 000 ភាគក្នុងមួយលាន)។

សម្ភារៈ: ដូចជាទង់ដែង សំណ ស័ង្កសី សំណប៉ាហាំង ស្ពាន់និងសំរិទ្ធិគួរតែចៀសវាងប្រើជាគ្រឿងបរិក្ខារសម្រាប់ចាត់ចែងចែកចាយនិងទុកដាក់ប្រេងឥន្ធនៈ: ពីព្រោះលោហធាតុទាំងនេះ អាចបង្កើតប្រតិកម្មអុកស៊ីដកម្មប្រេងឥន្ធនៈដែលអាចបណ្តាលឲ្យកកប្រព័ន្ធប្រេងឥន្ធនៈនិងស្ទះតម្រងប្រេង។

ប្រេងឥន្ធៈ E-Diesel

កុំប្រើប្រេងម៉ាស៊ូត E-Diesel (ល្បាយប្រេងម៉ាស៊ូត និងអេតាណុល)។ ការប្រើប្រាស់ប្រេងម៉ាស៊ូត E-Diesel នៅក្នុងគ្រឿងចក្រ John Deere ណាមួយ អាចធ្វើឲ្យខូចការធានារ៉ាប់រងចំពោះគ្រឿងចក្រ។

⚠ ប្រយ័ត្ន៖ ប្រយ័ត្នក្រែងលោរងរបួសធ្ងន់ធ្ងរ ឬស្លាប់ដោយសារការផ្ទុះនិងអគ្គីភ័យដែលបណ្តាលមកពីការប្រើប្រេង E-Diesel។

បរិមាណស្ពាន់ធ័រសម្រាប់ម៉ាស៊ីន Interim Tier 4, Final Tier 4, Stage III B, Stage IV, និង Stage V លើសពី 560 kW

- ចូរប្រើតែប្រេងម៉ាស៊ូតដែលមានចំណុះស្ពាន់ធ័រអតិបរិមា 500 មក្រ/គក្រ (500 ppm) ប៉ុណ្ណោះ។

បរិមាណស្ពាន់ធ័រសម្រាប់ម៉ាស៊ីន Interim Tier 4, Final Tier 4, Stage III A និង B, Stage IV, និង Stage V

- ប្រើប្រាស់តែ ប្រេងម៉ាស៊ូតមានស្ពាន់ធ័រទាបខ្លាំង (ULSD) ដែលមានចំណុះស្ពាន់ធ័រអតិបរិមា 15 មក្រ/គក្រ (15 ppm) ប៉ុណ្ណោះ។

ចំណុះស្ពាន់ធ័រសម្រាប់ម៉ាស៊ីនថ្នាក់ទី 3 និងដំណាក់កាលទី III A

- គួរប្រើប្រាស់ប្រេងម៉ាស៊ូតដែលមានចំណុះស្ពាន់ធ័រតិចជាង 1000 មក្រ/គក្រ (1000 ភាគក្នុងមួយលាន) ។
- ការប្រើប្រាស់ប្រេងម៉ាស៊ូតដែលមានចំណុះស្ពាន់ធ័រ 1000—2000 មក្រ/គក្រ (1000—2000 ភាគក្នុងមួយលាន) កាត់បន្ថយចន្លោះពេលផ្លាស់ប្តូរប្រេងម៉ាស៊ីន និងតម្រងប្រេងម៉ាស៊ីន។
- មុននឹងប្រើប្រាស់ប្រេងម៉ាស៊ូតដែលមានចំណុះស្ពាន់ធ័រច្រើនជាង 2000 មក្រ/គក្រ (2000 ភាគក្នុងមួយលាន) សូមទាក់ទងអ្នកចែកចាយ John Deere របស់អ្នក។

ចំណុះស្ពាន់ធ័រសម្រាប់ម៉ាស៊ីនថ្នាក់ទី 2 និងដំណាក់កាលទី II

- គួរប្រើប្រាស់ប្រេងម៉ាស៊ូតដែលមានចំណុះស្ពាន់ធ័រតិចជាង 2000 មក្រ/គក្រ (2000 ភាគក្នុងមួយលាន) ។
- ការប្រើប្រាស់ប្រេងម៉ាស៊ូតដែលមានចំណុះស្ពាន់ធ័រ 2000—5000 មក្រ/គក្រ (2000—5000 ភាគក្នុងមួយលាន) កាត់បន្ថយចន្លោះពេលផ្លាស់ប្តូរប្រេងម៉ាស៊ីន និងតម្រងប្រេងម៉ាស៊ីន។[1]
- មុននឹងប្រើប្រាស់ប្រេងម៉ាស៊ូតដែលមានចំណុះស្ពាន់ធ័រច្រើនជាង 5000 មក្រ/គក្រ (5000 ភាគក្នុងមួយលាន) សូមទាក់ទងអ្នកចែកចាយ John Deere របស់អ្នក។

ចំណុះស្ពាន់ធ័រសម្រាប់ម៉ាស៊ីនផ្សេងៗ

- គួរប្រើប្រាស់ប្រេងម៉ាស៊ូតដែលមានចំណុះស្ពាន់ធ័រតិចជាង 5000 មក្រ/គក្រ (5000 ភាគក្នុងមួយលាន) ។
- ការប្រើប្រាស់ប្រេងម៉ាស៊ូតដែលមានចំណុះស្ពាន់ធ័រច្រើនជាង 5000 មក្រ/គក្រ (5000 ភាគក្នុងមួយលាន) កាត់បន្ថយចន្លោះពេលផ្លាស់ប្តូរប្រេងម៉ាស៊ីន និងតម្រងប្រេងម៉ាស៊ីន។

សំខាន់៖ កុំលាយប្រេងម៉ាស៊ីនម៉ាស៊ូតដែលប្រើប្រាស់រួច ឬប្រេងរំអិលប្រភេទផ្សេងទៀតជាមួយនឹងប្រេងម៉ាស៊ីនម៉ាស៊ូត។

ការប្រើប្រាស់ប្រេងបន្ថែមមិនបានត្រឹមត្រូវ អាចបង្កការខូចខាតដល់ឧបករណ៍ចាក់បញ្ចូលប្រេងឥន្ធនៈរបស់ម៉ាស៊ីនម៉ាស៊ូត។

[1] សម្រាប់ព័ត៌មានបន្ថែមស្តីអំពីសេវាកម្មប្រេងប្រេងនិងសេវាកម្មតម្រង ចូរមើល *DX,ENOIL12,OEM, DX,ENOIL12,T2,STD,* ឬ*DX,ENOIL12,T2, EXT*។

DX,FUEL1-KM-01NOV22-1/1

ប្រេងជីវៈម៉ាស៊ូត

ឥន្ធនៈជីវម៉ាស៊ូតមានសារធាតុម្សៅអ័រគីលីសនៃអាស៊ីតខ្លាញ់ច្រវាក់វែងដែលបានមកពីប្រេងបន្លែឬខ្លាញ់សត្វ។ ល្បាយជីវៈម៉ាស៊ូត គឺជាជីវៈម៉ាស៊ូតដែលលាយជាមួយប្រេងឥន្ធនៈតាមមូលដ្ឋានមាឌ។

មុនពេលប្រើប្រាស់ប្រេងឥន្ធនៈដែលមានផ្គុកជីវៈម៉ាស៊ូត សូមពិនិត្យមើលការណែនាំ និងលក្ខខណ្ឌចាំបាច់ក្នុងការប្រើប្រាស់ជីវៈឥន្ធនៈ នៅក្នុងសៀវភៅណែនាំអ្នកបើកបរ។

នីតិបញ្ញត្តិ និងច្បាប់បរិស្ថានអាចលើកទឹកចិត្ត ឬក៏ហាមប្រាមនូវការប្រើប្រាស់ជីវឥន្ធនៈ។ អ្នកបើកបរគួរតែពិគ្រោះជាមួយអាជ្ញាធររដ្ឋាភិបាលពាក់ព័ន្ធ មុននឹងប្រើប្រាស់ជីវៈឥន្ធនៈ។

John Deere Stage V Engines ដែលប្រតិបត្តិការនៅក្នុងសហភាពអឺរ៉ុប

នៅកន្លែងដែលម៉ាស៊ូនត្រូវបានដំណើរការនៅក្នុងសហភាពអឺរ៉ុប ស្តីពីប្រេងឥន្ធនៈម៉ាស៊ូតឬប្រេងឥន្ធនៈឧស្ម័នដែលមិនចប្រើលើផ្លូវថ្នល់ ប្រេងឥន្ធនៈដែលមានបរិមាណ FAME មិនលើសពី 8% បរិមាណ / បរិមាណ (B8) នឹងត្រូវប្រើ។

ម៉ាស៊ូន John Deere ដែលប្រើតម្រងបំពង់ស៊ីម៉ុងលើកលែងម៉ាស៊ូណដំណាក់កាល V ដែលប្រតិបត្តិការនៅក្នុងសហភាពអឺរ៉ុប

ល្បាយជីវឥន្ធនៈរហូតដល់ B20 អាចត្រូវបានគេប្រើប្រាស់លុះត្រាតែជីវឥន្ធនៈ: (ជីវឥន្ធនៈ: 100% ឬ B100) បំពេញតាមលក្ខណៈបច្ចេកទេស ASTM D6751 EN14214 ឬលក្ខណៈបច្ចេកទេសសមមូល។ នៅពេលដែលប្រើប្រាស់B20 សូមគិតថានឹងមានការថយចុះ 2% លើកំលាំងថាមពល និង ថយចុះ 3% លើការសន្សំសំចៃប្រេង។

កំហាប់ជីវឥន្ធនៈដែលលើសពី B20 អាចធ្វើឲ្យខូចប្រព័ន្ធគ្រប់គ្រងការបញ្ចេញផ្សែងរបស់ម៉ាស៊ូន ហើយគួរតែកុំប្រើប្រាស់អោយសោះ។ ហានិភ័យរួមបញ្ចូលតែមិនកំណត់ចំពោះ ការកើនឡើងដំណើរការសម្អាតតម្រងនៅពេលបញ្ចោះម៉ាស៊ូន ការកើនឡើងកំទេចម៉ត់កាបូន(soot) និងការកើនឡើងចន្លោះពេលសម្រាប់ដកផេះចេញ។

ខនឌីហ្សិណឺរឬសមមូលដែលអនុញ្ញាតឲ្យប្រើដោយ John Deere ដែលផ្គុកម្សៅសម្អាត និង សារធាតុបន្ថែមការពារកករ ត្រូវការចាំបាច់នៅពេលដែលប្រើប្រាស់ល្បាយជីវឥន្ធនៈពី B10 ដល់ B20 និងត្រូវបានណែនាំឲ្យប្រើពេលដែលប្រើប្រាស់ល្បាយជីវឥន្ធនៈមានកម្រិតទាប។

ម៉ាស៊ូណ John Deere ដែលមិនមានតម្រងបពង់ផ្សែងស៊ីម៉ុង John Deere

ល្បាយជីវឥន្ធនៈរហូតដល់ B20 អាចត្រូវបានគេប្រើប្រាស់លុះត្រាតែជីវឥន្ធនៈ: (ជីវឥន្ធនៈ: 100% ឬ B100) បំពេញតាមលក្ខណៈបច្ចេកទេស ASTM D6751 EN14214 ឬលក្ខណៈបច្ចេកទេសសមមូល។ នៅពេលដែលប្រើប្រាស់B20 សូមគិតថានឹងមានការថយចុះ 2% លើកំលាំងថាមពល និង ថយចុះ 3% លើការសន្សំសំចៃប្រេង។

ម៉ាស៊ូន John Deere ទាំងនេះអាចបើកបរដោយប្រើល្បាយជីវឥន្ធនៈលើស B20 (រហូតដល់ជីវឥន្ធនៈ: 100%)។ បើកបរនៅកំរិតលើសពី B20 លុះត្រាតែជវឥន្ធនៈត្រូវបានអនុញ្ញាតដោយច្បាប់ និងបំពេញលក្ខណៈបច្ចេកទេស EN14214 (ដែលជាបឋមមាននៅអ៊ឺរ៉ុប)។ គ្រឿងចក្រដែលបើកបរដោយប្រើល្បាយជីវឥន្ធនៈលើសពី B20 អាចមិនស្របទៅតាម និងអនុញ្ញាតដោយច្បាប់បញ្ចេញផ្សែងដែលត្រូវបានគេអនុវត្តទាំងស្រុងទេ។ រំពឹងថានឹងមានការថយចុះរហូតដល់ 12% លើថាមពល និង ថយចុះ 18% លើការសន្សំសំចៃប្រេងនៅពេលដែលប្រើប្រាស់ជីវឥន្ធនៈ: 100%។

ខនឌីហ្សិណឺរឬសមមូលដែលអនុញ្ញាតឲ្យប្រើដោយ John Deere ដែលផ្គុកម្សៅសម្អាត និង សារធាតុបន្ថែមការពារកករ ត្រូវការចាំបាច់នៅពេលដែលប្រើប្រាស់ល្បាយជីវឥន្ធនៈពី B10 ដល់ B100 និងត្រូវបានណែនាំឲ្យប្រើពេលដែលប្រើប្រាស់ល្បាយជីវឥន្ធនៈមានកម្រិតទាប។

សេចក្តីតម្រូវប្រើជីវៈម៉ាស៊ូតនិងអនុសាសន៍

ចំណែករបស់ប្រេងឥន្ធនៈនៃល្បាយជីវឥន្ធនៈទាំងអស់ត្រូវតែបំពេញទៅតាមលក្ខខណ្ឌត្រូវការរបស់បទដ្ឋានពាណិជ្ជកម្ម ASTM 975 (សហរដ្ឋអាមេរិក) ឬ EN 590 (អ៊ឺរ៉ុប)។

អ្នកប្រើប្រាស់ជីវឥន្ធនៈ:ទាំងឡាយនៅក្នុងសហរដ្ឋអាមេរិកត្រូវបានលើកទឹកចិត្តយ៉ាងខ្លាំងអោយជាវល្បាយឥន្ធនៈពីអ្នកនាំទំនិញទៅទីផ្សារដែលមានការបញ្ជាក់ពី BQ-9000 និងមានប្រភពពីអ្នកផលិតដែលទទួលស្គាល់ពី BQ-9000 (ជាការបញ្ជាក់ពីគណៈក្រុមប្រឹក្សាជីវឥន្ធនៈជាតិ)។ អ្នកនាំទំនិញទៅទីផ្សារដែលមានការបញ្ជាក់ និងអ្នកផលិតដែលទទួលស្គាល់ អាចរកបានតាមគេហទំព័រដូចតទៅ៖ http://www.bq9000.org។

ចំហេះមានផេះសំណល់។ កម្រិតផេះដែលលើសអតិបរមាដែលបានអនុញ្ញាតទាំងនៅក្នុង ASTM D6751 ឬ EN14214 អាចបណ្តាលឲ្យមានការផ្គុកផេះកាន់តែឆាប់រហ័ស និងទាមទារឲ្យមានការសម្អាតតម្រងស៊ីម៉ុងឲ្យបានញឹកញាប់ (ប្រសិនជាមាន)។

តម្រងប្រេងអាចទាមទាឲ្យមានការប្រាស់ប្តូរញឹកញាប់ជាងមុននៅពេលដែលប្រើប្រាស់ប្រេងជីវឥន្ធនៈ: ជាពិសេសប្រសិនបើផ្លាស់ប្តូរពីប្រេងម៉ាស៊ូត។ ត្រួតពិនិត្យកម្រិតប្រេងម៉ាស៊ូនប្រចាំថ្ងៃ មុនពេលបញ្ឆោះម៉ាស៊ូន។ កម្រិតប្រេងកើនឡើងអាចបង្ហាញពីភាពពង្រាររបស់ប្រេងឥន្ធនៈនៃប្រេងម៉ាស៊ូន។ ជីវម៉ាស៊ូតលាយបញ្ចូលគ្នារហូតដល់ប្រភេទ B20 ត្រូវតែប្រើក្នុងរយៈពេល 90 ថ្ងៃនៃកាលបរិច្ឆេទនៃការផលិតជីវម៉ាស៊ូត។ ល្បាយជីវឥន្ធនៈលើសពី B20 គួរត្រូវបានប្រើប្រាស់ក្នុងអំឡុងពេល 45ថ្ងៃ ចាប់ពីកាលបរិច្ឆេទនៃការផលិតជីវឥន្ធនៈ។

នៅពេលដែលប្រើប្រាស់ល្បាយជីវឥន្ធនៈដែលមានរហូតដល់ B20 ត្រូវតែគិតដូចតទៅ៖

- ការផ្លាក់ចុះលំហូរនៅសីតុណ្ហភាពត្រជាក់
- បញ្ហាការក្បាទុក និង បញ្ហាស្រោរភាព (ការស្រូបយកសំណើម ការលូតលាស់នៃពួកមេរោគ)។
- អាចមានការគាំង និងស្ទះតម្រងប្រេង (ជាទូទៅវាជាបញ្ហាមួយនៅពេលដែលមានការផ្លាស់ប្តូរទៅប្រើជីវឥន្ធនៈទៅលើគ្រឿងចក្រដែលត្រូវបានប្រើរួច។
- អាចមានការលេចជ្រាបប្រេងឥន្ធនៈ: តាមរ៉ងនិងទុយោ (ជាបញ្ហាចំបងមួយមានលើគ្រឿងចក្រចាស់)។
- អាចមានការថយចុះជីវិតប្រើប្រាស់នៃគ្រឿងម៉ាស៊ូនទាំងឡាយ។

ស្នើសុំវិញ្ញាបនបត្រនៃការវិភាគពីអ្នកចែកចាយប្រេងឥន្ធនៈដើម្បីធានាថាប្រេងឥន្ធនៈស្របទៅតាមលក្ខណៈបច្ចេកទេសដែលបានផ្តល់ក្នុងសៀវភៅណែនាំអ្នកបើកបរ។

សូមពិគ្រោះជាមួយអ្នកចែកចាយ John Deere អំពីផលិតផលប្រេងឥន្ធនៈ John Deere ដើម្បីបង្កើនការសុកទុកនិងប្រសិទ្ធពលជាមួយឥន្ធនៈជីវម៉ាស៊ូត។

តទៅទំព័របន្ទាប់

DX,FUEL7-KM-13JAN18-1/2

នៅពេលដែលប្រើប្រាស់ល្បាយជីវឥន្ធនៈលើសពី B20 ត្រូវតែគិតដូចតទៅ៖

- ក្បាលបិចអាចឈ្លក់ប្រេង ឬស្នះ ដែលបណ្តាលមកពីការបាត់បង់ថាមពលនិងការឧកធំហេះម៉ាស៊ីន ប្រសិនបើមិនប្រើគ្រឿងបន្ថែម និងខន់ឌីហ្សីលើរ ឬម្សៅសាប៊ូសមូលទេនោះ។
- អាចមានភាពពង្រាវនៃប្រេងម៉ាស៊ីនក្នុងប្រអប់រ៉ែ (ទាមទារអោយមានការផ្លាស់ប្តូរប្រេងម៉ាស៊ីនជាញឹកញាប់)។
- អាចមានខ្លោចលើង ឬការគាំងនៃគ្រឿងក្នុង
- អាចកើតមានស្នែ និងកំទេចកំទី
- អាចកើតមានអុកស៊ីដកម្មកំដៅនៃប្រេងឥន្ធនៈដោយសារការកើនសីតុណ្ហភាពខ្ពស់
- អាចកើតមានបញ្ហានៃភាពឆបគ្នាជាមួយវត្ថុធាតុផ្សេងៗទៀត (រួមមាន៖ ទង់ដែង សំណរ សង្កសី សំណប៉ាហាំង លង្ហិន និងសំរិទ្ធ) ដែលត្រូវបានប្រើប្រាស់នៅក្នុងឧបករណ៍ចាត់ចែងប្រេងឥន្ធនៈ ចែកចាយ និងស្តុកទុក។
- អាចមានការថយចុះនូវប្រសិទ្ធិភាពនៃឧបករណ៍ញែកចម្រោះទឹក។
- អាចខូចពណ៌ថ្នាំ ប្រសិនជាប៉ះនឹងជីវឥន្ធនៈ។
- អាចកើតច្រេះលើឧបករណ៍បាញ់ប្រេង។
- អាចមានការចិចរិលហ្វឹត និងរ៉ងកៅស៊ូ(ជាចំបងជាបញ្ហាជាមួយគ្រឿងចក្រចាស់)។
- អាចមានកម្រិតអាស៊ីតខ្ពស់ក្នុងប្រព័ន្ធប្រេងឥន្ធនៈ។
- ពីព្រោះល្បាយជីវឥន្ធនៈលើ B20 មានផ្ទុកជេះ ការប្រើប្រាស់ល្បាយលើ B20 អាចបណ្តាលឲ្យមានការកើតមាន ការផ្ទុកជេះឆាប់រហ័សទៅៗ និងទាមទារឲ្យមានការសំអាតតម្រងបំពង់ស៊ីមុាំង (ប្រសិនជាមាន)។

សំខាន់៖ ប្រេងឆៅដែលបានមកពីការគៀបចេញពីរុក្ខជាតិបន្លែមិនត្រូវបានអនុញ្ញាតអោយប្រើជាប្រេងឥន្ធនៈទោះក្នុងកំហាប់ណាក៏ដោយទៅក្នុងគ្រឿងចក្រ John Deere បានទេ។ ការប្រើប្រាស់វាអាចធ្វើឲ្យខូចគ្រឿងម៉ាស៊ីន។

DX,FUEL7-KM-13JAN18-2/2

ភាពរំអិលនៃប្រេងម៉ាស៊ូត

ប្រេងម៉ាស៊ូតភាគច្រើនដែលផលិតនៅសហរដ្ឋអាមេរិក កាណាដា និងសហភាពអឺរ៉ុប មានភាពរំអិលគ្រប់គ្រាន់ដើម្បីធានានូវប្រតិបត្តិការត្រឹមត្រូវ និងជាប់បានយូរនៃសមាសភាគប្រព័ន្ធចាក់បញ្ចូលប្រេងឥន្ធនៈ។ ទោះជាយ៉ាងណាប្រេងម៉ាស៊ូតដែលផលិតនៅតំបន់មួយចំនួននៅក្នុងពិភពលោកអាចខ្វះភាពរំអិលដែលចាំបាច់។

សំខាន់៖ ធ្វើឲ្យប្រាកដថា ប្រេងម៉ាស៊ូតដែលប្រើប្រាស់នៅក្នុងគ្រឿងចក្ររបស់អ្នកបង្ហាញឲ្យឃើញនូវលក្ខណៈភាពរំអិលល្អ។

ភាពរំអិលនៃប្រេងឥន្ធនៈ គួរឆ្លងផុតអង្កត់ផ្ចិតសម្លាកអតិបរមា .52 មម តាមការវាស់វែងដោយ ASTM D6079 ឬ ISO 12156-1។ យកល្អគួរប្រើអង្កត់ផ្ចិតសម្លាកអតិបរមា .45 មម។

ប្រសិនបើប្រើប្រាស់ប្រេងដែលមានភាពរំអិលកម្រិតទាប ឬកម្រិតណាមួយដែលគេមិនដឹង សូមបន្ថែម ធាតុសម្រួលប្រេងប្រេងម៉ាស៊ូតការពារប្រេងឥន្ធនៈ (ឬកម្រិតស្មើគ្នា) នៅកម្រិតភាពខាប់ជាក់លាក់ណាមួយ។

ភាពរំអិលនៃជីវប្រេងឥន្ធនៈម៉ាស៊ូត

ភាពរំអិលនៃប្រេងឥន្ធនៈ អាចធ្វើឲ្យប្រសើរឡើងយ៉ាងច្រើនជាមួយនឹងល្បាយជីវម៉ាស៊ូតរហូតដល់ B20 (20% ជីវម៉ាស៊ូត)។ កំណើនបន្ថែមនៃភាពរំអិលគឺមានកម្រិតសម្រាប់ល្បាយជីវម៉ាស៊ូតដែលធំជាង B20។

DX,FUEL5-KM-07FEB14-1/1

សារធាតុបន្ថែមទៅលើប្រេងម៉ាស៊ូតបំពេញបន្ថែម

ប្រេងម៉ាស៊ូតអាចជាប្រភពនៃប្រសិទ្ធពល ឬជាប្រភពនៃបញ្ហាប្រតិបត្តិការដទៃទៀតក្នុងហេតុផលជាច្រើន។ មូលហេតុរួមមានភាពរំអិលខ្សោយ ភាពកខ្វក់ ចំនួនជាតិសេតានទាប និងលក្ខណៈជាច្រើនដែលបង្ករឲ្យមានកំណក្នុងប្រព័ន្ធប្រេងឥន្ធនៈ។ លក្ខណៈទាំងនេះនិងលក្ខណៈដទៃទៀតមានបង្ហាញនៅក្នុងផ្នែកផ្សេងទៀតនៃសៀវភៅណែនាំប្រើប្រាស់នេះ។

ដើម្បីធ្វើឲ្យម៉ាស៊ីនកាន់តែមានប្រសិទ្ធពលនិងអាចទុកចិត្តបាន ចូរអនុវត្តឲ្យបានជិតដល់តាមអនុសាសន៍ស្តីពីគុណភាពប្រេងរំអិល ការទុកដាក់ និងការប្រើប្រាស់ដែលមាននិយាយនៅក្នុងផ្នែកផ្សេងទៀតនៅក្នុងសៀវភៅណែនាំប្រើប្រាស់នេះ។

ដើម្បីជួយរក្សាប្រសិទ្ធពលនិងភាពជឿទុកចិត្តលើប្រព័ន្ធប្រេងឥន្ធនៈរបស់ម៉ាស៊ីនជាបន្ថែម John Deere បានផលិតនូវអំបូរផលិតផលដាក់បន្ថែមក្នុងប្រេងឥន្ធនៈសម្រាប់លក់ក្នុងទីផ្សារភាគច្រើន។ ផលិតផលចម្បងទាំងនោះរួមមាន Fuel-Protect Diesel Fuel Conditioner (ខនឌីហ្សីនណឺរពេញលក្ខណៈសម្រាប់ប្រើក្នុងរដូវត្រជាក់និងរដូវក្តៅ) និង Fuel-Protect Keep Clean (សារធាតុសម្អាតនិងបង្ការកំណប៊ិចប្រេង)។ ការរកទិញផលិតផលទាំងនេះនិងផលិតផលដទៃទៀតបានអាស្រ័យទៅលើទីផ្សារ។ ចូរពិគ្រោះជាមួយអ្នកចែកចាយក្រុមហ៊ុន John Deere ក្នុងមូលដ្ឋានរបស់លោកអ្នកដើម្បីរកទិញ និងអំពីព័ត៌មានបន្ថែមអំពីសារធាតុបន្ថែមក្នុងប្រេងឥន្ធនៈដែលអាចឆ្លើយតមនឹងតម្រូវការរបស់លោកអ្នក។

DX,FUEL13-KM-07FEB14-1/1

ការធ្វើតេស្តប្រេងម៉ាស៊ូត

កម្មវិធីវិភាគប្រេងឥន្ធនៈ អាចជួយដល់ការត្រួតពិនិត្យគុណភាពនៃប្រេងម៉ាស៊ូត។ ការវិភាគប្រេងឥន្ធនៈអាចផ្តល់ទិន្នន័យសំខាន់ៗដូចជា សន្ទស្សន៍សេតានដែលបានគណនា ប្រភេទប្រេងឥន្ធនៈ ចំណុះស្ពានជ័រ ចំណុះទឹក លក្ខណៈខាងក្រៅ ភាពសមស្របសម្រាប់ប្រតិបត្តិការក្នុងអាកាសធាតុត្រជាក់ ជាក់តេរី ចំនុចរងជាក្រមួន ចំនួនអាស៊ីត ភាពកខ្វក់នៅក្នុងទម្រង់បំបែកជាចំណែកៗ និងថាតើប្រេងឥន្ធនៈនេះឆ្លើយតបទៅនឹងលក្ខណៈបច្ចេកទេស ASTM D975 ឬដែលមានតម្លៃស្មើដែរឬទេ។

សូមទាក់ទងអ្នកចែកចាយ John Deere របស់អ្នកសម្រាប់ព័ត៌មានបន្ថែមអំពីការវិភាគប្រេងម៉ាស៊ូត។

DX,FUEL6-KM-13JAN18-1/1

កាត់បន្ថយឥទ្ធិពលនៃអាកាសធាតុត្រជាក់លើម៉ាស៊ីនម៉ាស៊ូត

រាល់ម៉ាស៊ីនម៉ាស៊ូត John Deere ទាំងឡាយ ត្រូវបានរចនាឡើងដើម្បីដំណើរការយ៉ាងមានប្រសិទ្ធិភាពក្នុងអាកាសធាតុត្រជាក់។

ទោះជាយ៉ាងណាក៏ដោយ ដើម្បីដំណើរការនៅអាកាសធាតុត្រជាក់ និងការបញ្ចេះអោយមានប្រសិទ្ធភាព ការយកចិត្តទុកដាក់បន្ថែមមានភាពចាំបាច់។ ពត៌មានបន្តបន្ទាប់ផ្តល់នូវជំហានសំខាន់ៗដែលអាចកាត់បន្ថយនូវឥទ្ធិពលដែលអាកាសធាតុត្រជាក់អាចមានទៅលើដំណើរការ និងការបញ្ចេះគ្រឿងម៉ាស៊ីនរបស់អ្នក។ សូមទៅជួបអ្នកចែកចាយJohn Deere របស់អ្នក សំរាប់ពត៌មានបន្ថែម និងជំនួយលើដំណើរការក្នុងអាកាសធាតុត្រជាក់ដែលអាចមាននៅក្នុងតំបន់របស់អ្នក។

ប្រើប្រាស់ប្រេងឥន្ធនៈ:ចំណាត់ថ្នាក់រដូវរងា

នៅពេលដែលសីតុណ្ហភាពធ្លាក់ចុះក្រោម 0 ° C (32 ° F), ឥន្ធនៈរដូវរងារ (លេខ 1-D នៅអាមេរិកខាងជើង) គឺល្អបំផុតសម្រាប់ប្រតិបត្តិការអាកាសធាតុត្រជាក់។ នៅពេលដែលប្រេងឥន្ធនៈ:ចំណាត់ថ្នាក់រដូវរងាមានចំនុចរងជាក្រមួន និងចំនុចលំហូរទាប។

ចំនុចរងជាក្រមួន ជាសីតុណ្ហភាពដែលក្រមួនចាប់ផ្តើមកកើតឡើងនៅក្នុងប្រេងឥន្ធនៈ។ ក្រមួននេះបណ្តាលឲ្យតម្រងប្រេងស្ទះ។ **ចំនុចលំហូរ** ជាសីតុណ្ហភាពដែលចលនារបស់ប្រេងឥន្ធនៈអាចត្រូវបានសង្កេតមើលឃើញ។

កំណត់ចំណាំ៖ ជាមធ្យម ប្រេងឥន្ធនៈ:ចំណាត់ថ្នាក់រដូវរងាមានអត្រាថាមពល *Btu (បរិមាណកំដៅ)* ទាប។ ប្រើប្រាស់ប្រេងឥន្ធនៈ:ចំណាត់ថ្នាក់រដូវរងាអាចកាត់បន្ថយថាមពល និងប្រសិទ្ធភាពប្រេងឥន្ធនៈ: ប៉ុន្តែវាមិនបណ្តាលឲ្យមានឥទ្ធិពលដទៃទៀតលើប្រសិទ្ធភាពបំពេញមុខងាររបស់ម៉ាស៊ីនទេ។ ត្រួតពិនិត្យមើលចំណាត់ថ្នាក់ប្រេងឥន្ធនៈដែលត្រូវប្រើ មុនពេលដោះស្រាយរកបញ្ហាលើម៉ាស៊ីនមានកំលាំងទាប ក្នុងពេលដំណើរការក្នុងអាកាសធាតុត្រជាក់។

ឧបករណ៍កំដៅខ្យល់ចូល

ឧបករណ៍កំដៅខ្យល់ចូល ជាជំរើសដែលអាចមានសំរាប់គ្រឿងម៉ាស៊ីនមួយចំនួន ដើម្បីជំនួយក្នុងការបញ្ចេះក្នុងអាកាសធាតុត្រជាក់។

អេតែរ

មានច្រកអេតែរនៅកន្លែងខ្យល់ចូល ដើម្បីជួយក្នុងការបញ្ចេះម៉ាស៊ីននៅពេលអាកាសធាតុត្រជាក់។

⚠ ប្រយ័ត្ន៖ អេតែរងាយនឹងឆាបឆេះបំផុត។ កុំប្រើអេតែរនៅពេលណាដែលបញ្ចេះម៉ាស៊ីនដែលមានបំពាក់ជាមួយប៉ូស៊ីកំដៅ ឬឧបករណ៍កំដៅខ្យល់ចូល។

ឧបករណ៍កំដៅទឹកស្អំម៉ាស៊ីន

ឧបករណ៍កំដៅប្លុកម៉ាស៊ីន (ឧបករណ៍កំដៅទឹកស្អំម៉ាស៊ីន) ជាជំរើសដែលអាចមានដើម្បីជួយក្នុងការបញ្ចេះនៅក្នុងពេលអាកាសធាតុត្រជាក់។

ប្រេងម៉ាស៊ីនដែលមានភាពអន្ទិលតាមរដូវកាល និងកំហាប់សមរម្យរបស់ទឹកស្អំម៉ាស៊ីន

ប្រើប្រាស់ប្រេងម៉ាស៊ីនដែលមានភាពអន្ទិលតាមរដូវកាលផ្អែកលើចន្លោះសីតុណ្ហភាពខ្យល់ដែលត្រូវបានរំពឹងទុកនៅរវាងការប្រែប្រួលប្រេងម៉ាស៊ីន និងកំហាប់សមរម្យរបស់សារធាតុប្រឆាំងការកកដែលមានស៊ីលីកាទាបដូចបានណែនាំ។ (សូមមើល លក្ខណៈចាំបាច់របស់ប្រេងម៉ាស៊ីនម៉ាស៊ូត និងទឹកស្អំម៉ាស៊ីន នៅក្នុងផ្នែកនេះ។)

គ្រឿងបន្ថែមលំហូរត្រជាក់ប្រេងម៉ាស៊ូតប្រេងឥន្ធនៈ:

ប្រើប្រាស់សារធាតុសម្រួល និងការពារប្រេងឥន្ធនៈ:ម៉ាស៊ូតរបស់ John Deere (រូបមន្តរដូវរងា) ដែលមានសារធាតុគីមីប្រឆាំងការខាប់អន្ទិល ឬសារធាតុសម្រួលប្រេងឥន្ធនៈ:សមមូល ដើម្បីធ្វើប្រព្រឹត្តកម្មប្រេងឥន្ធនៈ:ចំណាត់ថ្នាក់មិនមែនរដូវរងា (លេខ 2-D នៅអាមេរិកខាងជើង) អំឡុងពេលរដូវត្រជាក់។ ប្រការនេះជាទូទៅពង្រីកលទ្ធភាពប្រតិបត្តិការទៅដល់ប្រហែល 10 ° C (18 ° F) ខាងក្រោមចំណុចពពកឥន្ធនៈ:។ សំរាប់សមត្ថភាពដំណើរការទោះបីជាឥន្ធនៈសីតុណ្ហភាពទាបក្តី ចូរប្រើប្រាស់ប្រេងឥន្ធនៈ:ចំណាត់ថ្នាក់រដូវរងា។

សំខាន់៖ ធ្វើប្រព្រឹត្តកម្មប្រេងឥន្ធនៈ:នៅពេលសីតុណ្ហភាពខាងក្រៅធ្លាក់ក្រោម 0 °C (32 °F)។ ដើម្បីបានលទ្ធផលល្អ ប្រើប្រាស់ប្រេងឥន្ធនៈ:ដែលមិនត្រូវបានធ្វើប្រព្រឹត្តកម្ម។ ធ្វើតាមការណែនាំទាងឡាយទៅតាមស្លាក។

ជីវៈម៉ាស៊ូត

នៅពេលដំណើរការជាមួយជីវៈម៉ាស៊ូត ការកកើតកំណកពណ៌សអាចកើតមានឡើងនៅពេលសីតុណ្ហភាពក្តៅ។ ប្រើប្រាស់សារធាតុសម្រួល និងការពារប្រេងឥន្ធនៈ:ម៉ាស៊ូតរបស់ John Deere (រូបមន្តរដូវរងា)ឬសមមូល នៅ 5 °C (41 °F) ដើម្បីធ្វើប្រព្រឹត្តកម្មប្រេងជីវៈម៉ាស៊ូត អំឡុងពេលរដូវត្រជាក់។ ប្រើប្រាស់ B5 ឬល្បាយទាបនៅសីតុណ្ហភាពក្រោម 0 °C (32 °F)។ ប្រើប្រាស់ប្រេងឥន្ធនៈ:ម៉ាស៊ូតចំណាត់ថ្នាក់រដូវរងានៅសីតុណ្ហភាពក្រោម -10 °C (14 °F)។

រនាំងការពារព្រិល និងទឹកកក

ប្រើប្រាស់រនាំងការពារព្រិល និងទឹកកក ដែលធ្វើពីក្រណាត់ក្រដាសការតុង ឬតូរិង មិនត្រូវបានណែនាំឲ្យប្រើជាមួយគ្រឿងម៉ាស៊ីន John Deere ឡើយ។ ការប្រើប្រាស់វា អាចបណ្តាលឲ្យមានសីតុណ្ហភាពទឹកស្អំម៉ាស៊ីន ប្រេង និងខ្យល់ចូលខ្ពស់។ ទាំងនេះបណ្តាលឲ្យអាយុកាលម៉ាស៊ីនត្រូវបានកាត់បន្ថយ ការបាត់បង់ថាមពល និងការសន្សំសំចៃប្រេងទាប។ រនាំងការពារព្រិល និងទឹកកកអាចបង្កើតកំលាំងខុសប្រក្រតីទៅលើកង្ហារ ឧបករណ៍ចំលងចលនាដោយកង្ហារ ដោយអាចបង្កឲ្យមានការខូចមុនពេលកំណត់។

ប្រសិនបើរនាំងការពារព្រិល និងទឹកកកត្រូវបានប្រើ រនាំងការពារព្រិល និងទឹកកកនោះមិនគួរបិទជិតផ្ទៃសំណាញ់ដែកមុខឡើយ។ ផ្ទៃប្រហែល 25% នៅកណ្តាលចំរឹងដែកខាងមុខគួរតែរក្សាឲ្យនៅចំហគ្រប់ពេលវេលា។ គ្រប់ពេលទាំងអស់ មិនគួរដាក់វត្តុបាំងខ្យល់ចូលនៅប៉ះនឹងតួធុងទឹកស្អំឲ្យសោះ។

សន្ទះបិទធុងទឹកស្អំ

ប្រសិនបើមានបំពាក់ប្រពន្ធ័សន្ទះបិទធុងទឹកស្អំដែលបញ្ជាដោយទែរម៉ូស្តាត ប្រពន្ធ័នេះគួរតែលៃតម្រូវក្នុងរបៀបដែលសន្ទះបិទធុងទឹកស្អំត្រូវបានបើកទាំងស្រុងនៅពេលដែលទឹកស្អំម៉ាស៊ីនឡើងមុនដល់ 93 °C (200 °F) ដើម្បីការពារសីតុណ្ហភាពចូលកុំឲ្យកើនខ្ពស់ពេក។ ប្រពន្ធ័ទាំងឡាយដែលបញ្ជាដោយដៃមិនត្រូវបានណែនាំឡើយ។

ប្រសិនបើបែបបទការបញ្ចាំកំដៅរវាងខ្យល់នឹងខ្យល់ត្រូវបានប្រើប្រាស់ សន្ទះបិទត្រូវតែបើកទាំងស្រុងនៅពេលដែលសីតុណ្ហភាពខ្យល់ចូលបំពង់ឡើងដល់សីតុណ្ហភាពអនុញ្ញាតអតិបរមា ដែលចេញពីឧបករណ៍បញ្ចាំកំដៅខ្យល់ចេញពីទួរបូ។

តទៅទំព័របន្ទាប់

សម្រាប់ពត៌មានបន្ថែម សូមទៅជួបអ្នកចែកចាយ John Deere។

DX,FUEL10-KM-13JAN18-2/2

សារធាតុរាវបំពង់ស៊ីមុាំងម៉ាស៊ូត (DEF)—ប្រើប្រាស់នៅក្នុងម៉ាស៊ីនដែលបំពាក់ការកាត់បន្ថយកត្តាលីករជម្រើស (SCR)

ដើម្បីថែរក្សាប្រសិទ្ធពលបំភាយឧស្ម័នរបស់ម៉ាស៊ីន ជាការសំខាន់ត្រូវប្រើនិងចាក់បំពេញបន្ថែម DEF ស្របតាមលក្ខណៈពិសេសបច្ចេកទេស។

សារធាតុរាវនៅក្នុងបំពង់ស៊ីមុាំងប្រេងម៉ាស៊ូត (DEF) គឺជាសារធាតុរាវដែលមានភាពសុទ្ធខ្ពស់ ដែលត្រូវបានចាក់បញ្ចូលទៅក្នុងប្រព័ន្ធបំពង់ស៊ីមុាំងរបស់ម៉ាស៊ីនជាមួយប្រព័ន្ធកាត់បន្ថយកត្តាលីករជម្រើស (SCR)។ ការថែទាំភាពសុទ្ធរបស់ DEF គឺសំខាន់ដើម្បីជៀសផុតពីការដំណើរការមិនបានត្រឹមត្រូវនៅក្នុងប្រព័ន្ធ SCR។ ម៉ាស៊ីនដែលត្រូវការ DEF ត្រូវប្រើប្រាស់ផលិតផលដែលបំពេញតាមលក្ខខណ្ឌតម្រូវសម្រាប់សូលុយស្យុងអ៊ុយរ៉េលាយទឹក 32 (AUS 32) ស្របតាម ISO 22241-1។

គេណែនាំឲ្យប្រើប្រាស់សារធាតុរាវនៅក្នុងបំពង់ស៊ីមុាំងដែលប្រើប្រេងម៉ាស៊ូត (Diesel Exhaust Fluid) របស់ John Deere។

សារធាតុរាវកាត់បន្ថយជាតិពុលក្នុងផ្សែងម៉ាស៊ូត (Diesel Exhaust Fluid) របស់ John Deere អាចរកបានតាមរយៈភ្នាក់ងារចែកចាយ John Deere របស់អ្នកនៅក្នុងទំហំកញ្ចប់ខុសៗគ្នាជាច្រើនដែលស័ក្តិសមនឹងតម្រូវការប្រតិបត្តិការរបស់អ្នក។

ប្រសិនបើមិនអាចរកបានសារធាតុរាវកាត់បន្ថយជាតិពុលក្នុងផ្សែងម៉ាស៊ូតរបស់ John Deere ទេនោះ ចូរប្រើប្រាស់ DEF ដែលត្រូវបានបញ្ជាក់ដោយកម្មវិធីបញ្ជាក់សារធាតុរាវកាត់បន្ថយជាតិពុលក្នុងផ្សែងម៉ាស៊ូតរបស់វិទ្យាស្ថានតេលសិលាអាមេរិក (API) ឬដោយ AdBlue កម្មវិធីបញ្ជាក់សារធាតុរាវកាត់បន្ថយជាតិពុលក្នុងផ្សែងម៉ាស៊ូត។ ស្វែងរកនិម្មិតសញ្ញាបញ្ជាក់ API ឬឈ្មោះ AdBlue នៅលើធុង។

DX,DEF(T)-KM-08APR22-1/2

នៅក្នុងករណីមួយចំនួន DEF ត្រូវបានសំដៅដល់ដោយឈ្មោះមួយ ឬច្រើននៃឈ្មោះទាំងនេះ៖

- អ៊ុយរ៉ែ
- សូលុយស្យុងអ៊ុយរ៉េលាយទឹក 32
- AUS 32
- AdBlue
- ភ្នាក់ងារកាត់បន្ថយ NOx
- សូលុយស្យុងរបស់កាតាលីករ

RG30211—UN—08MAR18



DX,DEF(T)-KM-08APR22-2/2

ការធ្វើតេស្តសារធាតុរាវនៅក្នុងបំពង់ស៊ីមុាំងដែលប្រើប្រេងម៉ាស៊ូត (Diesel Exhaust Fluid (DEF))

សំខាន់៖ ការប្រើប្រាស់ DEF ដែលមានកំហាប់ត្រឹមត្រូវ គឺសំខាន់សម្រាប់ម៉ាស៊ីន និងការអនុវត្តរបស់ប្រព័ន្ធក្រោយប្រព្រឹត្តកម្ម។ ការរក្សាទុកដែលពន្យារពេល និងស្ថានភាពផ្សេងទៀតអាចផ្លាស់ប្តូរកំហាប់ DEF ជាអវិជ្ជមាន។

ប្រសិនបើនៅមានភាពងឿងឆ្ងល់អំពីគុណភាពរបស់ DEF យកសំណាកចេញពីអាង ឬអាងរក្សាទុក DEF ដាក់ចូលទៅក្នុងធុងទទេមួយ។ DEF ត្រូវតែមានភាពថ្លាដែលមានក្លិនអាម៉ូញាក់ស្រាល។ ប្រសិនបើ DEF ឡើងស្រអាប់ មានពណ៌ក្រៀមៗ ឬមានក្លិនអាម៉ូញាក់ខ្លាំង វាមិនទំនងជាស្ថិតនៅក្នុងលក្ខណៈពិសេសនេះឡើយ។ មិនគួរប្រើប្រាស់ DEF នៅក្នុងស្ថានភាពនេះឡើយ។ បង្ហូរវាចេញពីអាង បាញ់ទឹកដែលបានបានចម្រាញ់ និងបំពេញអាងដោយ DEF ថ្មី ឬល្អ។ បន្ទាប់ពីបំពេញអាងឡើងវិញហើយ ត្រួតពិនិត្យកំហាប់ DEF។

ប្រសិនបើ DEF បានឆ្លងផុតការធ្វើតេស្តដោយភ្នែកទទេរ និងក្លិននោះ ត្រួតពិនិត្យកំហាប់ DEF ដោយឧបករណ៍វាស់កាំរស្មីកាន់ដោយដៃដែលត្រូវបានកំណត់ដើម្បីវាស់ DEF។

កំហាប់ DEF គួរត្រូវបានត្រួតពិនិត្យនៅពេលដែលម៉ាស៊ីនត្រូវបានរក្សាទុកក្នុងរយៈពេលដែលបានពន្យារ ឬប្រសិនបើមានការសង្ស័យថាម៉ាស៊ីន ឬសារធាតុរាវ DEF ដែលបានវេចខ្ចប់ត្រូវបានបំពុលដោយទឹក។

ឧបករណ៍ដែលទទួលបានការឯកភាពចំនួនពីរអាចស្វែងរកបានតាមរយៈភ្នាក់ងារចែកចាយ John Deere របស់អ្នក៖

- JDG11594 Digital DEF Refractometer—ឧបករណ៍ឌីជីថលមួយដែលផ្តល់រង្វាស់កំហាប់ដែលងាយស្រួលអាន
- JDG11684 DEF Refractometer—ឧបករណ៍ជំនួសដែលមានតម្លៃទាប ផ្តល់អំណានដែលស្រដៀងគ្នាមួយ

អនុវត្តតាមសេចក្តីណែនាំ ដោយរួមបញ្ចូលជាមួយឧបករណ៍ណាមួយដើម្បីទទួលបានរង្វាស់។

កំហាប់ DEF ដែលត្រឹមត្រូវ គឺមានអ៊ុយរ៉ែ 31.8—33.2%។ ប្រសិនបើកំហាប់ DEF មិនស្ថិតនៅក្នុងលក្ខណៈពិសេសនេះទេនោះ បង្ហូរ DEF ចេញពីអាង បាញ់ទឹកដែលត្រូវបានចម្រាញ់ និងបំពេញវាជាមួយ DEF ថ្មី ឬល្អ។ ប្រសិនបើ DEF ដែលត្រូវបានវេចខ្ចប់ មិនស្ថិតនៅក្នុងលក្ខណៈពិសេសនេះ បោះចោលកញ្ចប់ DEF និងជំនួសវាដោយ DEF ថ្មី ឬល្អ។

DX,DEF,TEST-KM-13JUN13-1/1

ការរក្សាទុក Diesel Exhaust Fluid (DEF)

⚠ ប្រយ័ត្ន៖ ចូរប្រយ័ត្នក្រែងលោប៉ះត្នែក។ ក្នុងករណីមានការប៉ះពាល់ ជាញឹកញាប់ចំនួនច្រើនចូលក្នុងត្នែកភ្លាមៗ ក្នុងរយៈពេលយ៉ាងតិច 15 នាទី។ ដើម្បីជ្រាបនូវព័ត៌មានបន្ថែម សូមអានតារាងទិន្នន័យសុវត្ថិភាពសម្ភារៈ (MSDS)។

ចូរកុំលេប DEF ចូល។ ក្នុងករណីបានលេប DEF ចូលក្នុងពោះ ចូរទៅរកគ្រូពេទ្យជាបន្ទាន់។ ដើម្បីជ្រាបនូវព័ត៌មានបន្ថែម សូមអានតារាងទិន្នន័យសុវត្ថិភាពសម្ភារៈ (MSDS)។

សំខាន់៖ វាជារឿងមិនត្រឹមត្រូវដែលលោកអ្នកគោះឬដោះសមាសភាពប្រព័ន្ធប្រព្រឹត្តិកម្មណាមួយ។ ចូរកុំប្រើប្រាស់ DEF ដែលមិនបំពេញតាមលក្ខណៈពិសេសដែលបានតម្រូវ ឬធ្វើប្រតិបត្តិការម៉ាស៊ីនដោយគ្មាន DEF។

ចូរកុំមានបំណងបង្កើត DEF ដោយលាយកម្រិតអ៊ុយរេនៅក្នុងផ្នែកកសិកម្មជាមួយទឹក។ កម្រិតអ៊ុយរេនៅក្នុងផ្នែកកសិកម្មមិនបំពេញតាមលក្ខណៈពិសេសចាំបាច់នោះទេ និងអាចធ្វើឲ្យប្រព័ន្ធក្រោយប្រព្រឹត្តកម្មមានការខូចខាត។

ចូរកុំបន្ថែមសារធាតុគីមី ឬសារធាតុបន្ថែមចូលទៅក្នុង DEF ដើម្បីទប់ស្កាត់ការកក។ សារធាតុគីមី ឬសារធាតុបន្ថែមណាមួយដែលត្រូវបានបន្ថែមទៅក្នុង DEF អាចធ្វើឲ្យប្រព័ន្ធក្រោយប្រព្រឹត្តកម្មមានការខូចខាត។

ចូរកុំបន្ថែមទឹក ឬសារធាតុរាវណាមួយផ្សេងទៀតជំនួសឲ្យ ឬបន្ថែមពីលើ DEF។ ការធ្វើប្រតិបត្តិការជាមួយ DEF ដែលបានកែប្រែ ឬការប្រើប្រាស់ DEF ដែលមិនទទួលបានការឯកភាព អាចធ្វើឲ្យប្រព័ន្ធក្រោយប្រព្រឹត្តកម្មមានការខូចខាត។

ព័ត៌មានស្តីពីការទុកដាក់ដែលមានផ្តល់ជូនខាងក្រោមគឺសម្រាប់ជាឯកសារយោង និងប្រើជាការណែនាំប៉ុណ្ណោះ។

គេចូលចិត្តរក្សាទុក DEF នៅកន្លែងដែលគ្មានសីតុណ្ហភាពជុំវិញខ្ពស់ពេក ឬទាបពេក។ DEF កកនៅសីតុណ្ហភាព –11°C (12°F)។ ការទទួលរងសីតុណ្ហភាពខ្ពស់ជាង 30°C (86°F) អាចកាត់បន្ថយ DEF ជាបន្តបន្ទាប់។ កុំទុក DEF ក្នុងពន្លឺព្រះអាទិត្យដោយផ្ទាល់។

ប្រដាប់រក្សាទុក DEF ដែលត្រូវបានផ្តល់ជូនត្រូវតែបានបិទជិតនៅចន្លោះពេលប្រើប្រាស់ដើម្បីបង្ការរំហួត និងការបំពុល។ ប្រដាប់ដាក់ដែលត្រូវបានធ្វើឡើងពីប៉ូលីអេទីឡែន ប៉ូលីប្រូពីឡែន ឬដែកអ៊ីណុក ត្រូវបានណែនាំឲ្យប្រើប្រាស់ដើម្បីដឹកជញ្ជូន និងរក្សាទុក DEF។

លក្ខខណ្ឌល្អបំផុតសម្រាប់ការរក្សាទុក DEF គឺ៖
- រក្សាទុកនៅក្នុងសីតុណ្ហភាពចន្លោះពី –5 °C ទៅ 30 °C (ពី 23 °F ទៅ 86 °F)
- រក្សាទុកនៅក្នុងប្រដាប់ដាក់ត្រូវបានប្រគល់ជូន និងត្រូវបានបិទជិតដើម្បីជៀសវាងការបំពុល និងរំហួត។

នៅក្នុងស្ថានភាពទាំងនេះ DEF ត្រូវបានរំពឹងទុកថានឹងនៅតែអាចប្រើប្រាស់បានក្នុងរយៈពេលយ៉ាងតិច 18 ខែ។ ការរក្សា DEF ទុកក្នុងសីតុណ្ហភាពខ្ពស់ជាងនេះអាចកាត់បន្ថយអាយុកាលសំខាន់របស់វាមកត្រឹមរយៈពេលប្រហែល 6 ខែ សម្រាប់រាល់សីតុណ្ហភាព 5°C (9°F) លើ 30°C (86°F)។

ប្រសិនបើមិនច្បាស់អំពីរយៈពេល និងលក្ខខណ្ឌដែល DEF ត្រូវបានរក្សាទុកទេនោះ ចូរធ្វើតេស្ត DEF។ ចូរមើលការធ្វើតេស្តសារធាតុរាវនៅក្នុងបំពង់ស៊ីមុំងដែលប្រើប្រេងម៉ាស៊ូត (Diesel Exhaust Fluid (DEF))។

ការរក្សាទុកក្នុងអាង DEF ក្នុងរយៈពេលវែង (លើសពី 12 ខែ) មិនត្រូវបានណែនាំនោះទេ។ ប្រសិនបើចាំបាច់ត្រូវរក្សាទុកក្នុងរយៈពេលវែង ចូរធ្វើតេស្ត DEF មុនពេលធ្វើប្រតិបត្តិការម៉ាស៊ីន។ ចូរមើលការធ្វើតេស្តសារធាតុរាវនៅក្នុងបំពង់ស៊ីមុំងដែលប្រើប្រេងម៉ាស៊ូត (Diesel Exhaust Fluid (DEF))។

គេបានណែនាំឲ្យទិញ DEF ក្នុងបរិមាណដែលនឹងត្រូវប្រើប្រាស់ក្នុងរយៈពេល 12 ខែ។

DX,DEF,STORE-KM-15JUL20-1/1

ចាក់បំពេញអាងសារធាតុរាវបំពង់ស៊ីមុំងម៉ាស៊ូត (DEF) ឡើងវិញ

តទៅទំព័របន្ទាប់

DX,DEF,REFILL-KM-15JUL20-1/2

⚠ ប្រយ័ត្ន៖ ចូរប្រយ័ត្នក្រែងលោប៉ះភ្នែក។ ក្នុងករណីមានការប៉ះពាល់ ជាញឹកញាប់ក្នុងចំនួនច្រើនចូលក្នុងភ្នែកភ្លាមៗ ក្នុងរយៈពេលយ៉ាងតិច 15 នាទី។ ដើម្បីជ្រាបនូវព័ត៌មានបន្ថែម សូមអានតារាងទិន្នន័យសុវត្ថិភាពសម្ភារៈ (MSDS)។

ចូរកុំលេប DEF ចូល។ ក្នុងករណីបានលេប DEF ចូលក្នុងពោះ ចូរទៅរកគ្រូពេទ្យជាបន្ទាន់។ ដើម្បីជ្រាបនូវព័ត៌មានបន្ថែម សូមអានតារាងទិន្នន័យសុវត្ថិភាពសម្ភារៈ (MSDS)។

សំខាន់៖ ប្រើប្រាស់តែទឹកដែលបានចម្រាញ់ដើម្បីលាងសម្អាតសមាសធាតុដែលត្រូវបានប្រើប្រាស់ដើម្បីបញ្ជូន DEF តែប៉ុណ្ណោះ។ ទឹកម៉ាស៊ីនអាចបំពុល DEF។ ប្រសិនបើគ្មានទឹកដែលបានចម្រាញ់ទេនោះ លាងជាមួយទឹកម៉ាស៊ីនស្អាត បន្ទាប់មកលាងឲ្យបានជ័តជល់ដោយប្រើ DEF ក្នុងបរិមាណច្រើន។

ប្រសិនបើ DEF កំពប់ ឬប៉ះពាល់ផ្ទៃណាមួយក្រៅពីធុងស្តុក ចូរលាងសម្អាតផ្ទៃនោះភ្លាមៗដោយប្រើទឹកផ្លាវ។ DEF ធ្វើឲ្យផ្ទៃលោហធាតុដែលបានលាបថ្នាំពណ៌ និងមិនបានលាបថ្នាំពណ៌ច្រេះ និងអាចបំផ្លាញរូបរាងដើមរបស់សមាសធាតុផ្លាស្ទិច និងជ័រមួយចំនួន។

ប្រសិនបើ DEF ត្រូវបានបំពេញនៅក្នុងអាងប្រេងម៉ាស៊ីន ឬធុងផ្ទុកសារធាតុរាវផ្សេងទៀត ចូរកុំធ្វើប្រតិបត្តិការម៉ាស៊ីនរហូតទាល់ប្រព័ន្ធត្រូវបានធ្វើវិសុទ្ធកម្ម DEF យ៉ាងត្រឹមត្រូវ។ ទាក់ទងភ្នាក់ងារចែកចាយ John Deere របស់អ្នកភ្លាមៗដើម្បីកំណត់អំពីរបៀបលាងសម្អាត និងធ្វើវិសុទ្ធកម្មប្រព័ន្ធ។

ការថែទាំសមស្របគួរត្រូវបានធ្វើឡើងនៅពេលបំពេញ DEF ចូលទៅក្នុងអាងវិញ។ ជានាថា ទីផ្លាកាប៊ីនអាង DEF គ្មានកម្តៅចកម្ចី មុនពេលយកកាប៊ីនចេញ។ បិទធុងដាក់ DEF នៅចន្លោះពេលប្រើប្រាស់ដើម្បីបង្ការការបំពុល និងរំហួត។

ជៀសវាងការសាច DEF និងកុំឲ្យ DEF ប៉ះស្បែក ភ្នែក ឬមាត់។

DEF ពុំមានគ្រោះថ្នាក់ក្នុងការចាត់ចែងនោះទេ ប៉ុន្តែ DEF អាចធ្វើឲ្យសម្ភារៈនានា ដូចជាដែក ធាតុដែក ស័ង្កសី នីកែល ទង់ដែង អាលុយមីញ៉ូម និងម៉ាញ៉េស្យូម ច្រេះបាន។ ប្រើប្រាស់ប្រដាប់ដាក់ដែលសមស្របដើម្បីដឹកជញ្ជូន និងរក្សាទុក



TS1731—UN—23AUG13

DEF។ ប្រដាប់ដាក់ដែលត្រូវបានធ្វើឡើងពីប៉ូលីអេទីឡែន ប៉ូលីប្រូពីឡែន ឬដែកអ៊ីណុក ត្រូវបានណែនាំឲ្យប្រើប្រាស់។

ជៀសវាងការប៉ះពាល់ជាមួយស្បែកក្នុងរយៈពេលវែង។ ក្នុងករណីមានការប៉ះពាល់ដោយអចេតនា លាងស្បែកដោយសាប៊ូសុសខ្លួយន និងទឹកភ្លាមៗ។

រក្សាវត្ថុណាមួយដែលត្រូវបានប្រើប្រាស់ដើម្បីរក្សាទុក ឬចែកចាយ DEF ឲ្យបានស្អាត និងគ្មានជ្រលក់។ លាង និងដុសលាងប្រដាប់ដាក់ ឬដងឡៅឲ្យបានជ័តជល់ដោយទឹកដែលត្រូវបានចម្រាញ់ដើម្បីកម្ចាត់សារធាតុបំពុលនានា។

ប្រសិនបើមានការបន្ថែមសារធាតុដែលទទួលបានការឯកភាពដូចជាប្រេងម៉ាស៊ូត ឬទឹកថ្នាំសុំម៉ាស៊ីន ចូលទៅក្នុងអាង DEF ទាក់ទងភ្នាក់ងារចែកចាយ John Deere របស់អ្នកភ្លាមៗដើម្បីកំណត់អំពីរបៀបលាងសម្អាត និងធ្វើវិសុទ្ធកម្មប្រព័ន្ធ។

ប្រសិនបើមានការបន្ថែមទឹកចូលទៅក្នុងអាង DEF ការលាងអាងគឺចាំបាច់។ ចូរមើលការលាងអាង DEF នៅក្នុងសៀវភៅណែនាំនេះ។ បន្ទាប់ពីបំពេញអាងឡើងវិញហើយ ត្រួតពិនិត្យកំហាប់ DEF។ ចូរមើលការធ្វើតេស្តសារធាតុរាវនៅក្នុងបំពង់ស៊ុមាំងដែលប្រើប្រេងម៉ាស៊ូត (Diesel Exhaust Fluid (DEF))។

ប្រតិបត្តិករត្រូវតែថែរក្សាកម្រិត DEF សមស្របនៅគ្រប់ពេលទាំងអស់។ ត្រួតពិនិត្យកម្រិត DEF ជារៀងរាល់ថ្ងៃ និងចាក់បំពេញធុងឡើងវិញតាមចាំបាច់។ ច្រកចាក់បំពេញត្រូវបានកំណត់ដោយគម្របពណ៌ខៀវដែលត្រូវបានបិទសញ្ញា DEF ដូចបានបង្ហាញ។

DX,DEF,REFILL-KM-15JUL20-2/2

ការចាក់ចោលសារធាតុរាវនៅក្នុងបំពង់ស៊ុមាំងដែលប្រើប្រេងម៉ាស៊ូត (Diesel Exhaust Fluid (DEF))

ទោះបីជាមានបញ្ហាតូចតាចចំពោះការកំពប់ DEF បន្តិចបន្តួចនៅលើដីក៏ដោយ ក៏គួរហាមឃាត់កុំឲ្យមានការកំពប់ DEF ក្នុងបរិមាណច្រើន។ ប្រសិនបើមានការកំពប់ក្នុងបរិមាណច្រើន ទាក់ទងអាជ្ញាធរនៃមជ្ឈដ្ឋានក្នុងមូលដ្ឋានដើម្បីទទួលបានជំនួយលើការលាងសម្អាត។

ប្រសិនបើ DEF ក្នុងបរិមាណច្រើនមិនស្ថិតនៅក្នុងលក្ខណៈពិសេស ចូរទាក់ទងអ្នកផ្គត់ផ្គង់ DEF ដើម្បីទទួលបានជំនួយក្នុងការចាក់ចោល។ ចូរកុំចាក់ចោល DEF ក្នុងបរិមាណច្រើននៅលើដី ឬបញ្ជូន DEF ទៅកាន់ទីតាំងប្រព្រឹត្តកម្មទឹកកខ្វក់។

DX,DEF,DISPOSE-KM-13JUN13-1/1

ទឹកស្ពំម៉ាស៊ីនម៉ាស៊ូត (ម៉ាស៊ីនដែលមានស្រោមទ្រនាប់ស៊ីឡាំង)

ការមិនអនុវត្តតាមស្តង់ដារទឹកថ្នាំស្ពំម៉ាស៊ីននិងចន្លោះពេលបង្ហូរអាចបណ្តាលឱ្យខូចម៉ាស៊ីនធ្ងន់ធ្ងរដែលអាចធ្វើឱ្យបាត់បង់ការធានា។ ការធានា ដែលរួមមានការធានារ៉ាប់រងលើការបំភាយឧស្ម័នគឺមិនមែនជាលក្ខខណ្ឌចំពោះការប្រើពពួកទឹកថ្នាំស្ពំម៉ាស៊ីន គ្រឿងបន្លាស់ ឬសេវាកម្ម របស់ក្រុមហ៊ុន John Deere ឡើយ។

ទឹកស្ពំម៉ាស៊ីនដែលគេនិយមប្រើ

គេនិយមប្រើទឹកស្ពំម៉ាស៊ីនដែលលាយជាមុនខាងក្រោមនេះ៖

- **John Deere Cool-Gard II**
- **John Deere Cool-Gard II PG**

ទឹកស្ពំម៉ាស៊ីនដែលលាយជាមុន Cool-Gard II មានកំហាប់ផ្សេងៗជាមួយនឹងកម្រិតនៃការការពារការកកផ្សេងៗគ្នា ដូចដែលបានបង្ហាញក្នុងតារាងខាងក្រោម។

Cool-Gard II លាយជាមុន	កម្រិតនៃការការពារការកក
Cool-Gard II 20/80	-9°C (16°F)
Cool-Gard II 30/70	-16°C (3°F)
Cool-Gard II 50/50	-37°C (-34°F)
Cool-Gard II 55/45	-45°C (-49°F)
Cool-Gard II PG 60/40	-49°C (-56°F)
Cool-Gard II 60/40	-52°C (-62°F)

មិនមានលក់ផលិតផលលាយជាមុន Cool-Gard II នៅគ្រប់ប្រទេសឡើយ។

ប្រើទឹកស្ពំម៉ាស៊ីន Cool-Gard II PG នៅពេលដែលគេតម្រូវឱ្យប្រើរូបមន្តទឹកថ្នាំស្ពំម៉ាស៊ីនដែលគ្មានជាតិពុល។

ទឹកស្ពំត្រជាក់ផ្សេងៗតាមការណែនាំ

ទឹកស្ពំម៉ាស៊ីនខាងក្រោមក៏ត្រូវបានណែនាំឱ្យប្រើប្រាស់ផងដែរ៖

- ទឹកស្ពំម៉ាស៊ីន Cool-Gard II របស់ John Deere លាយជាល្បាយដែលមានកំហាប់ពី 40 ទៅ 60% ជាមួយបរិមាណទឹក

សំខាន់៖ នៅពេលលាយកំហាប់ទឹកស្ពំម៉ាស៊ីនជាមួយទឹក កុំលាយកំហាប់ទឹកស្ពំម៉ាស៊ីនអោយតិចជាង 40% ឬលើសពី 60%។ ការលាយកំហាប់ទឹកស្ពំម៉ាស៊ីនតិចជាង 40% មិនអាចផ្តល់ឱ្យសារធាតុបន្ថែមជួយការពារពីច្រេះបានទេ។ ការលាយកំហាប់ទឹកស្ពំម៉ាស៊ីនលើសជាង 60% អាចបណ្តាលធ្វើឱ្យទឹកស្ពំម៉ាស៊ីនកក និងមានបញ្ហាដល់ប្រព័ន្ធបញ្ចុះកំដៅ។

ទឹកស្ពំម៉ាស៊ីនត្រជាក់ផ្សេងៗ

ទឹកស្ពំម៉ាស៊ីនផ្សេងទៀតប្រភេទអេទីឡែនគ្លីកូល និងប្រភេទប្រូពីឡែនគ្លីកូល អាចត្រូវបានប្រើប្រាស់ ប្រសិនបើវាបំពេញនូវលក្ខណៈបច្ចេកទេសដូចខាងក្រោម:

- ទឹកស្ពំម៉ាស៊ីនដែលលាយជាមុន ដែលបំពេញនូវលក្ខខណ្ឌចាំបាច់របស់ ASTM D6210
- ត្រូវបានផ្សំរួបមន្តជាមួយនឹងកញ្ចប់សារធាតុបន្ថែមដែលគ្មានសារធាតុនីត្រីត
- កំហាប់ទឹកស្ពំម៉ាស៊ីនដែលបំពេញនូវលក្ខខណ្ឌចាំបាច់របស់ ASTM6210 នៅក្នុងល្បាយដែលមានកំហាប់ 40-60% ជាមួយទឹក

ប្រសិនបើទឹកស្ពំម៉ាស៊ីនមិនបំពេញលក្ខណៈបច្ចេកទេសមួយនៃលក្ខណៈបច្ចេកទេសទាំងឡាយ សូមប្រើកំហាប់ទឹកស្ពំម៉ាស៊ីន ឬទឹកស្ពំម៉ាស៊ីនដែលលាយជាមុន ដែលមានលក្ខណៈរូប និងលក្ខណៈគីមី អប្បរមាដូចខាងក្រោម៖

- ផ្តល់ការការពារស្ពាមខូងនៅលើទ្រនាប់ស៊ីឡាំងយោងទៅតាមវិធីធ្វើតេស្តស្ពាមខូងឬ ការសិក្សាដ៏ឆាប់រហ័សរបស់ John Deere ដែលដំណើរការនៅសមត្ថភាពផ្តកស្មើ ឬលើស 60%
- ត្រូវបានផ្សំរួបមន្តជាមួយនឹងកញ្ចប់សារធាតុបន្ថែមដែលគ្មានសារធាតុនីត្រីត
- ត្រូវបានផ្សំរួបមន្តជាមួយនឹងកញ្ចប់សារធាតុបន្ថែមដែលគ្មានសារធាតុនីត្រីត
- ការពារលោហៈប្រព័ន្ធបន្តុយកម្តៅ (ដែកស៊ុត សំលោហៈអាលុយមីញ៉ូម និងសំលោហៈស្ពានលាយស័ង្កសីដូចជា ទង់ដែង) ពីការកាត់ស៊ុ

គុណភាពទឹក

គុណភាពទឹកមានសារៈសំខាន់ចំពោះការអនុវត្តការងាររបស់ប្រព័ន្ធបន្តុយកម្តៅ។ គួរប្រើប្រាស់ទឹកចម្រាញ់បំបាត់អ៊ីយ៉ុងឬបំបាត់ជាតិខណិច សម្រាប់លាយជាមួយកំហាប់ទឹកថ្នាំស្ពំម៉ាស៊ីនបាសអេទីឡែនគ្លីកុល និងប្រូពីឡែនគ្លីកុល។

ចន្លោះពេលបង្ហូរទឹកស្ពំម៉ាស៊ីន

បង្ហូរ និងលាងប្រព័ន្ធបញ្ចុះកំដៅ និងចាក់បំពេញទឹកស្ពំម៉ាស៊ីនថ្មីចូល នៅក្នុងចន្លោះដែលបានកំណត់ ដែលប្រែប្រួលជាមួយនឹងទឹកស្ពំម៉ាស៊ីនដែលបានប្រើ។

នៅពេលប្រើប្រាស់ទឹកស្ពំម៉ាស៊ីន Cool-Gard II ឬ Cool-Gard II PG ចន្លោះពេលបង្ហូរចេញគឺមានរយៈពេល 6 ឆ្នាំ ឬ 6000 ម៉ោងប្រតិបត្តិការ។

នៅពេលប្រើប្រាស់ទឹកស្ពំម៉ាស៊ីនផ្សេងទៀតក្រៅពី Cool-Gard II ឬ Cool-Gard II PG ចន្លោះពេលបង្ហូរចេញគឺមានរយៈពេល 2 ឆ្នាំ ឬ 2000 ម៉ោងប្រតិបត្តិការ[1]

សំខាន់៖ កុំប្រើសារធាតុបន្ថែមសម្រាប់ភ្ជិតប្រព័ន្ធបន្តុយកម្តៅ ឬសារធាតុប្រឆាំងនឹងការកក ដែលផ្តកសារធាតុបន្ថែមភ្ជិត។

កុំលាយទឹកស្ពំសអេទីឡែនគ្លីកុល និងប្រូពីឡែនគ្លីកុល។

កុំប្រើធាតុជាក់ដែលផ្តកសារធាតុនីត្រីត។

[1] ការវិភាគទឹកថ្នាំស្ពំម៉ាស៊ីនអាចពន្យារយៈពេលសេវាថែទាំ "ទឹកថ្នាំស្ពំម៉ាស៊ីន" ផ្សេងទៀតរហូតដល់កម្រិតអតិបរមាមិនលើសពីបរិមាណនៃទឹកថ្នាំស្ពំម៉ាស៊ីន *Cool-Gard II* ឡើយ។ ការវិភាគទឹកថ្នាំស្ពំម៉ាស៊ីនមានន័យថាការយកគំរូទឹកថ្នាំស្ពំម៉ាស៊ីនជាបន្តបន្ទាប់ក្នុងរយៈពេល *1000* ម៉ោងលើសពីចន្លោះសេវាកម្មធម្មតារហូតដល់ទិន្នន័យបង្ហាញថាបញ្ចប់នៃជីវិតទឹកថ្នាំស្ពំម៉ាស៊ីនដែលមានប្រយោជន៍ឬឈានដល់កម្រិតអតិបរិមានៃសេវាថែទាំទឹកថ្នាំស្ពំម៉ាស៊ីន *Cool Gardard*។

DX,COOL3(T)-KM-04APR22-1/1

ធាតុបន្ថែមលើទឹកស្អុំម៉ាស៊ីន Cool-Gard II របស់ John Deere

ធាតុបន្ថែមលើទឹកស្អុំម៉ាស៊ីនខ្លះបាត់បង់បន្តិចម្តងៗអំឡុងពេលដំណើរការម៉ាស៊ីន។ សម្រាប់កំហាប់ Cool-Gard II និង Cool-Gard II ដែលលាយជាមុន បន្ថែមសារធាតុបន្ថែមលើសារធាតុធ្វើឲ្យត្រជាក់ រវាងចន្លោះពេលនៃការបង្ហូរដោយបន្ថែមសារធាតុបន្ថែមលើសារធាតុធ្វើឲ្យត្រជាក់ COOL-GARD II

ធាតុបន្ថែមលើទឹកស្អុំម៉ាស៊ីន COOL-GARD II Coolant Extender មិនគួរបន្ថែមនោះទេ លុះត្រាតែត្រូវបានបញ្ជាក់ដោយបន្ទះធ្វើតេស្ត COOL-GARD II។ បន្ទះធ្វើតេស្តទាំងនេះផ្តល់នូវវិធីសាស្ត្រសាមញ្ញ និងមានប្រសិទ្ធភាព ដើម្បីត្រួតពិនិត្យមើលពីចំនុចកក កម្រិតសារធាតុបន្ថែម និងpHរបស់ទឹកស្អុំម៉ាស៊ីនរបស់អ្នក។

ធ្វើតេស្តសូលុយស្យុងទឹកស្អុំម៉ាស៊ីននៅចន្លោះពេល 12ខែ និងរៀងរាល់ពេលណាក៏ដោយដែលទឹកស្អុំម៉ាស៊ីនជាច្រើនត្រូវបានបាត់បង់ដោយសារការលេចជ្រាប និងការកើនកំដៅហួស។

សំខាន់៖ កុំប្រើបន្ទះធ្វើតេស្ត COOL-GARD II ជាមួយនឹងសារធាតុធ្វើឲ្យត្រជាក់ COOL-GARD PG។

ធាតុបន្ថែមលើទឹកស្អុំម៉ាស៊ីន Cool-Gard II Coolant Extender ជាប្រព័ន្ធបន្ថែមត្រូវគ្នាតាមលក្ខណៈគីមីសម្រាប់ប្រើជាមួយទឹកស្អុំម៉ាស៊ីន Cool-Gard II។ ធាតុបន្ថែមលើទឹកស្អុំម៉ាស៊ីន Cool-Gard II Coolant Extender មិនមានគោលបំណងប្រើជាមួយទឹកស្អុំម៉ាស៊ីនដែលមានជាតិនីត្រីតទេ។

សំខាន់៖ មិនត្រូវប្រើសារធាតុបន្ថែមលើទឹកស្អុំម៉ាស៊ីនដទៃទៀតនៅពេលដែលប្រព័ន្ធបញ្ចុះកំដៅត្រូវបានបង្ហូរចេញ និងចាក់បំពេញ ដែលមានលក្ខណៈណាមួយដូចខាងក្រោម៖

- **John Deere Cool-Gard II**
- **John Deere Cool-Gard II PG**

ការប្រើសារធាតុបន្ថែមលើទឹកស្អុំម៉ាស៊ីនដទៃទៀតដែលមិនបានណែនាំ អាចបណ្តាលឲ្យមានការមិនរលាយនៃសារធាតុបន្ថែមការកកនៃទឹកស្អុំម៉ាស៊ីន ឬការកើតច្រេះលើសមាសធាតុរបស់ប្រព័ន្ធបញ្ចុះកំដៅ។

បន្ថែមកំហាប់សារធាតុបន្ថែមលើទឹកស្អុំម៉ាស៊ីន Cool-Gard II Coolant Extender ដែលបានណែនាំ។ កុំប្រើឲ្យលើសពីបរិមាណដែលបានណែនាំ។

DX,COOL16(T)-KM-11APR22-1/1

ការដំណើរការក្នុងអាកាសធាតុក្តៅ

រាល់ម៉ាស៊ីន John Deereទាំងឡាយ ត្រូវបានរចនាឡើងដើម្បីដំណើរការដោយប្រើប្រាស់សារធាតុធ្វើឲ្យត្រជាក់ម៉ាស៊ីនដែលបានណែនាំ។

តែងតែប្រើប្រាស់ទឹកស្អុំម៉ាស៊ីនដែលបានណែនាំ ទោះបីជាដំណើរការនៅក្នុងតំបន់ភូមិសាស្ត្រដែលការការពារការកកមិនត្រូវទាមទារក៏ដោយ។

សំខាន់៖ *ទឹកអាចប្រើជាទឹកស្អុំម៉ាស៊ីនបាន*នៅក្នុងស្ថានភាពអាសន្នតែប៉ុណ្ណោះ។

ការកើតជាពពុះ ការច្រេះលើដែក និងអាលុយមីញ៉ូមនៅពេលផ្ទៃក្តៅ កើតជាក្រម និង ការសឹកអចរិលក្រហូង កើតមាននៅពេលគេប្រើទឹកជាទឹកស្អុំម៉ាស៊ីន ទោះបីជាសារធាតុសម្រួលទឹកស្អុំម៉ាស៊ីនត្រូវបានបន្ថែមក៏ដោយ។

បង្ហូរចេញពីប្រព័ន្ធបញ្ចុះកំដៅ និងបំពេញជាមួយនឹងទឹកស្អុំម៉ាស៊ីនដែលបានណែនាំភ្លាមៗដូចដែលអាចធ្វើបាន។

DX,COOL6-KM-15MAY13-1/1

គុណភាពទឹកសម្រាប់លាយជាមួយកំហាប់ទឹកថ្នាំស្អុំម៉ាស៊ីន

ទឹកថ្នាំស្អុំម៉ាស៊ីនគឺជាការរួមបញ្ចូលគ្នារវាងសមាសធាតុគីមីចំនួនបី៖ សារធាតុប្រឆាំងភាពកកអេទីឡែនគ្លីកូល (EG) ឬប្រូពីឡែនគ្លីកូល (PG) សារធាតុបន្ថែមការស្អុំដែលមានស្រាប់ និងទឹកដែលមានគុណភាព។

គុណភាពទឹកមានសារៈសំខាន់ចំពោះការអនុវត្តការងាររបស់ប្រព័ន្ធបន្ថយកម្តៅ។ គួរប្រើប្រាស់ទឹកចម្រាញ់បំបាត់អ៊ីយ៉ុង ឬបំបាត់ជាតិខណ្ឌិច សម្រាប់លាយជាមួយកំហាប់ទឹកថ្នាំស្អុំម៉ាស៊ីនបាសអេទីឡែនគ្លីកុល និងប្រូពីឡែនគ្លីកុល។

ទឹកទាំងអស់ដែលប្រើក្នុងប្រព័ន្ធបញ្ចុះកម្តៅគួរតែឆ្លើយតបតាមលក្ខណៈបច្ចេកទេសគុណភាពអប្បរមាដូចខាងក្រោម៖

ក្លរ៉ាយ	<40 mg/L
ស៊ុលហ្វាត	<100 mg/L
សារធាតុរឹងសរុប	<340 mg/L
ភាពរឹង ៖ រលាយក្នុងទឹកសរុប	<170 mg/L
pH	5.5—9.0

សំខាន់៖ ចូរកុំប្រើប្រាស់ទឹកពិសារទ្រកដប ពីព្រោះវាតែងតែមានកំហាប់ខ្ពស់ជាងសារធាតុរឹងដែលរលាយក្នុងទឹកសរុប។

ការការពារការកក

កំហាប់ធៀបនៃគ្លីកូល និងទឹកនៅក្នុងទឹកស្អុំម៉ាស៊ីនកំណត់កម្រិតការពារការកករបស់វា។

អេទីឡែនគ្លីកូល	កម្រិតនៃការការពារការកក
40%	-24°C (-12°F)
50%	-37°C (-34°F)
60%	-52°C (-62°F)
ប្រូពីឡែនគ្លីកូល	**កម្រិតនៃការការពារការកក**
40%	-21°C (-6°F)
50%	-33°C (-27°F)
60%	-49°C (-56°F)

កុំប្រើល្បាយទឹក និងទឹកស្អុំម៉ាស៊ីនដែលលើសពី 60% នៃអេទីឡែនគ្លីកូល និង 60% នៃប្រូពីឡែនគ្លីកូល។

DX,COOL19-KM-13JAN18-1/1

ការធ្វើតេស្តចំណុចកកកររបស់ទឹកថ្នាំស្ពាំម៉ាស៊ីន

DX,COOL,TEST(T)-KM-04APR22-1/2

ការប្រើប្រដាប់វាស់វត្ថុធាតុធន់នឹងកម្តៅទឹកថ្នាំស្ពាំម៉ាស៊ីនកាន់នឹងដៃ គឺជាវិធីសាស្ត្រលឿន ងាយស្រួល និងត្រឹមត្រូវបំផុតក្នុងការកំណត់ចំណុចកកកររបស់ទឹកថ្នាំស្ពាំម៉ាស៊ីន។ វិធីសាស្ត្រនេះមានលក្ខណៈត្រឹមត្រូវជាចម្រៀកតេស្ត ឬអ៊ីដ្រូម៉ែត្រប្រភេទអណ្តែតដែលអាចផ្តល់លទ្ធផលមិនសូវល្អ។

ប្រដាប់វាស់លំងាកកាំពន្លឺទឹកថ្នាំស្ពាំម៉ាស៊ីនរកបានតាមរយៈអ្នកចែកចាយ John Deere របស់អ្នក ដែលស្ថិតនៅក្រោមកម្មវិធីឧបករណ៍ SERVICEGARD ។ លេខគ្រឿងបន្លាស់ 75240 ផ្តល់នូវដំណោះស្រាយសន្សំសំចៃចំពោះការកំណត់ចំណុចកកត្រឹមត្រូវនៅក្នុងការដ្ឋាន។


ដើម្បីប្រើប្រាស់ឧបករណ៍នេះ៖

1. អនុញ្ញាតឲ្យប្រព័ន្ធបញ្ចេះកម្តៅធ្វើការបញ្ចេះកម្តៅសីតុណ្ហភាពជុំវិញ។
2. បើកកាប៊ីនធុងទឹកម៉ាស៊ីនដើម្បីបញ្ចេញទឹកថ្នាំស្ពាំម៉ាស៊ីន។
3. ដោយមានឧបករណ៍សម្រាប់បន្ថែកដែលបានរួមបញ្ចូលធ្វើការប្រមូលសំណាកទឹកថ្នាំស្ពាំម៉ាស៊ីនបន្តិចបន្តួច។
4. ចូរបើកគម្របប្រដាប់វាស់ ដាក់ទឹកថ្នាំស្ពាំម៉ាស៊ីនមួយតំណក់ទៅលើបង្ហួច ហើយបិទគម្រប។
5. មើលតាមរយៈវែនតាម ហើយផ្តោតតាមតែចាំបាច់។
6. កត់ត្រាចំណុចកកដែលបានរៀបរាប់សម្រាប់ប្រភេទទឹកថ្នាំស្ពាំម៉ាស៊ីន (ទឹកថ្នាំស្ពាំម៉ាស៊ីនអេទីឡែនគ្លីកូល ឬប្រូពីឡែនគ្លីកូល) ដែលបានធ្វើតេស្ត។



TS1732—UN—04SEP13

SERVICEGARD លេខគ្រឿងបន្លាស់ *75240*



TS1733—UN—04SEP13

រូបភាពជាមួយកំនក់នៃទឹកស្ពាំម៉ាស៊ីន *50/50* ដែលបានដាក់នៅលើរីនដូឧបករណ៍វាស់

DX,COOL,TEST(T)-KM-04APR22-2/2

ប្រេងម៉ាស៊ីនម៉ាស៊ូតដែលទើបប្រើថ្មី — គ្មានការភាយឧស្ម័ន ថ្នាក់ទី 1 ថ្នាក់ទី 2 ថ្នាក់ទី 3 ដំណាក់កាលទី I ដំណាក់កាលទី II និងដំណាក់កាលទី III

ម៉ាស៊ីនថ្មីត្រូវបានចាក់បំពេញប្រេងម៉ាស៊ីនពីរោងចក្រនូវប្រេង John Deere Break-In ឬ John Deere Break-In Plus។ នៅអំឡុងពេលប្រើប្រាស់ដំបូង សូមបន្ថែមប្រេងម៉ាស៊ីនម៉ាក John Deere Break-In ឬ Break-In Plus តាមតម្រូវការដើម្បីរក្សាកម្រិតប្រេងតាមលក្ខណៈបច្ចេកទេស។

ប្រតិបត្តិការម៉ាស៊ីនក្រោមលក្ខខណ្ឌផ្សេងៗ ជាពិសេសបន្តកន្ទុយ ជាមួយនឹងការការ៉ងទីម៉ាស៊ីនតិចតួចបំផុត ដើម្បីជួយឲ្យចូលសមាសភាគម៉ាស៊ីនបានត្រឹមត្រូវ។

ប្រសិនបើប្រើប្រេងម៉ាស៊ីនម៉ាក John Deere Break-In នៅអំឡុងពេលប្រតិបត្តិការដំបូងនៃម៉ាស៊ីនថ្មី ឬម៉ាស៊ីនដែលផ្តុំឡើងវិញ សូមប្តូរប្រេងម៉ាស៊ីន និងតម្រងប្រេងម៉ាស៊ីនក្នុងរយៈពេលអតិបរិមា 100 ម៉ោង។

ប្រសិនបើប្រើប្រាស់ប្រេងម៉ាស៊ីន John Deere Break-In ចូរប្តូរប្រេង និងតម្រងក្នុងអំឡុងពេលជាអប្បបរមាចំនួន 100 ម៉ោង និងជាអតិបរមាស្មើនឹងចន្លោះពេលដែលបានបញ្ជាក់សម្រាប់ប្រេង John Deere Plus-50 II ឬប្រេង Plus-50។

បន្ទាប់ពីរុះរើម៉ាស៊ីនរួចរាល់ហើយ ចូរចាក់បំពេញប្រេងម៉ាស៊ីន John Deere Break-In ឬ Break-In Plus។

ប្រសិនបើគ្មានប្រេងម៉ាស៊ីន John Deere Break-In ឬ John Deere Break-In Plus™ ទេនោះ ចូរប្រើប្រាស់ប្រេងម៉ាស៊ីនម៉ាស៊ូតដែលមានកម្រិតភាពអន្លិល SAE10W-30 ដែលបំពេញតាមចំណុចណាមួយដូចខាងក្រោម និងប្តូរប្រេង និងតម្រងក្នុងរយៈពេលជាអតិបរមាចំនួន 100 ម៉ោងនៃប្រតិបត្តិការ៖

- សេវា API ចំណាត់ថ្នាក់ CE
- សេវា API ចំណាត់ថ្នាក់ CD
- សេវា API ចំណាត់ថ្នាក់ CC
- សេវា ACEA ចំណាត់ថ្នាក់ E2
- ប្រេង ACEA លំដាប់ E1

សំខាន់៖ កុំប្រើប្រេងម៉ាស៊ុន Plus-50 II, Plus-50 ឬប្រេងម៉ាស៊ីនទាំងឡាយណាដែលត្រូវនឹងតម្រូវការណាមួយខាងក្រោម សម្រាប់ការប្រើប្រាស់ដំបូងនៃម៉ាស៊ីនថ្មី ឬម៉ាស៊ីនដែលទើបនឹងផ្តុំនឹងឡើងវិញ៖

API CK-4	**ACEA E9**
API CJ-4	**ACEA E7**
API CI-4 PLUS	**ACEA E6**
API CI-4	**ACEA E5**
API CH-4	**ACEA E4**
API CG-4	**ACEA E3**
API CF-4	
API CF-2	
API CF	

ប្រេងម៉ាស៊ីនទាំងនេះ មិនអនុញ្ញាតឲ្យម៉ាស៊ីនប្រើប្រាស់ដំបូងបានត្រឹមត្រូវទេ។

ប្រេងម៉ាស៊ីនម៉ាក John Deere Break-In Plus អាចប្រើប្រាស់សម្រាប់ប្រេងម៉ាស៊ីនម៉ាស៊ូតទាំងអស់របស់ John Deere នៅគ្រប់កម្រិតនៃការបញ្ចាក់អំពីការបំភាយឧស្ម័នទាំងអស់។

ក្រោយពេលចប់រយៈពេលប្រើប្រាស់ដំបូង សូមប្រើប្រេងម៉ាក John Deere Plus-50 II, John Deere Plus-50 ឬប្រេងម៉ាស៊ីនម៉ាស៊ូតផ្សេងទៀតតាមការណែនាំនៅក្នុងសៀវភៅណែនាំនេះ។

DX,ENOIL4(T)-KM-04APR22-1/1

ប្រេងម៉ាស៊ីន John Deere Break-In Plus — បណ្តោះអាសន្ន ថ្នាក់ទី 4, ចុងក្រោយ ថ្នាក់ទី 4, ដំណាក់កាលទី IIIB, IV និង V

ម៉ាស៊ីនថ្មីត្រូវបានចាក់ប្រេង John Deere Break-In Plus ពីរោងចក្រ។ នៅអំឡុងពេលប្រើប្រាស់ដំបូង សូមបន្ថែមប្រេងម៉ាស៊ីនម៉ាក John Deere Break-In Plus តាមតម្រូវការដើម្បីរក្សាកម្រិតប្រេងតាមលក្ខណៈបច្ចេកទេស។

ប្រតិបត្តិការម៉ាស៊ីនក្រោមលក្ខខណ្ឌផ្សេងៗ ជាពិសេសបន្តកន្ទុយ ជាមួយនឹងការការ៉ងទីម៉ាស៊ីនតិចតួចបំផុត ដើម្បីជួយឲ្យចូលសមាសភាគម៉ាស៊ីនបានត្រឹមត្រូវ។

ក្នុងអំឡុងពេលប្រតិបត្តិការដំបូងរបស់ម៉ាស៊ីនថ្មី ឬម៉ាស៊ីនដែលត្រូវបានបង្កើតឡើងវិញ ការផ្លាស់ប្តូរប្រេង និងតម្រងចន្លោះពេលជាអប្បបរមាចំនួន 100 ម៉ោង និងជាអតិបរមាស្មើនឹងចន្លោះពេលដែលត្រូវបានបញ្ជាក់សម្រាប់ប្រេង John Deere Plus-50™ II។

បន្ទាប់ពីរុះរើម៉ាស៊ីនរួចរាល់ហើយ ចូរចាក់ប្រេងម៉ាស៊ីន John Deere Break-In Plus Engine Oil។

ប្រសិនបើពុំអាចរកបានប្រេងម៉ាស៊ីនម៉ាក John Deere Break-In Plus ទេនោះ សូមប្រើប្រេងម៉ាស៊ីនម៉ាស៊ូតដែលមានកម្រិតស្ថិតអន្លិល SAE 10W-30 ដែលត្រូវតាមតម្រូវការណាមួយខាងក្រោម៖

- CK-4 ប្រភេទសេវា API
- សេវា API ប្រភេទ CJ-4
- ប្រេង ACEA លំដាប់ E9
- ប្រេង ACEA លំដាប់ E6

ប្រសិនបើប្រេងណាមួយក្នុងចំណោមប្រេងទាំងនេះត្រូវបានប្រើប្រាស់ក្នុងអំឡុងពេលប្រតិបត្តិការដំបូងរបស់ម៉ាស៊ីនថ្មី ឬម៉ាស៊ីនដែលត្រូវបានបង្កើតឡើងវិញ ចូរប្តូរប្រេង និងតម្រងក្នុងចន្លោះពេលជាអប្បបរមាចំនួន 100 ម៉ោង និងជាអតិបរមាចំនួន 250 ម៉ោង។

សំខាន់៖ ចូរកុំប្រើប្រាស់ប្រេងម៉ាស៊ីនណាមួយផ្សេងទៀតក្នុងអំឡុងពេលរដាស់ដំបូងរបស់ម៉ាស៊ីនថ្មី ឬម៉ាស៊ីនដែលត្រូវបានបង្កើតឡើងវិញ។

ប្រេងម៉ាស៊ីនម៉ាក John Deere Break-In Plus អាចប្រើប្រាស់សម្រាប់ប្រេងម៉ាស៊ីនម៉ាស៊ូតទាំងអស់របស់ John Deere នៅគ្រប់កម្រិតនៃការបញ្ចាក់អំពីការបំភាយឧស្ម័នទាំងអស់។

ក្រោយរយៈពេលរដាស់ ចូរប្រើប្រាស់ប្រេង John Deere Plus-50 II ឬប្រេងម៉ាស៊ីនម៉ាស៊ូតផ្សេងទៀតតាមការណែនាំនៅក្នុងសៀវភៅណែនាំនេះ។

DX,ENOIL16(T)-KM-05APR22-1/1

ប្រេងម៉ាស៊ីនម៉ាស៊ូតថ្នាក់ទី 2 និងដំណាក់កាល II

DX,ENOIL7(T)-KM-04APR22-1/2

ការមិនអនុវត្តតាមស្តង់ដារប្រេងនិងចន្លោះពេលបង្ហូរអាចបណ្តាលឱ្យខូចម៉ាស៊ីនធ្ងន់ធ្ងរដែលអាចធ្វើឱ្យបាត់បង់ការធានា។ ការធានា ដែលរួមមានការធានារ៉ាប់រងលើការបំភាយឧស្ម័នគឺមិនមែនជាលក្ខខណ្ឌចំពោះការប្រើពួកប្រេងម៉ាស៊ីនគ្រឿងបន្លាស់ ឬសេវាកម្ម របស់ក្រុមហ៊ុន John Deere ឡើយ។

ប្រើកម្រិតភាពស្អិតខាប់ដោយផ្អែកលើលំដាប់សីតុណ្ហភាពខ្យល់ដែលបានរំពឹងទុកនៅអំឡុងចន្លោះពេលនៃការផ្លាស់ប្តូរប្រេងម៉ាស៊ីនម្តងៗ។

ប្រេង John Deere Plus-50 II គឺជាប្រេងដែលគេនិយមប្រើ។

យកល្អគួរប្រើប្រេង John Deere Plus-50 ផងដែរ។


ប្រេង John Deere Torq-Gard ក៏អនុញ្ញាតឲ្យប្រើផងដែរ។

ប្រេងដទៃទៀតអាចប្រើបាន ប្រសិនបើឆ្លើយតាមបទដ្ឋានមួយឬច្រើនដូចខាងក្រោម៖

- CK-4 ប្រភេទសេវា API
- សេវា API ប្រភេទ CJ-4
- សេវា API ប្រភេទ CI-4 PLUS
- សេវា API ប្រភេទ CI-4
- សេវា API ប្រភេទ CH-4
- ប្រេង ACEA លំដាប់ E9
- ប្រេង ACEA លំដាប់ E7
- ប្រេង ACEA លំដាប់ E6
- ប្រេង ACEA លំដាប់ E5
- ប្រេង ACEA លំដាប់ E4

យកល្អគួរប្រើប្រេងម៉ាស៊ីនម៉ាស៊ូតដែលមានពហុកម្រិតភាពអន្ទិល។

គុណភាព និងចំណុះស្ពាន់ធ័ររបស់ប្រេងម៉ាស៊ូត ត្រូវតែអនុលោមតាមបទបញ្ជាត្បិបំភាយឧស្ម័នជាធរមានសម្រាប់តំបន់ដែលត្រូវម៉ាស៊ីនដំណើរការ។



កម្រិតរំអិលនៃប្រេងម៉ាស៊ីនសម្រាប់លំដាប់សីតុណ្ហភាពខ្យល់

សំខាន់៖ កុំប្រើប្រេងម៉ាស៊ូតដែលមានចំណុះស្ពាន់ធ័រធំជាង 10 000 មក្រ/គក្រ (10 000 ភាគក្នុងមួយលាន)។

DX,ENOIL7(T)-KM-04APR22-2/2

ប្រេងម៉ាស៊ីនម៉ាស៊ូត—បណ្តោះអាសន្ន ថ្នាក់ទី 4, ចុងក្រោយ ថ្នាក់ទី 4, ដំណាក់កាលទី IIIB ដំណាក់កាល IV និង ដំណាក់កាលទី V

តទៅទំព័របន្ទាប់

DX,ENOIL14(T)-KM-05APR22-1/2

ការមិនអនុវត្តតាមស្តង់ដារប្រេងនិងចន្លោះពេលបង្ហូរអាចបណ្តាលឱ្យខូចម៉ាស៊ីនធ្ងន់ធ្ងរដែលអាចធ្វើឱ្យបាត់បង់ការធានា។ ការធានា ដែលរួមមានការធានារ៉ាប់រងលើការបំភាយឧស្ម័នគឺមិនមែនជាលក្ខខណ្ឌចំពោះការប្រើពពួកប្រេងម៉ាស៊ីនគ្រឿងបន្លាស់ ឬសេវាកម្ម របស់ក្រុមហ៊ុន John Deere ឡើយ។

ប្រើកម្រិតភាពស្អិតខាប់ដោយផ្អែកលើលំដាប់សីតុណ្ហភាពខ្យល់ដែលបានរំពឹងទុកនៅអំឡុងចន្លោះពេលនៃការផ្លាស់ប្តូរប្រេងម៉ាស៊ីនម្តងៗ។

John Deere Plus-50 គឺជាប្រេងម៉ាស៊ីនដែលគួរប្រើ។

ចន្លោះពេលថែទាំដែលពន្យារអាចអនុវត្តបាននៅពេលប្រើប្រាស់ប្រេងម៉ាស៊ីន John Deere Plus-50 II។ សូមយោងដល់តារាងចន្លោះពេលបង្ហូរប្រេងម៉ាស៊ីន និងប្រឹក្សាជាមួយភ្នាក់ងារចែកចាយ John Deere របស់អ្នក សម្រាប់ព័ត៌មានបន្ថែម។


ប្រសិនបើមិនមានប្រេងម៉ាស៊ីន John Deere Plus-50 ទេនោះគេអាចប្រើប្រាស់ប្រេងម៉ាស៊ីនដែលបំពេញតាមចំណុចមួយ ឬច្រើនដូចខាងក្រោម៖

- CK-4 ប្រភេទសេវា API
- សេវា API ប្រភេទ CJ-4
- ប្រេង ACEA លំដាប់ E9
- ប្រេង ACEA លំដាប់ E6

ចូរកុំប្រើប្រាស់ប្រេងម៉ាស៊ីនដែលមានផេះស៊ុលហ្វាតលើសពី 1.0% ផ្ទុស្ងួរ .12% ឬស្ពាន់ធ័រ .4% ឡើយ។

យកល្អគួរប្រើប្រេងម៉ាស៊ីនម៉ាស៊ូតដែលមានពហុកម្រិតភាពអន្ទិល។

គុណភាព និងចំណុះស្ពាន់ធ័ររបស់ប្រេងម៉ាស៊ូត ត្រូវតែអនុលោមតាមបទបញ្ញត្តិបំភាយឧស្ម័នជាធរមានសម្រាប់តំបន់ដែលត្រូវម៉ាស៊ីនដំណើរការ។



កម្រិតរំអិលនៃប្រេងម៉ាស៊ីនសម្រាប់លំដាប់សីតុណ្ហភាពខ្យល់

សំខាន់៖ ចូរប្រើតែប្រេងម៉ាស៊ូតមានស្ពាន់ធ័រទាបខ្លាំង (ULSD) ដែលមានចំណុះស្ពាន់ធ័រអតិបរិមា 15 ម.ក/គ.ក (15 ppm) ប៉ុណ្ណោះ។

DX,ENOIL14(T)-KM-05APR22-2/2

ចន្លោះម៉ោងថែទាំប្រេងម៉ាស៊ូតសម្រាប់ការប្រើប្រាស់នៅរយៈកម្ពស់ខ្ពស់សម្រាប់ជាព័ត៌មានបន្ថែម

ដើម្បីជៀសវាងភាពចុះអន់ថយនៃប្រេងខ្លាំងពេក និងការខូចខាតជាសកានុពលចំពោះម៉ាស៊ីន ចូរកាត់បន្ថយចន្លោះម៉ោងថែទាំប្រេង និងតម្រងប្រេងមកត្រឹម 50% នៃតម្លៃដើមដែលត្រូវបានណែនាំ នៅពេលធ្វើប្រតិបត្តិការម៉ាស៊ីនដែលមានរយៈកម្ពស់លើស **1675 m (5500 ft)**។

ការវិភាគអំពីប្រេងអាចអនុញ្ញាតឱ្យមានចន្លោះម៉ោងថែទាំយូរជាងនេះ។

ប្រើប្រាស់តែប្រភេទប្រេងដែលបានអនុម័តប៉ុណ្ណោះ។

ឧទាហរណ៍នៃម៉ោងដើម	ម៉ោងនៃរយៈកម្ពស់ខ្ពស់ដែលពាក់ព័ន្ធគ្នា
125	60
150	75
175	85
200	100

ឧទាហរណ៍នៃម៉ោងដើម	ម៉ោងនៃរយៈកម្ពស់ខ្ពស់ដែលពាក់ព័ន្ធគ្នា
250	125
275	135
300	150
350	175
375	185
400	200
500	250

DX,ENOIL,SERV,HIALT-KM-11NOV14-1/1

ចន្លោះម៉ោងថែទាំប្រេងម៉ាស៊ីន និងតម្រងប្រេង — ម៉ាស៊ីនថ្នាក់ទី 2 និងដំណាក់កាលទី II

ចន្លោះម៉ោងថែទាំប្រេង និងតម្រងដែលត្រូវបានណែនាំ គឺផ្អែកលើការរួមបញ្ចូលគ្នារវាងចំណុះនៃធុងប្រេង ប្រភេទប្រេងម៉ាស៊ីន និងតម្រងដែលត្រូវបានប្រើប្រាស់ និងចំណុះស្ពាន់ធ័រនៃប្រេងម៉ាស៊ូត។ ចន្លោះម៉ោងថែទាំជាក់ស្តែងក៏ពឹងផ្អែកលើប្រតិបត្តិការ និងទម្លាប់អនុវត្តតំហែទាំផងដែរ។

ប្រភេទប្រេងដែលបានអនុម័ត:

- “ពពួកប្រេង Plus-50” រួមមាន John Deere Plus-50 II និង John Deere Plus-50
- “ពពួកប្រេងផ្សេងទៀត” រួមមាន John Deere Torq-Gard, API CK-4, API CJ-4, API CI-4 PLUS, API CI-4,API CH-4, ACEA E9, ACEA E7, ACEA E6, ACEA E5, និង ACEA E4។

ចូរប្រើការវិភាគប្រេងដើម្បីវាយតម្លៃ លក្ខខណ្ឌរបស់ប្រេងនិងដើម្បីជួយជ្រើសរើសប្រេង និងចន្លោះពេលផ្លាស់ថែទាំតម្រងឲ្យបានត្រឹមត្រូវ។ សម្រាប់ព័ត៌មានបន្ថែមស្តីពីការវិភាគប្រេងម៉ាស៊ីន សូមទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere ឬអ្នកផ្តល់សេវាកម្មដែលមានការអនុញ្ញាត។

ផ្លាស់ប្តូរប្រេង និងតម្រងប្រេងយ៉ាងតិចម្តងរៀងរាល់ 12 ខែ ទោះបីជាម៉ោងប្រតិបត្តិការតិចជាងចន្លោះម៉ោងថែទាំដែលបានណែនាំក៏ដោយ។

ចំណុះស្ពាន់ធ័រប្រេងម៉ាស៊ូត ប៉ះពាល់ដល់ចន្លោះម៉ោងថែទាំប្រេងម៉ាស៊ីន និងតម្រង។

- លោកអ្នកគួរតែប្រើប្រាស់ប្រេងម៉ាស៊ូតដែលមានផ្ទុកសារធាតុស្ពាន់ធ័រតិចជាង 2000 មីលីក្រាម / គីឡូក្រាម (2000 ppm)
- ការប្រើប្រាស់ប្រេងម៉ាស៊ូតដែលមានចំណុះស្ពាន់ធ័រ 2000—5000 មក្រ/គក្រ(2000—5000 ppm) កាត់បន្ថយចន្លោះពេលផ្លាស់ប្តូរប្រេងម៉ាស៊ីន និងតម្រងប្រេងម៉ាស៊ីន។
- មុននឹងប្រើប្រេងម៉ាស៊ូតដែលមានផ្ទុកសារធាតុស្ពាន់ធ័រច្រើនជាង 5000 មីលីក្រាម / គីឡូក្រាម (5000 ppm) សូមទាក់ទងអ្នកចែកចាយ John Deere របស់អ្នកឬអ្នកផ្តល់សេវាកម្មដែលមានការអនុញ្ញាត។

ចន្លោះម៉ោងថែទាំប្រេងម៉ាស៊ីន និងតម្រង	
ស្ពាន់ធ័រប្រេងឥន្ធនៈ:	តិចជាង 2000 មីលីក្រាម/គក្រ. (2000 ppm)
ប្រេង Plus-50	375 ម៉ោង
ប្រេងផ្សេងទៀត	250 ម៉ោង
ស្ពាន់ធ័រប្រេងឥន្ធនៈ:	2000—5000 មីលីក្រាម/គក្រ. (2000—5000 ppm)
ប្រេង Plus-50	275 ម៉ោង
ប្រេងផ្សេងទៀត	150 ម៉ោង
ស្ពាន់ធ័រប្រេងឥន្ធនៈ:	5000—10 000 មីលីក្រាម/គក្រ. (5000—10 000 ppm)
ប្រេង Plus-50	187 ម៉ោង (ជួបភ្នាក់ងារចែកចាយ John Deere)
ប្រេងផ្សេងទៀត	125 ម៉ោង (ជួបភ្នាក់ងារចែកចាយ John Deere)
ការវិភាគអំពីប្រេងអាចពន្យារចន្លោះម៉ោងថែទាំរបស់ “ប្រេងផ្សេងទៀត” រហូតដល់ចំនួនអតិបរមាដែលមិនលើសពីចន្លោះម៉ោងថែទាំសម្រាប់ប្រេង Plus-50 ឡើយ។ ការវិភាគអំពីប្រេងមានន័យថា ការយកសំរិនៃសំណាកប្រេងក្នុងពេល 50 ម៉ោងបង្ករ លើសពីចន្លោះពេលនៃការផ្តល់សេវាធម្មតា រហូតទាល់តែទិន្នន័យចង្អុលបង្ហាញអំពីការបញ្ចប់អាយុកាលប្រេងមានប្រយោជន៍ឬបានឈានដល់ចន្លោះម៉ោងថែទាំអតិបរមារបស់ប្រេង John Deere Plus-50។	

សំខាន់៖ ដើម្បីជៀសវាងការខូចខាតដល់ម៉ាស៊ីន៖

- **កាត់បន្ថយចន្លោះម៉ោងថែទាំប្រេង និងតម្រងត្រឹម 50% នៅពេលប្រើប្រាស់ការរួមបញ្ចូលគ្នានៃជីវម៉ាស៊ូតលើសពី B20**
- **ការវិភាគប្រេងអាចនឹងអនុញ្ញាតឱ្យមានចន្លោះសេវាកម្មយូរជាងនេះ**
- **ប្រើតែប្រភេទប្រេងដែលបានអនុញ្ញាតឲ្យប្រើប៉ុណ្ណោះ**

DX,ENOIL12,T2,STD(T)-KM-08APR22-1/1

ចន្លោះម៉ោងថែទាំប្រេងម៉ាស៊ីន និងតម្រង — ម៉ាស៊ីន ថ្នាក់ទី 4 បណ្តោះអាសន្ន ថ្នាក់ទី 4 ចុងក្រោយ ដំណាក់កាលទី III B ដំណាក់កាល IV និងដំណាក់កាល V

ការមិនអនុវត្តតាមស្តង់ដារប្រេងនិងចន្លោះពេលបង្ហូរអាចបណ្តាលឱ្យខូចម៉ាស៊ីនធ្ងន់ធ្ងរដែលអាចធ្វើឱ្យបាត់បង់ការធានា។ ការធានា ដែលរួមមានការធានារ៉ាប់រងលើការបំភាយឧស្ម័នគឺមិនមែនជាលក្ខខណ្ឌចំពោះការប្រើពពួកប្រេងម៉ាស៊ីនគ្រឿងបន្លាស់ ឬសេវាកម្ម របស់ក្រុមហ៊ុន John Deere ឡើយ។

ចន្លោះម៉ោងថែទាំប្រេង និងតម្រងដែលត្រូវបានណែនាំ គឺផ្អែកលើការរួមបញ្ចូលគ្នារវាងចំណុះនៃធុងប្រេង ប្រភេទប្រេងម៉ាស៊ីន និងតម្រងដែលត្រូវបានប្រើប្រាស់ និងចំណុះស្តង់ដារនៃប្រេងម៉ាស៊ូត។ ចន្លោះម៉ោងថែទាំជាក់ស្តែងក៏ពឹងផ្អែកលើប្រតិបត្តិការ និងទម្លាប់អនុវត្តតំហែទាំផងដែរ។

ប្រភេទប្រេងដែលបានអនុញ្ញាតឲ្យប្រើ

- John Deere Plus-50 II
- “ពពួកប្រេងផ្សេងទៀត” រួមមាន API CK-4, API CJ-4, ACEA E9, and ACEA E6

ចូរប្រើការវិភាគប្រេងដើម្បីវាយតម្លៃ លក្ខខណ្ឌរបស់ប្រេងនិងដើម្បីជួយជ្រើសរើសប្រេង និងចន្លោះពេលផ្លាស់សេវាថែទាំតម្រងឲ្យបានត្រឹមត្រូវ។ សម្រាប់ព័ត៌មានបន្ថែមស្តីពីការវិភាគប្រេងម៉ាស៊ីន សូមទាក់ទងអ្នកចែកចាយក្រុមហ៊ុន John Deere ឬអ្នកផ្តល់សេវាកម្មដែលមានការអនុញ្ញាត។

ផ្លាស់ប្តូរប្រេង និងតម្រងប្រេងយ៉ាងតិចម្តងរៀងរាល់ 12 ខែ ទោះបីជាម៉ោងប្រតិបត្តិការតិចជាងចន្លោះម៉ោងថែទាំដែលបានណែនាំក៏ដោយ។

ចំណុះស្តង់ដារប្រេងម៉ាស៊ូត ប៉ះពាល់ដល់ចន្លោះម៉ោងថែទាំប្រេងម៉ាស៊ីន និងតម្រង។ កម្រិតស្តង់ដារប្រេងឥន្ធនៈខ្ពស់ជាងកាត់បន្ថយចន្លោះម៉ោងថែទាំប្រេងម៉ាស៊ីន និងតម្រង។

សំខាន់៖ ការប្រើប្រាស់ប្រេងម៉ាស៊ូតដែលមានចំណុះស្តង់ដារតិចជាង 15 ម.ក/គ.ក (15 ppm) គឺត្រូវបានតម្រូវ។

ការប្រើប្រាស់ម៉ាស៊ីននៅរយៈកម្ពស់ខ្ពស់ បន្ថយចន្លោះពេលផ្លាស់ប្តូរប្រេង។ ចូរមើលចន្លោះពេលថែទាំប្រេងម៉ាស៊ូតសម្រាប់ការប្រើប្រាស់នៅរយៈកម្ពស់ខ្ពស់សម្រាប់ជាព័ត៌មានបន្ថែម។

ចន្លោះម៉ោងថែទាំប្រេងម៉ាស៊ីន និងតម្រង	
John Deere Plus-50 II	400 ម៉ោង
ប្រេងផ្សេងទៀត	250 ម៉ោង
ការវិភាគអំពីប្រេងអាចពន្យារចន្លោះពេលថែទាំ “ប្រេងផ្សេងទៀត” ជាអតិបរមាដោយមិនឲ្យលើសពីចន្លោះពេលថែទាំរបស់ប្រេង Plus-50 II។ ការវិភាគអំពីប្រេងមានន័យថាការយកសំណាកស៊េរីប្រេងដែលបានបង្ហូរក្នុងរយៈពេល 50 ម៉ោងលើសពីចន្លោះពេលថែទាំធម្មតា រហូតដល់ទិន្នន័យបង្ហាញថា បានឈានដល់ចំណុចចុងក្រោយនៃជីវិតប្រេងដែលមានប្រយោជន៍ ឬចន្លោះពេលនៃសេវាកម្មអតិបរមារបស់ប្រេង John Deere Plus-50 II។	

សំខាន់៖ ដើម្បីជៀសវាងការខូចខាតដល់ម៉ាស៊ីន៖

- **កាត់បន្ថយចន្លោះម៉ោងថែទាំប្រេង និងតម្រងត្រឹម 50% នៅពេលប្រើប្រាស់ការរួមបញ្ចូលគ្នានៃជីវម៉ាស៊ូតលើសពី B20**
- **ការវិភាគប្រេងអាចនឹងអនុញ្ញាតឱ្យមានចន្លោះសេវាកម្មយូរជាងនេះ**
- **ប្រើតែប្រភេទប្រេងដែលបានអនុញ្ញាតឲ្យប្រើប៉ុណ្ណោះ**

OUO6075,1683581426282-KM-08MAY23-1/1

Oilscan និង CoolScan


តទៅទំព័របន្ទាប់

DX,OILSCAN(T)-KM-06APR22-1/2


Oilscan និង CoolScan គឺជាកម្មវិធីយកសំណាកដើម្បីជួយអ្នកតាមដានមើលប្រសិទ្ធិភាពបំពេញមុខងារ របស់គ្រឿងចក្រ និងកំណត់បញ្ហាដែលអាចនឹងកើតឡើងមុនពេលដែលពួកវាអាចបង្កឲ្យមានការខូចខាតធ្ងន់ធ្ងរ។

សំណាកប្រេងម៉ាស៊ីន និងទឹកស្អំម៉ាស៊ីនត្រូវបានយកចេញពីគ្រឿងចក្រនីមួយៗមុនចន្លោះពេលផ្លាស់ប្តូរតាមការណែនាំ។

ពិគ្រោះជាមួយអ្នកចែកចាយ John Deere របស់អ្នកអំពីលទ្ធភាពរកបាននូវកញ្ចប់ Oilscan និង CoolScan ។



T6828AB—UN—15JUN89



T6829AB—UN—26AUG11

DX,OILSCAN(T)-KM-06APR22-2/2

ប្រអប់លេខ ProDrive, ដុំអូសទាញមាត់ច្រកបួងចូលពហុល្បឿន CommandTouch, ប្រព័ន្ធអូសទាញអ៊ុជ្រូស្តាទិក, ប្រព័ន្ធអ៊ុជ្រូលីកមេ និងប្រេងប្រអប់ស្តីម៉ាស៊ីនមេ

OUO6075,1683582120123-KM-13JUN23-1/2


កំណត់ចំណាំ៖ គ្រឿងចក្រដឹកចេញពីរោងចក្រដោយចាក់ប្រេង *John Deere Hy-Gard* ។

មានតែប្រេងដូចខាងក្រោមប៉ុណ្ណោះដែលអនុញ្ញាតឲ្យប្រើ៖

- John Deere HY-GARD
- ប្រេងដែលឆ្លើយតបនឹង John Deere Standard JDM J20C

កំណត់ចំណាំ៖ សម្រាប់ប្រើប្រាស់ក្នុងសីតុណ្ហភាពត្រជាក់ខ្លាំង, មានតែប្រេងដូចតទៅនេះប៉ុណ្ណោះដែលអាចប្រើជំនួសបាន៖

- *Low Viscosity Hy-Gard*
- ប្រេងដែលឆ្លើយតបនឹង *John Deere Standard JDM J20D*



ZX1030848—UN—15SEP02

OUO6075,1683582120123-KM-13JUN23-2/2

ប្រអប់លេខ (ការបូរដោយមេកានិច និងដោយរុញប៊ូតុង), ដុំអូសទាញខាងចុង, ប្រដាប់បួងផ្តុក, ដងស្តីចម្បង និងប្រេងប្រអប់ស្តីអូសគ្រឿងប់បែកល្បឿនពីរ


OUO6075,1683581665364-KM-26JUN23-1/2

ប្រើកម្រិតភាពស្អិតខាប់ដោយផ្អែកលើលំដាប់សីតុណ្ហភាពខ្យល់ដែលបានរំពឹងទុកនៅអំឡុងចន្លោះពេលនៃការផ្លាស់ប្តូរប្រេងម៉ាស៊ីនម្តងៗ។

H132992—UN—19JAN21

មាត្រដ្ឋាន	សេវាថែទាំ	រាល់ 400 ម៉ោង
A	ពិនិត្យមើលប្រេងប្រអប់លេខ (S760 និង S770 មិនមែនគ្រឿងចក្រ ProDrive™) ផ្លៀងផ្នាត់ប្រវែងរបស់ខ្សែស៊ីឡាំងហ្វ្រាំងដៃ (គ្រឿងចក្រដែលប្តូរលេខដោយរុញប៊ូតុង S760 និង S770)	•
B	ផ្តល់សេវាថែទាំ/សម្អាតអាគុយ	•
C	ប្តូរតម្រងវ៉ារី/វ៉ារី (គ្រឿងចក្រ S760 និង S770)	•
D	ប្តូរតម្រងវ៉ារី/វ៉ារី (គ្រឿងចក្រមិនមែន ProDrive™ S760 និង S770) ប្តូរតម្រងវ៉ារី/វ៉ារី (គ្រឿងចក្រ ProDrive™ S760 និង S770)	•
E	ប្តូរតម្រងអ៊ីដ្រូលិក/អ៊ីដ្រូលិក (គ្រឿងចក្រ ProDrive™ S780, S785, និង S790) ប្តូរតម្រងប្រអប់ស្តីម៉ាស៊ីនមេ (គ្រឿងចក្រមិនមែន ProDrive™ S760 និង S770 ProDrive™) ប្តូរតម្រងប្រអប់ហ្គែរម៉ាស៊ីនមេ (គ្រឿងចក្រ ProDrive™ S760 និង S770)	•
F	ពិនិត្យតម្រងខ្យល់គ្រប់គ្រងកម្តៅចកម្តីម៉ាស៊ីន (ចំណាត់ថ្នាក់ចុងក្រោយ 4/ដំណាក់កាល V)	•
G	ពិនិត្យ/សាក/ប្តូរបំពង់ពន្លត់អគ្គីភ័យ	•
H	ពិនិត្យមើលប្រេងប្រអប់ស្តីឡាបមេ (ឈ្នើនថេរ និងដុំអូសមាត់ច្រកបូងចូលឈ្នើនអថេរ)	•
I	ពិនិត្យមើលប្រេងហ្វ្រាំង (គ្រឿងចក្រមិនមែន ProDrive™ S760 និង S770)	•

ProDrive គឺជាពាណិជ្ជសញ្ញារបស់ *Deere & Company*

OUO6075,0004FC8-KM-19JAN21-2/2

ប្រេងប្រអប់លេខ (គ្រឿងចក្រ Non-ProDrive™ S760 និង S770)


តទៅទំព័របន្ទាប់

OUO6075,000443F-KM-17JAN17-1/2

ដោះឆ្នុកចេញ (A) ហើយពិនិត្យមើលកម្រិតប្រេង។

បន្ថែមប្រេងតាមការចាំបាច់ឲ្យដល់កម្រិត 12 mm (1/2 in) នៃផ្នែកខាងក្រោមរន្ធ។

A—ឆ្នុក



ការប្តូរដោយមេកានិច / ការប្តូរដោយរុញប៊ូតុង

OUO6075,000443F-KM-17JAN17-2/2

ខ្សែស៊ីឡាំងហ្វ្រាំងដៃ (គ្រឿងចក្រដែលប្តូរលេខដោយរុញប៊ូតុង S760 និង S770)

OUO6075,0004440-KM-17JAN17-1/2

កំណត់ចំណាំ៖ ភ្ជាប់ហ្វ្រាំងដៃ (ពីស្តង់បានពង្រីក—បានអនុវត្តរីស័រ)។


វាស់ និងផ្ទៀងផ្ទាត់ថាចម្ងាយ (A) ពីសំបកឧបករណ៍បម្លែងអគ្គិសនី (B) ទៅជាតុរក្សាលំនឹង (C) នៅលើចុងទាំងសងខាងស្ថិតក្នុងលក្ខណៈបច្ចេកទេស។

លក្ខណៈបច្ចេកទេស

ខ្សែហ្វ្រាំងដៃ—កម្លាំងបង្វិល	37-1/2 ± 2-1/2 mm (1-31/64 ± 3/32 in)

⚠ ប្រយ័ត្ន៖ ខ្សែស៊ីឡាំងហ្វ្រាំងដៃគឺស្ថិតក្រោមសម្ពាធខ្លាំង។ ខ្សែត្រូវតែបានកែតម្រូវដោយតំណាងចែកចាយ John Deere របស់អ្នក។

ប្រសិនបើចាំបាច់ត្រូវកែតម្រូវខ្សែ សូមទាក់ទងតំណាងចែកចាយ John Deere របស់អ្នក។



A—ចម្ងាយ
B—ការដាក់សំបកឧបករណ៍អសកម្ម
C—ធាតុរក្សាលំនឹង


OUO6075,0004440-KM-17JAN17-2/2

អាគុយ

OUO6075,0004A99-KM-11JAN19-1/2

កំណត់ចំណាំ៖ អាគុយគឺស្ថិតនៅផ្នែកខាងស្តាំ ឬខាងឆ្វេងដោយអាស្រ័យតាមម៉ូដែលគ្រឿងចក្រ។

1. សម្អាតផ្នែកខាងលើអាគុយ និងពិនិត្យមើលកម្រិតនៅក្នុងថតនីមួយៗ។
2. ចាក់បំពេញផ្នែកខាងក្រោមការឧបករណ៍ចាក់បំពេញដោយប្រើទឹកបានចម្រោះប្រសិនបើចាំបាច់។
3. សម្អាតបង្គោលអាគុយ ខ្សែកាប និងរឹតបន្តឹងតំណតាមចាំបាច់។



រចនាប័ទ្ម *A* / រចនាប័ទ្ម *B*

OUO6075,0004A99-KM-11JAN19-2/2

តម្រងអ៊ីដ្រូលីក/អ៊ីដ្រូលីក (គ្រឿងចក្រ S760 និង S770)

OUO6075,0004E01-KM-13APR20-1/2

កំណត់ចំណាំ៖ វាមិនចាំបាច់បង្ហូរប្រេងចេញពីប្រព័ន្ធឡើយ នៅពេលប្តូរតម្រង។

1. ដោះចេញ ហើយប្តូរតម្រង (A) ។
2. លាបប្រេងគ្រឿងភ្ជិតលើតម្រងថ្មី។
3. ដាក់តម្រង។ រឹតបន្តឹងដោយដៃ បន្ទាប់មករឹតបន្តឹង 1/2 ជុំថែមទៀត។

A—តម្រង



OUO6075,0004E01-KM-13APR20-2/2

តម្រងបញ្ចេញវារី

OUO6075,0004E02-KM-26JUN20-1/2

កំណត់ចំណាំ៖ ដោយអាស្រ័យលើការកំណត់រចនាសម្ព័ន្ធគ្រឿងចក្រ រចនាប័ទ្ម និងទីតាំងតម្រងសាកអ៊ីដ្រូលីក។

វាមិនចាំបាច់បង្ហូរប្រេងចេញពីប្រព័ន្ធឡើយ នៅពេលប្តូរតម្រង។


1. ដោះតម្រងចេញ (A)។
2. ប្តូរតម្រង និងលាបប្រេងគ្រឿងភ្ជិត។
3. **រចនាប័ទ្ម A និងរចនាប័ទ្ម B ៖** រឹតដោយដៃ បន្ទាប់មកមួលបន្តឹងទៅតាមលក្ខណៈបច្ចេកទេស។

លក្ខណៈបច្ចេកទេស


តម្រងសាកអ៊ីដ្រូស្តាទិក—កម្លាំងបង្វិល	45 ញូតុនម៉ែត្រ (33 ផោនហ្វីត)

រចនាប័ទ្ម C ៖ រឹតបន្តឹងដោយដៃ បន្ទាប់មករឹតបន្តឹង 1/2 ជុំថែមទៀត។

A—តម្រង



រចនាប័ទ្ម *A* / រចនាប័ទ្ម *B*



រចនាប័ទ្ម *C*

OUO6075,0004E02-KM-26JUN20-2/2

តម្រងប្រអប់ហ្គែរម៉ាស៊ីនមេ

តទៅទំព័របន្ទាប់


OUO6075,00046D8-KM-28MAR17-1/2

កំណត់ចំណាំ៖ ដោយអាស្រ័យលើការកំណត់រចនាសម្ព័ន្ធ គ្រឿងចក្រ តម្រងប្រអប់ហ្គែរម៉ាស៊ីនមេស្ថិតនៅលើផ្នែកខុសៗគ្នានៃគ្រឿងចក្រ។ សូមើលតារាងចន្លោះពេលផ្តល់សេវាថែទាំ— រៀងរាល់ *400* ម៉ោង *(បន្ត)* សម្រាប់ព័ត៌មានបន្ថែម។

វាមិនចាំបាច់បង្ហូរប្រព័ន្ធទេ នៅពេលប្តូរតម្រង។

1. ដោះចេញ ហើយប្តូរតម្រង (A) ។
2. លាបប្រេងគ្រឿងភ្ជិតលើតម្រង។
3. ដាក់តម្រងដោយរឹតបន្តឹងដោយដៃ បន្ទាប់មករឹតបន្តឹង 1/2 ជុំទៀត។

A—តម្រង



H115762—UN—02SEP15


OUO6075,00046D8-KM-28MAR17-2/2

តម្រងខ្យល់ក្រប់ក្រងកម្ទេចកម្ទីម៉ាស៊ីន (ចំណាត់ថ្នាក់ចុងក្រោយ 4/ដំណាក់កាល V)

OUO6075,00047F9-KM-15NOV17-1/2

សំខាន់៖ នៅពេលសញ្ញាកម្រិតតម្រងខ្យល់ ត្រូវបានបង្ហាញលើអេក្រង់ ផ្តល់សេវាជួសជួលតម្រងខ្យល់មេ។

ចូរពិនិត្យតម្រងសុវត្ថិភាពក្រែងលោស្ទះ។



H115760—UN—02SEP15

OUO6075,00047F9-KM-15NOV17-2/2

បំពង់ពន្លត់អគ្គីភ័យ

OUO6075,000490D-KM-02MAR18-1/2

⚠ ប្រយ័ត្ន៖ ត្រួតពិនិត្យខ្សែរឹតបំពង់ពន្លត់អគ្គីភ័យ និងគ្រឿងខ្ទៅចាប់ភ្ជាប់យ៉ាងតិចម្តងក្នុងមួយឆ្នាំ។ ប្រសិនបើខ្សែរឹតបំពង់ពន្លត់អគ្គីភ័យ ឬគ្រឿងខ្ទៅមានលេចនូវសញ្ញាខូចខាត ឬសឹកអចរិលខុសប្រក្រតី ស្មែកពណ៌មានស្នាមរលាត់ លោកអ្នកគួរតែប្តូរខ្សែរឹតនឹងគ្រឿងខ្ទៅទាំងមូលចេញជាបន្ទាន់។ ដើម្បីសុវត្ថិភាពផ្ទាល់ខ្លួន ចូរផ្ទាស់ប្តូរសមាសភាពបំពង់ពន្លត់អគ្គីភ័យចេញដោយដាក់គ្រឿងបន្លាស់ទាំងឡាយណា ដែលមានការអនុញ្ញាតសម្រាប់គ្រឿងចក្ររបស់អ្នក។ ចូរពិគ្រោះជាមួយអ្នកចែកចាយ John Deere របស់អ្នក។

ត្រួតពិនិត្យបំពង់ពន្លត់អគ្គីភ័យ (ខាងមុខ និងខាងក្រោយ) ដោយអនុវត្តតាមការណែនាំថែទាំនៅលើស្លាកបិទលើបំពង់ពន្លត់អគ្គីភ័យ។

សាកឡើងវិញ ឬប្តូរថ្មីតាមចាំបាច់។





H123657—UN—02MAR18


OUO6075,000490D-KM-02MAR18-2/2

ប្រេងប្រអប់ហ្គែរឡាបមេ (ល្បឿនថេរ និងដ្រាយសំបកហ្វិនឌឺរល្បឿនអថេរ)

OUO6075,00046D9-KM-29MAR17-1/2

ពិនិត្យមើលកម្រិតប្រេងប្រអប់ហ្គែរឡាបមេជាមួយនឹងម៉ាកប្រេង (A) ។ បន្ថែមប្រេងតាមតម្រូវការ។

A—ឧបករណ៍វាស់កម្រិតប្រេង



OUO6075,00046D9-KM-29MAR17-2/2

ប្រេងហ្វ្រាំង (គ្រឿងចក្រ S760 និង S770 Non-ProDrive™)


OUO6075,0004449-KM-16JAN17-1/2

1. មើលតាមគម្របធុងសាកួ (A) ហើយពិនិត្យមើលប្រេងហ្វ្រាំង។

កំណត់ចំណាំ៖ កុំឲ្យធូលីចូលក្នុងប្រេងហ្វ្រាំង។

2. បន្ថែមប្រេងហ្វ្រាំងដល់កម្រិត 6 mm (1/4 in) ពីផ្នែកខាងលើ។


A—គម្របធុងសាកួ



OUO6075,0004449-KM-16JAN17-2/2

តារាងចន្លោះពេលផ្តល់សេវាថែទាំ— រាល់ 400 ម៉ោង (ត)

OUO6075,1683664421155-KM-13JUN23-1/2



H134411—UN—17MAY21

មាត្រដ្ឋាន	សេវាថែទាំ	រាល់ 400 ម៉ោង
A	ពិនិត្យខ្សែក្រវាត់សុវត្ថិភាព	•
B	តម្រងបូមប្រអប់ហ្គែរម៉ាស៊ីនមេ/ProDrive (គ្រឿងចក្រ ProDrive S760 និង S770) តម្រងប្រេងរំអិលប្រអប់ហ្គែរម៉ាស៊ីនមេ/ProDrive (គ្រឿងចក្រ ProDrive S780, S785, និង S790)	•
C	លាបប្រេងរំអិលលើអំក្រាយ៉ារំអិលមាត់ច្រកបួងចូល។	•
D	រឹតបន្តឹងក្បាលឡោស៊ីអំក្រាយ៉ាអេឡិកត្រូម៉ាញេទិកក្បាលកាត់ (មាត់ច្រកបួងចូលល្បឿនថេរ និងល្បឿនប្រែប្រួល)	•
E	សម្អាតប្រអប់ស្តីដុំអូសមាត់ច្រកបួងចូលពហុល្បឿន (គ្រឿងចក្រម៉ូដែលS770, S780, S785, និង S790)	•
F	ពិនិត្យមើលប្រេងប្រអប់ហ្គែរប្រដាប់បួងផ្តក	•
G	វ៉ាល់ខ្យល់ចេញចូលធុងសារធាតុរាវបំពង់ស៊ីមុំងម៉ាស៊ូត (DEF) (ចំណាត់ថ្នាក់ចុងក្រោយទី 4 ឬ ដំណាក់កាល V) ប្តូរវ៉ាល់ខ្យល់ចេញចូលធុងប្រេងឥន្ធនៈ	•
H	ពិនិត្យមើលធាតុតម្រងខ្យល់	•
I	អង្គញ្ជាណសំណើមស្អាត (បើមាន) សម្អាតប្រដាប់បួងឆ្លងកាត់អង្គញ្ជាណសំណើម (បើចាំបាច់) ប្តូរបំពង់សារធាតុការពារសំណើមកាមេរ៉ាស្អាត ActiveVision (បើមាន)[a]	•
J	ប្តូរបំពង់សារធាតុការពារសំណើមកាមេរ៉ាប្រព័ន្ធកាកសំណល់ ActiveVision (បើមាន)[a]	•

[a] ប្រសិនបើចប់រដូវច្រូតកាត់ហើយ ចូររង់ចាំរហូតដល់ដើមរដូវច្រូតកាត់បន្ទាប់ដើម្បីពង្រីកអាយុកាលរបស់បំពង់ដាក់សារធាតុការពារសំណើម។

OUO6075,1683664421155-KM-13JUN23-2/2

ខ្សែក្រវាត់សុវត្ថិភាព

តទៅទំព័របន្ទាប់

OUO6075,0004698-KM-21MAR17-1/2

⚠ ប្រយ័ត្ន៖ ត្រួតពិនិត្យខ្សែក្រវ៉ាត់សុវត្ថិភាព និងគ្រឿងចាប់ភ្ជាប់យ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ។ ប្រសិនបើប្រព័ន្ធខ្សែក្រវ៉ាត់សុវត្ថិភាពរួមមានគ្រឿងដំឡើងភ្ជាប់ជាមួយ ក្លាស់គន្លឹះ ខ្សែក្រវ៉ាត់ ឬប្រដាប់ពន្លឺបចូល បង្ហាញឲ្យឃើញនូវសញ្ញាខូចខាតដូចជាដាច់ រសាត់ ឬសឹក មេចរិលខុសប្រក្រតី ស្លេកពណ៌ មានស្នាមរលាត់ ប្រព័ន្ធខ្សែក្រវ៉ាត់សុវត្ថិភាពទាំងមូលគួរតែផ្លាស់ប្តូរភ្លាម។ ដើម្បីសុវត្ថិភាពរបស់អ្នក ប្តូរប្រព័ន្ធខ្សែក្រវ៉ាត់សុវត្ថិភាពជាមួយតែគ្រឿងបន្លាស់ទាំងឡាយណា ដែលមានការអនុញ្ញាតសម្រាប់គ្រឿងចក្ររបស់អ្នកប៉ុណ្ណោះ។ សូមពិគ្រោះជាមួយអ្នកចែកចាយ John Deere របស់អ្នក។

ត្រួតពិនិត្យខ្សែក្រវាក់សុវត្ថិភាពក្រែងលោខូច។



OUO6075,0004698-KM-21MAR17-2/2

ProDrive™/តម្រងបំពង់ប្រអប់ហ្គែរម៉ាស៊ីនមេ (គ្រឿងចក្រ ProDrive™)

OUO6075,00046DA-KM-28MAR17-1/2

កំណត់ចំណាំ៖ វាមិនចាំបាច់បង្ហូរប្រព័ន្ធទេ នៅពេលប្តូរតម្រង។

1. ដោះចេញ ហើយប្តូរតម្រង (A) ។
2. លាបប្រេងគ្រឿងភ្ជិតលើតម្រង។
3. ដាក់តម្រងដោយរឹតបន្តឹងដោយដៃ បន្ទាប់មករឹតបន្តឹង 1/2 ជុំទៀត។

A—តម្រង




OUO6075,00046DA-KM-28MAR17-2/2

អំជ្រាំយ៉ារអិលសំបកហ្វីឌឺរ

OUO6075,000444C-KM-16JAN17-1/2

ដាក់ខ្លាញ់ក្បាលក្រេះនៅអំជ្រាំយ៉ារអិលសំបកហ្វីឌឺរផ្នែកខាងលើ រហូតដល់ខ្លាញ់ចេញមកគ្រឿងភ្ជិតខាងក្រៅ។



OUO6075,000444C-KM-16JAN17-2/2

ក្បាលឡោស៊ីអំជ្រាំយ៉ាអេឡិកត្រូម៉ាញេទិកក្បាលកាត់ (មាត់ច្រកបួងចូលល្បឿនថេរ និងល្បឿនប្រែប្រួល)

តទៅទំព័របន្ទាប់


OUO6075,0005144-KM-18MAY21-1/2

រឹតបន្តឹងក្បាលឡោស៊ីអំប្រ៉ាយ៉ាអេឡិកត្រូម៉ាញេទិកក្បាលកាត់ (A) ទៅតាមលក្ខណៈពិសេសបច្ចេកទេស។

លក្ខណៈបច្ចេកទេស

ក្បាលឡោស៊ីអំប្រាយ៉ាអេឡិកត្រូ
ម៉ាញេទិកក្បាលកាត់ —កម្លាំងបង្វិល . . . . . 328 ញូតុនម៉ែត្រ
(242 ផោនហ្វីត)

A—ក្បាលឡោស៊ីអំប្រាយ៉ាអេឡិកត្រូ ម៉ាញេទិកក្បាលកាត់




OUO6075,0005144-KM-18MAY21-2/2

ប្រអប់ស្តីងំអូសមាត់ច្រកបួងចូលពហុល្បឿន (គ្រឿងចក្រម៉ូដែល S770, S780, S785, និង S790)

OUO6075,0004E94-KM-17JUN20-1/2

⚠ ប្រយ័ត្ន៖ ធូលី ប្រេង សំរាម និងកម្ទេចកម្ទីដំណាំនៅក្នុងផ្នែកនេះអាចបង្ករជាអគ្គីសនី។ ទិសដៅខ្យល់ ប្រភេទដើមដំណាំ និងចំណុះសំណើមដំណាំ អាចមានឥទ្ធិពលលើទីកន្លែងនិងបរិមាណដែលអំពុកចំបើងនិងកម្ទេចកម្ទីកកកុញលើគ្រឿងចក្រ។ ហាមសម្អាតនៅពេលម៉ាស៊ីនកំពុងដំណើរការ។

1. ដោះចង្អើស្តុក (បើមាន) នៅផ្នែកខាងមុខធុងគ្រាប់ធញ្ញជាតិចេញ។
2. ដោះទ្វារចូល នៅផ្នែកខាងមុខនៃធុងគ្រាប់ធញ្ញជាតិ។
3. សម្អាតសម្ភារៈនៅជុំវិញប្រអប់ហ្គែរដ្រាយមាត់ច្រកបួងចូលល្បឿនច្រើន។
4. ដំឡើងទ្វារលូកចូលនិងចង្អើស្តុក (បើមាន)។



OUO6075,0004E94-KM-17JUN20-2/2


ប្រេងប្រអប់ហ្គែរប្រដាប់បួងផ្តុក

OUO6075,00048BF-KM-22FEB18-1/2

កំណត់ចំណាំ៖ ប្រអប់ហ្គែរប្រដាប់បួងផ្តុកមិនតម្រូវឲ្យបង្ហូរទេ។

ពិនិត្យមើលកម្រិតប្រេងដោយប្រើម៉ាកប្រេង (A) ហើយបន្ថែមប្រេងតាមការចាំបាច់។

A—ម៉ាក្លេរ



OUO6075,00048BF-KM-22FEB18-2/2


វ៉ាល់ខ្យល់ចេញចូលធុងសារធាតុរាវ (DEF) (ចំណាត់ថ្នាក់ចុងក្រោយទី 4 ឬដំណាក់កាល V)

តទៅទំព័របន្ទាប់

OUO6075,0004A60-KM-04DEC18-1/2

ដោះចេញ ហើយប្តូរហឺយធុងសារធាតុរាវបំពង់ស៊ីម៉ាំង (DEF) (A)។

A—វ៉ាល់ខ្សល់ចេញចូលធុង Diesel Exhaust Fluid (DEF)




OUO6075,0004A60-KM-04DEC18-2/2

វ៉ាល់ខ្សល់ចេញចូលធុងប្រេងឥន្ធនៈ

OUO6075,0004A61-KM-04DEC18-1/2

ដោះចេញ ហើយប្តូរហឺយធុងប្រេងឥន្ធនៈ (A)។

A—ហឺយ



OUO6075,0004A61-KM-04DEC18-2/2


ធាតុតម្រងខ្សល់

OUO6075,0004451-KM-16JAN17-1/2

សំខាន់៖ នៅពេលសញ្ញាកម្រិតតម្រងខ្សល់របស់ម៉ាស៊ីនត្រូវបានបង្ហាញលើអេក្រង់ ផ្តល់សេវាជួសជុលតម្រងខ្សល់មេ។

ពិនិត្យមើលតម្រងសុវត្ថិភាពសម្រាប់ការដោតឌុយ។

ពិនិត្យមើលក្រែងលោលេចធ្លាយ វេញសម្រាប់បំពង់ស៊ីម៉ាំង។



OUO6075,0004451-KM-16JAN17-2/2

អង្គញ្ជាណសំណើម (បើមាន)

តទៅទំព័របន្ទាប់

OUO6075,1654101266385-KM-02JUN22-1/2


សំខាន់៖ ចរន្តអគ្គិសនីស្ថាទិកអាចធ្វើឲ្យខូចម៉ូឌុលអង្គញ្ជាណសំណើម។ ដើម្បីកុំឲ្យខូចខាត ចូរប្រាកដថាបានប៉ះផ្ទៃលោហៈនៅលើគ្រឿងចក្រដោយដៃម្ខាងយ៉ាងតិច មុននឹងបំពេញការងារនៅលើ ឬសម្អាត។


អង្គញ្ជាណសំណើមមានសមាសភាពគ្រឿងខាងក្នុងដែលអាចបន្ទរបាននៅពេលទម្លាក់ចុះ ដែលប្រហែលមិនអាចចាប់សញ្ញាបានភ្លាមៗ។ ចាត់ចែងអង្គញ្ជាណសំណើមដោយប្រុងប្រយ័ត្ននៅពេលធ្វើការឬសម្អាតនៅលើគ្រឿងចក្រ។

ដោះចេញ ហើយសម្អាតអង្គញ្ជាណសំណើម (A) នៅពេលប្រតិបត្តិការក្នុងស្មៅ ដំណាំបៃតង ឬគ្រាប់ធញ្ញជាតិតូចៗ (កាណូឡា)។

- ហាមប្រើសារធាតុរំលាយឬទឹកលាងសម្អាតផ្សេងទៀតនៅលើមុខអង្គញ្ជាណ។
- យកល្អគួរប្រើក្រណាត់ស្អួតសម្រាប់ជូតសម្អាត។ ប្រសិនបើសម្អាតមិនជ្រះទេ ចូរប្រើក្រណាត់និងទឹកដុសខាត់ពីលើ។
- ហាមប្រើម្សៅសម្អាតមុខអង្គញ្ជាណសំណើម។

ដំឡើងអង្គញ្ជាណសំណើមនិងក្រិតវាតាមខ្នាត។ មើលជំនួយ





H135696—UN—01JUN22

A—អង្គញ្ជាណសំណើម

អនុវត្តទិដ្ឋភាពរួមនៃគ្រឿងច្រូកកាត់ ឬជំនួយស្ថានីយប្រតិបត្តិការសម្រាប់ព័ត៌មានបន្ថែម។


OUO6075,1654101266385-KM-02JUN22-2/2

ប្រដាប់បួងឆ្លងកាត់អង្គញ្ជាណសំណើម (បើចាំបាច់)

OUO6075,1654101328258-KM-09JUN22-1/2

1. ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។
2. ដោះដែកស៊ក (A) និងគម្របខាងចុង (B) ចេញ។
3. ដោះប្រដាប់បួង (C) ចេញពេញប្រដាប់ឆ្លងកាត់អង្គញ្ជាណសំណើម។
4. សម្អាតប្រដាប់បួង និងតំបន់នៅក្នុងប្រដាប់ឆ្លងកាត់អង្គញ្ជាណសំណើម។
5. ដំឡើងនិងលៃតម្រូវប្រដាប់បួង។
6. ដាក់គម្របខាងចុង និងរឹតបន្តឹងដោយដែកស៊ក។

A—កន្លាស់ (ប្រើ 2)
B—គម្របខាងចុង
C—ប្រដាប់បួង



H135697—UN—01JUN22

OUO6075,1654101328258-KM-09JUN22-2/2

បំពង់សារធាតុការពារសំណើមកាមេរ៉ា ActiveVision (បើមាន)

តទៅទំព័របន្ទាប់

OUO6075,1654102766892-KM-09JUN22-1/4

សំខាន់៖ សម្ភារដើមដំណាំនិងកម្ទេចកម្ទីដទៃទៀតអាចកកកុញជុំវិញបំពង់សារធាតុការពារសំណើម។ ពិនិត្យនិងសម្អាតតំបន់ជុំវិញបំពង់សារធាតុការពារសំណើមមុននឹងដោះចេញ។


កំណត់ចំណាំ៖ កាមេរ៉ាប្រដាប់យោងគ្រាប់ធញ្ញជាតិស្អាត *ActiveVision* មានបង្ហាញជូន។ កាមេរ៉ាប្រព័ន្ធសណ្តោង *ActiveVision* គឺស្រដៀងគ្នា។

ប្តូរបំពង់សារធាតុការពារសំណើមតាមចាំបាច់នៅពេលសំណើមកកនៅផ្នែកខាងក្នុងកញ្ចក់ឡែនកាមេរ៉ា។

ប្រសិនបើចប់រដូវច្រូតកាត់ហើយ ចូររង់ចាំរហូតដល់ដើមរដូវច្រូតកាត់បន្ទាប់ដើម្បីពង្រីកអាយុកាលរបស់បំពង់ដាក់សារធាតុការពារសំណើម។

1. ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។
2. ដោះខ្ចៅក្បាលខ្សែក្រុង (A) និងបបន្ទះគម្រប (B) ចេញ។

A—ខ្ចៅក្បាលឡូត (ប្រើ 4) **B—បន្ទះគម្រប**




OUO6075,1654102766892-KM-09JUN22-2/4

3. លែតម្រឹមប្រអប់សារធាតុការពារសំណើម (A) ដែលដាក់បញ្ចូលជាមួយបំពង់សារធាតុការពារសំណើមថ្មីដែលមានគន្លាក់(B)។

សំខាន់៖ នៅពេលប្តូរបំពង់ដារធាតុការពារសំណើម ចូរកុំបណ្តោយឲ្យសម្ភារដំណាំចូលទៅក្នុងកាមេរ៉ា ActiveVision ។

4. ដោះបំពង់សារធាតុការពារសំណើម (C) ចេញពីកាមេរ៉ា ActiveVision ។
5. បោះបង់ចោលបំពង់សារធាតុការពារសំណើម។

A—ប្រអប់សារធាតុការពារសំណើម (ឧបករណ៍) **C—បំពង់សារធាតុការពារសំណើម**
B—គន្លាក់



តទៅទំព័របន្ទាប់


OUO6075,1654102766892-KM-09JUN22-3/4

6. ដោះប្រអប់សារធាតុការពារសំណើម (A) ចេញពីបំពង់សារធាតុការពារសំណើមថ្មី(B)។
7. ដំឡើងបំពង់ដាក់សារធាតុការពារសំណើមក្នុងកាមេរ៉ា ActiveVision ។
8. តម្រឹមឧបករណ៍សារធាតុការពារសំណើមជាមួយនឹងគន្លាក់។
9. រឹតបន្តឹងបំពង់សារធាតុការពារសំណើមទាល់តែវាណែន ឬទៅតាមលក្ខណៈបច្ចេកទេស។

លក្ខណៈបច្ចេកទេស

បំពង់សារធាតុការពារសំណើម—កម្លាំងបង្វិល . . . . . 5 ញូតុនម៉ែត្រ (44 ផោនអ៊ីញ)

10. ដាក់បន្ទះគម្របពីលើបំពង់សារធាតុការពារសំណើម។
11. លាបការបង្ហាំស្នែខ្ចៅ (កម្លាំងមធ្យម) លើខ្ចៅក្បាលខ្សែក្រវ៉ាត់។
12. រឹតបន្តឹងប៊ូឡុងក្បាលឡតខ្សែក្រវ៉ាត់ទៅតាមលក្ខណៈពិសេសបច្ចេកទេស។



ប្រអប់សារធាតុការពារសំណើម (ឧបករណ៍) និងបំពង់សារធាតុការពារសំណើម

A—ប្រអប់សារធាតុការពារសំណើម (ឧបករណ៍)

B—បំពង់សារធាតុការពារសំណើម


លក្ខណៈបច្ចេកទេស

ខ្ចៅក្បាលឡត—កម្លាំងបង្វិល . . . . . 2.5 ញូតុនម៉ែត្រ (22 ផោនអ៊ីញ)

OUO6075,1654102766892-KM-09JUN22-4/4

តារាងចន្លោះពេលផ្តល់សេវាថែទាំ— រៀងរាល់ 800 ម៉ោង

OUO6075,00046DD-KM-28MAR17-1/2



H119640—UN—13OCT16

មាត្រដ្ឋាន	សេវាថែទាំ	រៀងរាល់ 800 ម៉ោង
A	ប្តូរប្រេងប្រអប់ហ្គែរត្រាយបញ្ជាសសំបកហ្វីនីរ	•

OUO6075,00046DD-KM-28MAR17-2/2

ប្រអប់ហ្គែរត្រាយបញ្ជាសសំបកហ្វីនីរ

តទៅទំព័របន្ទាប់

OUO6075,00046DE-KM-28MAR17-1/2

1. លើកសំបកហ្វីឌីរឡើង ហើយបន្ទាបប្រដាប់ការពារសុវត្ថិភាព។

កំណត់ចំណាំ៖ សូមអានផ្នែក "ប្រេងតន្ទន: និងប្រេងរំអិលសម្រាប់ការណែនាំអំពីប្រេង។


2. បង្ហូរប្រេងតាមឆ្នុក (A) ជូតឆ្នុកឲ្យស្អាត ហើយចាក់បំពេញម៉ាកេប្រេងដែលបើក (B) ។

កំណត់ចំណាំ៖ ប្រអប់ហ្គែរមានឧបករណ៍បញ្ចេះកម្តៅប្រេងតម្រូវឲ្យបង្វិលប្រអប់ហ្គែរច្រើននាទី។ វាប្រាកដថា ឧបករណ៍បញ្ចេះកម្តៅត្រូវបានបំពេញដោយប្រេង។

កម្រិតប្រេងត្រូវតែបង្ហាញលើផ្នែកពករបស់ម៉ាកេប្រេង។


3. ពិនិត្យមើលកម្រិតប្រេងដោយលើកសំបកហ្វីឌីរឡើងលើ។

A—ឆ្នុក **B—ឧបករណ៍វាស់កម្រិតប្រេង**



H115801—UN—03SEP15

ប្រអប់ហ្គែរគ្រោយបញ្ហាសឈ្មៀនច្រើន/ឈ្មៀនអចេរ




H115802—UN—03SEP15

ឈ្មៀនចេរ

OUO6075,00046DE-KM-28MAR17-2/2

តារាងចន្លោះពេលផ្តល់សេវាថែទាំ— រៀងរាល់ 1000 ម៉ោង (គ្រឿងចក្រ ProDrive™)

OUO6075,00046DF-KM-28MAR17-1/2



H119641—UN—13OCT16

មាត្រដ្ឋាន	សេវាថែទាំ	រាល់ 1000 ម៉ោង
A, B, C, D, E	ប្តូរប្រេងប្រអប់ហ្គែរម៉ាស៊ីនមេ	•
F	ប្តូរតម្រងធុងសូកអ៊ីដ្រូលីក (គ្រឿងចក្រ S780, S785, និង S790)	•

OUO6075,00046DF-KM-28MAR17-2/2

ប្តូរប្រេងប្រអប់ហ្គែរម៉ាស៊ីនមេ

តទៅទំព័របន្ទាប់


OUO6075,0004940-KM-12APR18-1/2

1. ប្រេងប្រអប់ហ្គែរម៉ាស៊ីនមេ - បង្ហូរប្រេងតាមឆ្នុក (A) ។
2. **គ្រឿងចក្រ S760 និង S770 ProDrive™ ៖** ដោះនិងប្តូរតម្រង (B)។ លាបប្រេងរំអិលលើហ្គឺតនៅលើតម្រងថ្មី។ រឹតបន្តឹងដោយដៃ បន្ទាប់មករឹតបន្តឹង 1/2 ជុំថែមទៀត។
3. **គ្រឿងចក្រ ProDrive™ ៖** ប្រេងប្រអប់លេខ - បង្ហូរប្រេងតាមឆ្នុក (C) ។
4. ProDrive™/តម្រងបូមប្រអប់ហ្គែរម៉ាស៊ីនមេ - ដោះចេញហើយប្តូរតម្រង (D) ។ លាបប្រេងរំអិលលើហ្គឺតនៅលើតម្រង។ រឹតបន្តឹងដោយដៃ បន្ទាប់មករឹតបន្តឹង 1/2 ជុំថែមទៀត។


កំណត់ចំណាំ៖ ចាក់បំពេញប្រេងលើក្នុងប្រអប់ហ្គែរម៉ាស៊ីនមេអាចបង្ខំឱ្យម៉ាកេប្រេងចេញក្រៅនៅពេលម៉ាស៊ីនកំពុងដំណើរការ។

5. **បំពេញប្រេងប់ហ្គែរម៉ាស៊ីនមេ**
   1. ចាក់បំពេញរហូតដល់ប្រេងស្ថិតនៅគំនូសជាតលើម៉ាក្តេរប្រេង (E) ។
   2. ដាក់ម៉ាក្តេរចូលវិញ ហើយដំណើរការម៉ាស៊ីនយ៉ាងតិច 1 នាទី។
   3. ពន្លត់ម៉ាស៊ីន ហើយទុកឱ្យម៉ាស៊ីននៅស្ងៀម 5 នាទីដោយទុកឱ្យខ្យល់ចេញពីប្រេង។
   4. ដោះម៉ាក្តេរប្រេងចេញ ហើយពិនិត្យមើលកម្រិតប្រេង។ បន្ថែមប្រេងរហូតដល់ប្រេងស្ថិតនៅគំនូសខាងលើនៅលើម៉ាកេប្រេង។
   5. អនុវត្តតាមវិធីដដែលរហូតដល់កម្រិតប្រេងស្ថិតនៅលើគំនូសខាងលើនៅលើម៉ាកេប្រេង។


A—ឆ្នុក
B—តម្រង
C—ឆ្នុក
D—តម្រង
E—ម៉ាក្តេរ



H115805—UN—03SEP15



H119733—UN—27OCT16



H115807—UN—03SEP15

ProDrive គឺជាពាណិជ្ជសញ្ញារបស់ *Deere & Company*

OUO6075,0004940-KM-12APR18-2/2

តម្រងរន្ធហឺយអាងស្តុកអ៊ីដ្រូលីក (S780, S785, និង S790)

តទៅទំព័របន្ទាប់

OUO6075,00044C6-KM-22DEC16-1/2

កំណត់ចំណាំ៖ សម្អាតផ្ទៃជុំវិញគម្របតម្រងមុនពេលដោះចេញ ដើម្បីការពារប្រព័ន្ធមិនស្អាត។ វាមិនចាំបាច់បង្ហូរប្រេងចេញពីប្រព័ន្ធឡើយ នៅពេលប្តូរតម្រង។

តម្រងធុងសាកួវារី - ដោះចេញ ហើយប្តូរតម្រងប្រេងឥន្ធនៈចម្បង នៅពេលការបដិសេធក្នុងពេលអនុវត្តត្រូវបានជូនដំណឹង ឬលេខកូដវិនិច្ឆ័យត្រូវបានបង្កើតឡើង។


1. ផ្តាច់តំណចង្វាយខ្សែភ្លើង (A) ចេញពីអង្គញ្ជាណ។

⚠ ប្រយ័ត្ន៖ ដោះវីសប៊ូឡុងស្មើគ្នា ដើម្បីបន្ធូរសម្ពាធរីស័រពីប៊ូឡុងតម្រង។

កំណត់ចំណាំ៖ ត្រួតពិនិត្យ និងប្តូរប៊ូឡុងតម្រងនៅខាងក្រោមកងរាងអក្សរ *O* តាមការចាំបាច់។

2. ដោះនិងរឹតបន្តឹងប៊ូឡុង (C) និងគម្របតម្រង (D)។
3. ដោះចេញ និងរឹតប៊ូឡុងរីស័រនៅខាងលើតម្រង។
4. ដោះ និងបោះតម្រង (C) ចោល។
5. ដាក់តម្រងថ្មីចូលដូចក្នុងរូបភាពជាមួយរីស័រដែលបានដោះចេញកន្លងមក។
6. ចូរដំឡើងគម្របតម្រងដែលបានដោះចេញកន្លងមក។
7. ចូរប្រើគម្របតម្រងដើម្បីសង្កត់រីស័រនិងចាប់រីសគម្របដែលបានដោះចេញកន្លងមកចូលវិញ។

សំខាន់៖ ពិនិត្យមើលក្រែងលោកងរាងមូលមិនស្ថិតនៅនឹងកន្លែងនៅពេលដំឡើងគម្របតម្រង។



H115808—UN—03SEP15

A—តំណចង្វាយខ្សែភ្លើង
B—អង្គញ្ជាណ
C—ប៊ូឡុង
D—គម្របតម្រង

8. មួលបន្តឹងប៊ូឡុងទៅតាមលក្ខណៈបច្ចេកទេស។

លក្ខណៈបច្ចេកទេស


ប៊ូឡុង—កម្លាំងបង្វិល	7 ញូតុនម៉ែត្រ (62 ផោនអ៊ីញ)

9. តភ្ជាប់ចង្វាយខ្សែភ្លើងទៅនឹងអង្គញ្ជាណ។

OUO6075,00044C6-KM-22DEC16-2/2

តារាងចន្លោះពេលផ្តល់សេវាថែទាំ— រៀងរាល់ 1000 ម៉ោង (ក)

OUO6075,000503C-KM-14MAY21-1/2



H133703—UN—16MAR21

មាត្រដ្ឋាន	សេវាថែទាំ	រៀងរាល់ 1000 ម៉ោងម្តង
A	ប្តូរប្រេងហ្គ្រាំង (គ្រឿងចក្រម៉ូដែល S760 និង S770) (ប្រសិនបើមានបំពាក់ប្រអប់លេខប្តូរមេកានិកល្បឿនបី និងប្រអប់លេខប្តូរដោយចុចប៊ូតុង [PBST])	•

OUO6075,000503C-KM-14MAY21-2/2


ប្តូរប្រេងហ្គ្រាំង (គ្រឿងចក្រម៉ូដែល S760 និង S770)

OUO6075,000503D-KM-14MAY21-1/3

កំណត់ចំណាំ៖ ប្រសិនបើមានបំពាក់ប្រអប់លេខប្តូរមេកានិកល្បឿនបី និងប្រអប់លេខប្តូរដោយចុចប៊ូតុង *[PBST])*

1. ដោះគម្រប (A) ចេញពីធុងស្តុកប្រេងហ្គ្រាំង។

A—គម្រប



H100469—UN—25FEB11

តទៅទំព័របន្ទាប់

OUO6075,000503D-KM-14MAY21-2/3

សំខាន់៖ ដើម្បីកុំឲ្យខូចផ្ទៃដែលលាបថ្មាំ ចូរដំឡើងបំពង់ពីលើខ្ចៅសាប់បន្ទរ។

2. ដំឡើងបំពង់ពីលើខ្ចៅសាប់បន្ទរស៊ីឡាំងកង់ (A និង B)។
3. ដើម្បីយកប្រេងហ្វ្រាំងចេញពីទុយោហ្វ្រាំង ចូរសង្កត់ឈ្នាន់ហ្វ្រាំងទៅលើកម្រាលយឺតៗ។
4. ទុកឲ្យប្រេងហ្វ្រាំងហូរចូលទៅក្នុងធុងត្រង។
5. បិទខ្ចៅសាប់បន្ទរស៊ីឡាំងកង់នៅពេលបង្ហូរប្រេងហ្វ្រាំងរួច។

កំណត់ចំណាំ៖ ត្រូវការមនុស្សពីរនាក់ដើម្បីសាប់បន្ទរហ្វ្រាំង។ ម្នាក់ត្រូវតែបូមហ្វ្រាំង និងចាក់ប្រេងចូលធុងស្តុក ចំណែកម្នាក់ទៀតបើកនិងបិទខ្ចៅសាប់បន្ទរដើម្បីសាប់បន្ទរហ្វ្រាំង។

ប្រើតែប្រេងហ្វ្រាំងម៉ា *TY26180* ឬ *DOT 4* ដែលស្អាតប៉ុណ្ណោះ។


6. ចាក់ប្រេងហ្វ្រាំងចូលធុងស្តុកតាមចាំបាច់។
7. ដាក់គម្របពីលើធុងស្តុកសិនដើម្បីកុំបង្កើតជាសុញ្ញាកាសនៅអំឡុងពេលសាប់បន្ទរ។
8. ចាក់សោឈ្នាន់ហ្វ្រាំងរួមគ្នា។
9. បន្ទរខ្ចៅសាប់បន្ទរស៊ីឡាំងកង់ខាងឆ្វេងដៃចំនួន 1/4 ជុំ។

កំណត់ចំណាំ៖ ពិនិត្យមើលប្រេងហ្វ្រាំងនៅក្នុងធុងស្តុក និងចាក់បំពេញតាមចាំបាច់នៅអំឡុងពេលសាប់បន្ទរ។

10. ដោយឈ្នាន់ហ្វ្រាំងនៅខ្ជាស់ជាប់គ្នានៅឡើយ ចូរសង្កត់វាទៅកម្រាលយឺតៗ រីតបន្តឹងខ្ចៅសាប់បន្ទរ និងបន្ទរឈ្នាន់ហ្វ្រាំងយឺតៗ។ ធ្វើដដែលៗរហូតទាល់តែប្រេងថ្លាគ្មានពពុះហូរចេញមក។

កំណត់ចំណាំ៖ ប្រសិនបើចាក់ប្រេងចូលប្រព័ន្ធមួយផ្នែកមុននឹងចាប់ផ្តើមទម្រង់ការសាប់បន្ទរ នោះលំហូរប្រេងថ្មេរនិងថ្លាអាចលេចចេញមកក្នុងវគ្គដំបូងៗ។ ប្រសិនបើខ្យល់ស្ថិតនៅក្នុង ឬនៅជិតស៊ីឡាំងកង់ វាត្រូវការអនុវត្តច្រើនវគ្គដើម្បីរំដោះខ្យល់កាត់តាមបណ្តាញទុយោ និងបញ្ចេញពីខ្ចៅសាប់បន្ទរ។

11. បិទខ្ចៅសាប់បន្ទរស៊ីឡាំងកង់ខាងឆ្វេងដៃ។
12. ចាក់ខ្ជាស់ឈ្នាន់ហ្វ្រាំង។
13. បន្ទរខ្ចៅសាប់បន្ទរស៊ីឡាំងកង់ខាងស្តាំដៃចំនួន 1/4 ជុំ។



A—ខ្ចៅសាប់បន្ទរ (ស៊ីឡាំងកង់ខាងស្តាំដៃ) **B—ខ្ចៅសាប់បន្ទរ (ស៊ីឡាំងកង់ខាងឆ្វេងដៃ)**

កំណត់ចំណាំ៖ ពិនិត្យមើលប្រេងហ្វ្រាំងនៅក្នុងធុងស្តុក និងចាក់បំពេញតាមចាំបាច់នៅអំឡុងពេលសាប់បន្ទរ។

14. សង្កត់ឈ្នាន់ហ្វ្រាំងខាងស្តាំដៃយឺតៗទៅនឹងកម្រាល រីតបន្តឹងខ្ចៅសាប់បន្ទរ និងលែងឈ្នាន់ហ្វ្រាំងយឺតៗ។ ធ្វើដដែលៗរហូតទាល់តែប្រេងថ្លាគ្មានពពុះហូរចេញមក។
15. បិទខ្ចៅសាប់បន្ទរស៊ីឡាំងកង់ខាងស្តាំដៃ។
16. ដោះបំពង់ទុយោចេញពីខ្ចៅសាប់បន្ទរស៊ីឡាំងកង់។
17. មួលបន្តឹងខ្ចៅសាប់បន្ទរទាំងពីរទៅតាមលក្ខណៈពិសេសបច្ចេកទេស។

លក្ខណៈបច្ចេកទេស

ខ្ចៅសាប់បន្ទរស៊ីឡាំងកង់—កម្លាំងបង្វិល	12 ញូតុនម៉ែត្រ (106 ផោនអ៊ីញ)

កំណត់ចំណាំ៖ បន្ថែមប្រេងហ្វ្រាំងចូលដល់កម្រិត *6* មម *(1/4 អ៊ីញ)* ពីផ្នែកខាងលើ។

18. ពិនិត្យធុងស្តុកប្រេងហ្វ្រាំងមើលកម្រិតប្រេងសមស្រប។
19. ដាក់គម្របលើធុងស្តុកប្រេងហ្វ្រាំង។
20. ពិនិត្យមើលប្រព័ន្ធហ្វ្រាំងក្រែងលោលេចធ្លាយ និងពិនិត្យឈ្នាន់និមួយៗក្រែងលោគាំង។

OUO6075,000503D-KM-14MAY21-3/3

តារាងចន្លោះពេលធ្វើសេវាកម្មថែទាំ—រៀងរាល់ 2000 ម៉ោង

OUO6075,0004DE8-KM-02APR20-1/2



H119642—UN—13OCT16

កំណត់ចំណាំ៖ ចន្លោះពេលប្តូរទឹកថ្នាំស៊ុំដែលបានកំណត់ពេលពីរឆ្នាំ ឬ *2000* ម៉ោង ប្រសិនបើប្រើទឹកថ្នាំ *John Deere Cool-Gard™ II* ឬ *Cool-Gard™ II PG*។

មាត្រដ្ឋាន	សេវាថែទាំ	រាល់ 2000 ម៉ោង
A	ប្តូរប្រេងធុងសាកូវ៉ារី/វ៉ារី	•
B	ពិនិត្យមើលចន្លោះវ៉ាល់ម៉ាស៊ីន[a]	•
C	ពិនិត្យមើលប្រេងក្រាយចុងក្រោយ (ផ្នែកទាំងសងខាង)	•
D	ប្តូរប្រេងប្រអប់ហ្គែរម៉ាស៊ីនមេ (មិនមែនគ្រឿងចក្រ ProDrive™)	•
E	ប្តូរប្រេងគ្រឿងអូសគ្រឿងប៉ប៉ែក	•
F	ប្តូរប្រេងប្រអប់ហ្គែរឡាបមេ (ឡើនថេរ និងគ្រាយស់បកហ្វឺឌីរឡើនអថេរ)	•
G	ប្តូរប្រេងប្រអប់លេខ (ការប្តូរប្រអប់លេខដោយមេកានិច និងដោយរុញប៊ូតុង)	•
H	ប្រអប់ស្តីឌបករណ៍សម្អាត (ជាជម្រើស) (គ្រឿងចក្រ S770, S780, S785, និង S790)	•

[a] សម្រាប់សេវាថែទាំ សូមពិគ្រោះជាមួយអ្នកតំណាងចែកចាយ *John Deere*។

ProDrive គឺជាពាណិជ្ជសញ្ញារបស់ *Deere & Company*

Cool-Gard គឺជាពាណិជ្ជសញ្ញារបស់ *Deere & Company*

OUO6075,0004DE8-KM-02APR20-2/2

ប្រេងធុងសាកូវ៉ារី/វ៉ារី


តទៅទំព័របន្ទាប់

OUO6075,000445A-KM-22DEC16-1/2


កំណត់ចំណាំ៖ សម្អាតផ្នែធុងសាកួវារី ដើម្បីការពារប្រព័ន្ធមិនស្អាត។ មើលផ្នែកលក្ខណៈបច្ចេកទេសសម្រាប់សមត្ថភាពប្រេង។

1. បើកវាល់បង្ហូរ (A) ដើម្បីបង្ហូរប្រេង។ បិទវាល់នៅពេលប្រេងត្រូវបានបង្ហូរអស់។
2. ដោះគម្របចេញ (B) ហើយចាក់បំពេញធុងសាកួវារីរហូតដល់កម្រិតប្រេងដល់ផ្នែកខាងលើនៃកែវមើលឃើញ (C) មានសំបកហ្វីឌីរបានបន្ទាបទាំងស្រុង។

A—វាល់បង្ហូរ
B—គម្រប
C—កែវមើលកម្រិតប្រេង



រចនាប័ទ្ម *A*




រចនាប័ទ្ម *B*

OUO6075,000445A-KM-22DEC16-2/2

ចន្លោះវាល់ម៉ាស៊ីន

OUO6075,0004DE9-KM-26JUN20-1/2

ឱ្យតំណាងចែកចាយ John Deere របស់អ្នកពិនិត្យមើលចន្លោះវាល់ម៉ាស៊ីន ហើយលៃតម្រូវបើចាំបាច់។



OUO6075,0004DE9-KM-26JUN20-2/2

ប្រេងដុំអូសទាញខាងចុង


តទៅទំព័របន្ទាប់

OUO6075,1684873072806-KM-13JUN23-1/2

ប្រយ័ត្ន៖ គ្រឿងចក្រ HillMaster៖ នៅពេលពិនិត្យកម្រិតប្រេងដុំអូសទាញខាងចុង ចូរផ្តល់សញ្ញាដល់អ្នកនៅក្បែរឲ្យស្ថិតនៅឲ្យឆ្ងាយពីគ្រឿងចក្រខណៈពេលកំពុងពង្រាប។

សំខាន់៖ គ្រឿងចក្រ HillMaster៖ ដើម្បីពិនិត្យមើលកម្រិតប្រេងឲ្យបានត្រឹមត្រូវ ត្រូវតែដាក់ដុំអូសទាញខាងចុងដើម្បីឲ្យដងបញ្ចូលដុំអូសទាញខាងចុងស្ថិតនៅលើកម្រិតដូចគ្នានឹងដងបង្ងិលភ្លៅ។

1. ដោះឆ្នុកបង្ហូរ (A) ចេញពីដុំអូសទាញខាងចុង។
2. ទុកឲ្យប្រេងដុំអូសទាញខាងចុងហូរ។
3. ដាក់ឆ្នុកបង្ហូរចូលនៅពេលបង្ហូរប្រេងអស់។
4. ដោះឆ្នុកចាក់បំពេញ (B) ពីដុំអូសទាញខាងចុង។
5. ថែមប្រេងចូលរហូតដល់កម្រិតប្រេងស្ថិតក្នុងកម្រិត 12 ម.ម (1/2 អ៊ីញ) នៃផ្នែកខាងក្រោមរន្ធពិនិត្យមើល (C)។
6. ដាក់ឆ្នុកចាក់បំពេញដែលដោះចេញកន្លងមកចូលវិញ ហើយនពិនិត្យមើលឆ្នុករន្ធ។
7. ធ្វើដូចគ្នានេះសម្រាប់ផ្នែកម្ខាងទៀតនៃគ្រឿងចក្រ។



ការកំណត់រចនាសម្ព័ន្ធសម្បកកង់ទោល និង *HillMaster* (ឆ្វេង) / ការកំណត់រចនាសម្ព័ន្ធសម្បកកង់ឌុប (ស្តាំ)

A—ឆ្នុកបង្ហូរ
B—ឆ្នុកចាក់បំពេញ
C—រន្ធត្រួតពិនិត្យ

OUO6075,1684873072806-KM-13JUN23-2/2


ប្រេងប្រអប់ហ្គែរម៉ាស៊ីនមេ (គ្រឿងចក្រ Non-ProDrive™)

OUO6075,00046E2-KM-28MAR17-1/2

បង្ហូរតាមឆ្នុក (A) ។

ចាក់បំពេញ និងពិនិត្យមើលកម្រិតប្រេងតាមម៉ាកេប្រេង (B) ។

A—ឆ្នុកបង្ហូរ
B—ឧបករណ៍វាស់កម្រិតប្រេង



OUO6075,00046E2-KM-28MAR17-2/2


ប្រេងក្រោយតម្រងចម្រោះ

តទៅទំព័របន្ទាប់

OUO6075,0004A84-KM-17DEC18-1/2

1. ដោះគម្រប (A) ចេញ ហើយភ្ជាប់ទុយោទៅកាន់កន្លែងបង្ហូរ (B) ។
2. មួលបើកវីសក្បាលឡតដែលស្ថិតនៅក្នុងវ៉ាល់បង្ហូរ (C) ដើម្បីបង្ហូរប្រេងចេញ។
3. ចាក់ប្រេងចូលតាមម៉ាក្កោរ៍ (D) តាមចាំបាច់។

A—គម្រប
B—បង្ហូរ
C—វ៉ាល់បង្ហូរ
D—ម៉ាក្កោរ៍



H125516—UN—17DEC18


OUO6075,0004A84-KM-17DEC18-2/2

ប្រេងប្រអប់ហ្គែរឡាបមេ (ល្បឿនថេរ និងដ្រាយសំបកហ្វីឌឺរល្បឿនអថេរ)

OUO6075,00046E3-KM-28MAR17-1/2

បង្ហូរតាមគម្រប (A) ហើយចាក់បំពេញតាមម៉ាកេប្រេង (B) ។ កម្រិតប្រេងត្រូវតែបង្ហាញលើផ្នែកពករបស់ម៉ាកេប្រេង។

A—គម្រប
B—ឧបករណ៍វាស់កម្រិតប្រេង



H115817—UN—04SEP15


OUO6075,00046E3-KM-28MAR17-2/2

ប្រេងប្រអប់លេខ (ការប្តូរប្រអប់លេខដោយមេកានិច និងដោយរុញប៊ូតុង)

OUO6075,0004460-KM-22DEC16-1/2

1. រុញបំពង់ (A) ចេញពីកន្លែងទប់ស្កាត់ (B) ។
2. ដោះការទប់ស្កាត់ចេញ ដើម្បីបង្ហូរ។
3. ដោះឆ្នុកពិនិត្យមើល (C) ហើយចាក់បំពេញដល់កម្រិត 12 mm (1/2 in) នៃរន្ធ។

A—បំពង់
B—ទប់ស្កាត់
C—ពិនិត្យមើលឆ្នុក



H115818—UN—04SEP15

ការប្តូរដោយមេកានិច / ការប្តូរដោយរុញប៊ូតុង

OUO6075,0004460-KM-22DEC16-2/2


ប្រេងប្រអប់ស្តីឧបករណ៍សម្អាត (ជាជម្រើស) (គ្រឿងចក្រ S770, S780, S785, និង S790)

តទៅទំព័របន្ទាប់

OUO6075,00046E4-KM-28MAR17-1/2

បង្ហូរតាមឆ្នូក (A) ហើយចាក់បំពេញតាមឆ្នូក (B) ។ កម្រិតប្រេងត្រូវតែជាកម្រិតជាមួយនឹងរន្ធឆ្នូកនៅលើផ្នែកម្ខាងនៃប្រអប់ស្តី។

A—ឆ្នូក **B—ឆ្នូក**




H115819—UN—04SEP15

OUO6075,00046E4-KM-28MAR17-2/2

តារាងចន្លោះពេលផ្តល់សេវាថែទាំ— រាល់ 2000 ម៉ោង (ក)

OUO6075,1657720585940-KM-13JUL22-1/2



H120324—UN—22DEC16

មាត្រដ្ឋាន	សេវាថែទាំ	រាល់ 2000 ម៉ោង
A	ពិនិត្យមើលសម្រួបដងវៃម៉ាស៊ីន (ចំណាត់ថ្នាក់ចុងក្រោយ 4/ដំណាក់កាល V)	•

OUO6075,1657720585940-KM-13JUL22-2/2


ពិនិត្យមើលសម្រួបដងវៃម៉ាស៊ីនខាងមុខ (ចំណាត់ថ្នាក់ចុងក្រោយ 4/ដំណាក់កាល V)

តទៅទំព័របន្ទាប់

OUO6075,1657721749711-KM-13JUL22-1/2

សំខាន់៖ បង្គុំសម្រួបរំញ័រមិនអាចជួសជុលឡើងវិញបានឡើយ ហើយគួរតែពិនិត្យមើលរាល់ 2000 ម៉ោង។

ឲ្យអ្នកចែកចាយក្រុមហ៊ុន John Deere ពិនិត្យមើលគ្រឿងសម្រួបដងវៃម៉ាស៊ីនខាងមុខ។




H120326—UN—22DEC16

ចំណាត់ថ្នាក់ចុងក្រោយ *4*/ដំណាក់កាល *V (*បែប *A* / បែប *B)*

OUO6075,1657721749711-KM-13JUL22-2/2

តារាងចន្លោះពេលផ្តល់សេវាថែទាំ— រៀងរាល់ 2000 ម៉ោង ឬបីឆ្នាំ

OUO6075,0004A6E-KM-14DEC18-1/2



H125475—UN—10DEC18

មាត្រដ្ឋាន	សេវាថែទាំ	រាល់ 2000 ម៉ោង ឬ ៣ ឆ្នាំ ម្តង
A	ប្តូរតម្រងឧបករណ៍កំណត់ដូសធាតុរាវកាត់បន្ថយជាតិពុលក្នុងផ្សែងម៉ាស៊ូត (DEF) (ម៉ាស៊ីនចំណាត់ថ្នាក់ចុងក្រោយទី 4 ឬដំណាក់កាល V S780, S785, និង S790)	•
B	ប្តូរតម្រងជាដួរធាតុរាវកាត់បន្ថយជាតិពុលក្នុងផ្សែងម៉ាស៊ូត (DEF) (គ្រឿងចក្រចំណាត់ថ្នាក់ចុងក្រោយទី 4 ឬដំណាក់កាល V S780, S785, និង S790)	•

OUO6075,0004A6E-KM-14DEC18-2/2

ការប្តូរតម្រងប្រអប់កំណត់ដូសធាតុរាវកាត់បន្ថយជាតិពុលក្នុងផ្សែងម៉ាស៊ូត (DEF) (គ្រឿងចក្រម៉ូដែល S780, S785, និង S790)

តទៅទំព័របន្ទាប់

OUO6075,0004BBB-KM-30MAY19-1/2

⚠ ប្រយ័ត្ន៖ ចូរប្រយ័ត្នក្រែងលោប៉ះភ្នែក។ ប្រសិនបើប៉ះចំភ្នែក ចូរជាញឹកក្នុងចំនួនច្រើនចូលក្នុងភ្នែកភ្លាមៗ ក្នុងរយៈពេលយ៉ាងតិច 15 នាទី។ ដើម្បីជ្រាបនូវព័ត៌មានបន្ថែម សូមអានតារាងទិន្នន័យសុវត្ថិភាពសម្ភារៈ (MSDS)។

សំខាន់៖ ប្រសិនបើ DEF កំពប់ ឬប៉ះពាល់ផ្ទៃណាមួយក្រៅពីធុងស្តុក ចូរលាងសម្អាតផ្ទៃនោះភ្លាមៗដោយប្រើទឹកថ្លា។ DEF ធ្វើឲ្យផ្ទៃលោហធាតុដែលបានលាបថ្នាំពណ៌ និងមិនបានលាបថ្នាំពណ៌ច្រែះ និងអាចបំផ្លាញរូបរាងដើមរបស់សមាសធាតុផ្លាស្ទិច និងជរាមួយចំនួន។

DEF ដែលបានបញ្ចេញ បើបានទុកឱ្យស្ងួត ឬបើបានជូតចេញដោយក្រណាត់ប៉ុណ្ណោះ ទុកឱ្យមានសំណល់ពណ៌ស។ ការសម្អាត DEFដែលកំពប់មិនបានត្រឹមត្រូវអាចរំខានដល់ការវិនិច្ឆ័យបញ្ហាការលេចប្រព័ន្ធកាត់បន្ថយកត្តាលើករជម្រើស (SCR)។

កំណត់ចំណាំ៖ តម្រងឧបករណ៍កំណត់ដូស *DEF* និងតម្រងជាជួរ *DEF* ត្រូវតែប្តូរចោលជាមួយគ្នារៀងរាល់ *2000* ម៉ោងឬ *36* ខែ ទោះជាដល់កំណត់មួយណាមុនក៏ដោយ។

ការផ្តល់សេវាថែទាំតម្រងឧបករណ៍កំណត់ដូស *DEF* តម្រូវឲ្យដោះគម្រប ឬសមាសភាពគ្រឿងបន្ថែម។ សម្រាប់ព័ត៌មានអំពីទីតាំង ចូរអានអំពីការចូលទៅកាន់ឧបករណ៍កំណត់ដូស *DEF*។

1. សម្អាតកម្ទេចកម្ទីចេញពីតំបន់ជុំវិញឧបករណ៍កំណត់ដូស DEF។

កំណត់ចំណាំ៖ រង់ចាំប្រហែល *5* នាទី ដើម្បីឲ្យ *DEF* ធ្វើវិសុទ្ធកម្មពីប្រព័ន្ធ។


2. ដោះគម្របតម្រង (A) ចេញ។
3. ដោះនិងបោះចោលនូវសមាសធាតុរក្សាល់នឹង (B)។

កំណត់ចំណាំ៖ ឧបករណ៍តម្រង *DEF (C)* ត្រូវដាក់ដោយតម្រងជំនួស។

4. សិកចុងពណ៌"ខ្មៅ"នៃឧបករណ៍តម្រង (C) ទៅក្នុងតម្រងឧបករណ៍កំណត់ដូស DEF (D) រហូតដល់មានអារម្មណ៍ឬលឺសូរក្តឹក ដែលបង្ហាញថាឧបករណ៍តម្រងគឺត្រូវបានចូលកឹប។

កំណត់ចំណាំ៖ ឧបករណ៍ ដូចជាទួងណឺវីស អាចសិកចូលទៅក្នុងរន្ធឧបករណ៍តម្រងដើម្បីជួយដល់ការដោះចេញ។

5. ទាញឧបករណ៍តម្រង និងតម្រងឧបករណ៍កំណត់ដូស DEF



តម្រងឧបករណ៍កំណត់ដូស *DEF*

A—គម្របតម្រង
B—សមាសធាតុរក្សាល់នឹង
C—ឧបករណ៍តម្រង
D—តម្រងឧបករណ៍កំណត់ដូស DEF

ចេញពីឧបករណ៍កំណត់ដូស DEF នោះ។ បោះចោលឧបករណ៍តម្រង និងឧបករណ៍តម្រងឧបករណ៍កំណត់ដូស DEF។

6. សម្អាតស្នែខ្ចៅឧបករណ៍កំណត់ដូស DEF និងផ្ទៃបន្ទប់ដោយប្រើទឹកសុទ្ធ។
7. លាបប្រេងតម្រង DEF ស្អាតលើកងមូល។ ស៊កបញ្ចូលតម្រងឧបករណ៍កំណត់ដូស DEF ទៅក្នុងឧបករណ៍កំណត់ដូស DEF។
8. ដំឡើងធាតុលំនឹងតម្រងឧបករណ៍កំណត់ដូស DEF ថ្មីទៅក្នុងតម្រងឧបករណ៍កំណត់ដូស DEF។
9. ដាក់គម្របតម្រងចូល រួចរឹតបន្តឹងវាឲ្យត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស៖

លក្ខណៈបច្ចេកទេស

គម្របតម្រង—កម្លាំងបង្វិល	23 ញូតុនម៉ែត្រ (204 ផោនអ៊ីញ)

OUO6075,0004BBB-KM-30MAY19-2/2

ប្តូរតម្រងជាជួរធាតុរាវកាត់បន្ថយជាតិពុលក្នុងផ្សែងម៉ាស៊ូត (DEF) (គ្រឿងចក្រម៉ូដែល S780, S785, និង S790)

តទៅទំព័របន្ទាប់

OUO6075,0004BBC-KM-30MAY19-1/6

⚠ ប្រយ័ត្ន៖ ចូរប្រយ័ត្នក្រែងលោប៉ះក្អែក។ ប្រសិនបើប៉ះចំក្អែក ចូរជាញ់ទឹកក្តៅចំនួនច្រើនចូលក្នុងភ្នែកភ្លាមៗ ក្នុងរយៈពេលយ៉ាងតិច 15 នាទី។ ដើម្បីទ្រាបនូវព័ត៌មានបន្ថែម សូមអានតារាងទិន្នន័យសុវត្ថិភាពសម្ភារៈ (MSDS)។

សំខាន់៖ ប្រសិនបើ DEF កំពប់ ឬប៉ះពាល់ផ្ទៃណាមួយក្រៅពីធុងស្តុក ចូរលាងសម្អាតផ្ទៃនោះភ្លាមៗដោយប្រើទឹកថ្លា។ DEF ធ្វើឲ្យផ្ទៃលោហធាតុដែលបានលាបថ្នាំពណ៌ និងមិនបានលាបថ្នាំពណ៌ច្រេះ និងអាចបំផ្លាញរូបរាងដើមរបស់សមាសធាតុផ្លាស្ទិច និងជរាមួយចំនួន។


DEF ដែលបានបញ្ចេញ បើបានទុកឱ្យស្ងួត ឬបើបានជូតចេញដោយក្រណាត់ប៉ុណ្ណោះ ទុកឱ្យមានសំណល់ពណ៌ស។ ការសម្អាត DEFដែលកំពប់មិនបានត្រឹមត្រូវអាចរំខានដល់ការវិនិច្ឆ័យបញ្ហាការលេចប្រព័ន្ធកាត់បន្ថយកត្តាលិករជម្រើស (SCR)។

កំណត់ចំណាំ៖ តម្រងជាជួរ *DEF* និងតម្រងឧបករណ៍កំណត់ជួស *DEF* ត្រូវតែប្តូរចោលជាមួយគ្នារៀងរាល់ *2000* ម៉ោងឬ *36* ខែ ទោះជាដល់កំណត់មួយណាមុនក៏ដោយ។

1. សម្អាតកម្ទេចកម្ទីចេញពីតំបន់ជុំវិញបង្គុំតម្រងជាជួរ DEF។

កំណត់ចំណាំ៖ រង់ចាំប្រហែល *5* នាទី ដើម្បីឲ្យ *DEF* ធ្វើវិសុទ្ធកម្មពីប្រព័ន្ធ។

2. ដោះនិងបោះឆ្នុកតម្រង (A) ចោល។



A—ឆ្នុកបង្ហូរ **B—គម្របតម្រង**

3. បង្ហូរសារធាតុរាវ DEF ចូលទៅក្នុងធុង។
4. ដោះគម្របតម្រង (B) ចេញ។


OUO6075,0004BBC-KM-30MAY19-2/6

5. ទាញបង្គុំតម្រង (A) ចុះក្រោមចេញពីតួ DEF ។

កំណត់ចំណាំ៖ បើចាំបាច់ ចូរគោះតម្រងដើម្បីបន្ធូរ។ បន្ទះផ្លាស្ទិចនៅខាងក្នុងគម្របតម្រងចាក់ខ្ទាស់តម្រងឲ្យនៅនឹងកន្លែង។

6. ដោះនិងបោះចោលតម្រង (B) ពីគម្របតម្រង។
7. សម្អាតធ្មេញស្នែបង្គុំ និងផ្ទៃបន្ទប់ដោយប្រើទឹកបរិសុទ្ធ។

A—បង្គុំតម្រង **B—តម្រង**



OUO6075,0004BBC-KM-30MAY19-3/6

8. ដោះនិងបោះចោលប្រដាប់ញែកពពុះ (A) បោះចោលហ្វឺត (B) ដែលដោះចេញពីគម្របតម្រង(C)។
9. ដំឡើងប្រដាប់ញែកពពុះថ្មី ហើយដាក់ហ្វឺតថ្មីចូលទៅក្នុងគម្រងតម្រងដែលបានដោះចេញកន្លងមក។

A—ប្រដាប់ញែកពពុះ **C—គម្របតម្រង**
B—ហ្វឺត



តទៅទំព័របន្ទាប់

OUO6075,0004BBC-KM-30MAY19-4/6

កំណត់ចំណាំ៖ បន្ទុះផ្លាស្ទិចនៅខាងក្នុងគម្របចាក់ខ្វាស់តម្រងឲ្យនៅនឹងកន្លែង។

10. សិកតម្រងថ្មី (A) ទៅក្នុងគម្របតម្រងដូចក្នុងរូប ហើយបន្ទាប់មកសិកចូលក្នុងតួ DEF (B)។
11. ដាក់គម្របតម្រងចូល រួចរឹតបន្តឹងវាឲ្យត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស៖

លក្ខណៈបច្ចេកទេស

គម្របតម្រង—កម្លាំងបង្វិល	25 ញូតុនម៉ែត្រ (221 ផោនអ៊ីញ)

A—តម្រង **B—តួ DEF**



H125464—UN—06DEC18

OUO6075,0004BBC-KM-30MAY19-5/6

12. ដាក់រ៉ងមូល (A) ចូលទៅក្នុងគន្លាក់ (B) នៅលើឆ្នុលបង្ហូរថ្មី។
13. ចូរដាក់ឆ្នុកបង្ហូរចូលទៅក្នុងគម្របតម្រង រួចរឹតបន្តឹងវាទៅតាមលក្ខណៈបច្ចេកទេស។

លក្ខណៈបច្ចេកទេស

ឆ្នុកបង្ហូរប្រេង—កម្លាំងបង្វិល	4 ញូតុនម៉ែត្រ (35 ផោនអ៊ីញ)

A—កងមូល **B—គន្លាក់**




H125465—UN—06DEC18

OUO6075,0004BBC-KM-30MAY19-6/6

ការថែទាំ— រៀងរាល់ 3500 ម៉ោង ឬបីឆ្នាំម្តង

តារាងចន្លោះពេលផ្តល់សេវាថែទាំ— រៀងរាល់ 3500 ម៉ោង ឬបីឆ្នាំ

OUO6075,0004A6B-KM-14DEC18-1/2



H125475—UN—10DEC18

មាត្រដ្ឋាន	សេវាកម្មថែទាំ	រាល់ 3500 ម៉ោង ឬ ៣ ឆ្នាំម្តង
A	ប្តូរតម្រងឧបករណ៍កំណាត់ដូសសារធាតុរាវបំពង់ស៊ីម៉ាំងម៉ាស៊ូត (DEF) (ម៉ាស៊ីនចំណាត់ថ្នាក់ចុងក្រោយទី 4 ឬដំណាក់កាល V S760 និង S770)	•
B	ប្តូរតម្រងជាដួរសារធាតុរាវបំពង់ស៊ីម៉ាំងម៉ាស៊ូត (DEF) (គ្រឿងចក្រចំណាត់ថ្នាក់ចុងក្រោយទី 4 ឬដំណាក់កាល V S760 និង S770)	•

OUO6075,0004A6B-KM-14DEC18-2/2

ការប្តូរតម្រងប្រអប់កំណាត់ដូសសារធាតុរាវនៅក្នុងបំពង់ស៊ីម៉ាំងម៉ាស៊ូត (DEF) (គ្រឿងចក្រម៉ូដែល S760 និង S770)

តទៅទំព័របន្ទាប់

OUO6075,0004BB9-KM-30MAY19-1/2

⚠ ប្រយ័ត្ន: ចូរប្រយ័ត្នក្រែងលោប៉ះភ្នែក។ ប្រសិនបើប៉ះចំភ្នែក ចូរជាញឹកក្តងចំនួនច្រើនចូលក្នុងភ្នែកភ្លាមៗ ក្នុងរយៈពេលយ៉ាងតិច 15 នាទី។ សម្រាប់ព័ត៌មានបន្ថែម សូមអានតារាងទិន្នន័យសុវត្ថិភាពរបស់សម្ភារៈ (MSDS)។

សំខាន់: ប្រសិនបើ DEF កំពប់ ឬប៉ះពាល់ផ្ទៃណាមួយក្រៅពីធុងស្តុក ចូរលាងសម្អាតផ្ទៃនោះភ្លាមៗដោយប្រើទឹកថ្លា។ DEF ធ្វើឲ្យផ្ទៃលោហធាតុដែលបានលាបថ្នាំពណ៌ និងមិនបានលាបថ្នាំពណ៌ច្រែះ និងអាចបំផ្លាញរូបរាងដើមរបស់សមាសធាតុផ្លាស្ទិច និងជ័រមួយចំនួន។

DEF ដែលបានបញ្ចេញ បើបានទុកឱ្យស្ងួត ឬបើបានជូតចេញដោយក្រណាត់ប៉ុណ្ណោះ ទុកឱ្យមានសំណល់ពណ៌ស។ ការកំពប់ DEF ដែលមិនបានសម្អាតត្រឹមត្រូវអាចរំខានដល់ការវិនិច្ឆ័យបញ្ហាការលេចប្រព័ន្ធកាត់បន្ថយកត្តាលើករជម្រើស (SCR)។

កំណត់ចំណាំ: តម្រងឧបករណ៍កំណត់ដូស *DEF* និងតម្រងជាជួរ *DEF* ត្រូវតែប្តូរចោលជាមួយគ្នារៀងរាល់ *3500* ម៉ោងឬ *36* ខែ ទោះជាដល់កំណត់មួយណាមុនក៏ដោយ។

ការផ្តល់សេវាថែទាំតម្រងឧបករណ៍កំណត់ដូស *DEF* តម្រូវឲ្យដោះគម្រប ឬសមាសភាពគ្រឿងបន្ថែម។ សម្រាប់ព័ត៌មានអំពីទីតាំង ចូរអានអំពីការចូលទៅកាន់ឧបករណ៍កំណត់ដូស *DEF*។

1. សម្អាតកម្ទេចកម្ទីចេញពីតំបន់ជុំវិញឧបករណ៍កំណត់ដូស DEF។

កំណត់ចំណាំ: រង់ចាំប្រហែល *5* នាទី ដើម្បីឲ្យ *DEF* ធ្វើវិសុទ្ធកម្មពីប្រព័ន្ធ។


2. ដោះគម្របតម្រង (A) ចេញ។
3. ដោះនិងបោះចោលនូវសមាសធាតុរក្សាល់នឹង (B)។

កំណត់ចំណាំ: ឧបករណ៍តម្រង *DEF (C)* ត្រូវដាក់ដោយតម្រងជំនួស។

4. សិកចុងពណ៌"ខ្មៅ"នៃឧបករណ៍តម្រង (C) ទៅក្នុងតម្រងឧបករណ៍កំណត់ដូស DEF (D) រហូតដល់មានអារម្មណ៍ឬលឺសូរក្លឹក ដែលបង្ហាញថាឧបករណ៍តម្រងគឺត្រូវបានចូលកឹប។

កំណត់ចំណាំ: ឧបករណ៍ ដូចជាទួងណឺវីស អាចសិកចូលទៅក្នុងរន្ធឧបករណ៍តម្រងដើម្បីជួយដល់ការដោះចេញ។

5. ទាញឧបករណ៍តម្រង និងតម្រងឧបករណ៍កំណត់ដូស DEF



តម្រងឧបករណ៍កំណត់ដូស *DEF*

A—គម្របតម្រង
B—សមាសធាតុរក្សាល់នឹង
C—ឧបករណ៍តម្រង
D—តម្រងឧបករណ៍កំណត់ដូស DEF

ចេញពីឧបករណ៍កំណត់ដូស DEF នោះ។ បោះចោលឧបករណ៍តម្រង និងឧបករណ៍តម្រងឧបករណ៍កំណត់ដូស DEF។

6. សម្អាតស្នែខ្ចៅឧបករណ៍កំណត់ដូស DEF និងផ្ទៃបន្ទប់ដោយប្រើទឹកសុទ្ធ។
7. លាបប្រេងតម្រង DEF ស្អាតលើកងមូល។ ស៊កបញ្ចូលតម្រងឧបករណ៍កំណត់ដូស DEF ទៅក្នុងឧបករណ៍កំណត់ដូស DEF។
8. ដំឡើងធាតុលំនឹងតម្រងឧបករណ៍កំណត់ដូស DEF ថ្មីទៅក្នុងតម្រងឧបករណ៍កំណត់ដូស DEF។
9. ដាក់គម្របតម្រងចូល រួចរឹតបន្តឹងវាឲ្យត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស:

លក្ខណៈបច្ចេកទេស

គម្របតម្រង—កម្លាំងបង្វិល	23 ញូតុនម៉ែត្រ (204 ផោនអ៊ីញ)

OUO6075,0004BB9-KM-30MAY19-2/2

ប្តូរតម្រងជាជួរសារធាតុរាវបំពង់ស៊ីម៉ាំងម៉ាស៊ូត (DEF) (គ្រឿងចក្រម៉ូដែល S760 និង S770)

តទៅទំព័របន្ទាប់

OUO6075,0004BBA-KM-30MAY19-1/6

ប្រយ័ត្ន៖ ចូរប្រយ័ត្នក្រែងលោប៉ះត្នែក។ ប្រសិនបើប៉ះចំត្នែក ចូរជាញ់ទឹកក្នុងចំនួនច្រើនចូលក្នុងភ្នែកភ្លាមៗ ក្នុងរយៈពេលយ៉ាងតិច 15 នាទី។ សម្រាប់ព័ត៌មានបន្ថែម សូមអានតារាងទិន្នន័យសុវត្ថិភាពរបស់សម្ភារៈ (MSDS)។

សំខាន់៖ ប្រសិនបើ DEF កំពប់ ឬប៉ះពាល់ផ្ទៃណាមួយក្រៅពីធុងស្តុក ចូរលាងសម្អាតផ្ទៃនោះភ្លាមៗដោយប្រើទឹកថ្លា។ DEF ធ្វើឲ្យផ្ទៃលោហធាតុដែលបានលាបថ្នាំពណ៌ និងមិនបានលាបថ្នាំពណ៌ច្រេះ និងអាចបំផ្លាញរូបរាងដើមរបស់សមាសធាតុផ្លាស្ទិច និងជរាមួយចំនួន។


DEF ដែលបានបញ្ចេញ បើបានទុកឱ្យស្ងួត ឬបើបានជូតចេញដោយក្រណាត់ប៉ុណ្ណោះ ទុកឱ្យមានសំណល់ពណ៌ស។ ការកំពប់ DEF ដែលមិនបានសម្អាតត្រឹមត្រូវអាចរំខានដល់ការវិនិច្ឆ័យបញ្ហាការលេចប្រព័ន្ធកាត់បន្ថយកត្តាលិករជម្រើស (SCR)។

កំណត់ចំណាំ៖ តម្រងជាជួរ *DEF* និងតម្រងឧបករណ៍កំណត់ជួស *DEF* ត្រូវតែប្តូរចោលជាមួយគ្នារៀងរាល់ *2000* ម៉ោងឬ *36* ខែ ទោះជាដល់កំណត់មួយណាមុនក៏ដោយ។

1. សម្អាតកម្ទេចកម្ទីចេញពីតំបន់ជុំវិញបង្គុំតម្រងជាជួរ DEF។

កំណត់ចំណាំ៖ រង់ចាំប្រហែល *5* នាទី ដើម្បីឲ្យ *DEF* ធ្វើវិសុទ្ធកម្មពីប្រព័ន្ធ។

2. ដោះនិងបោះឆ្នុកតម្រង (A) ចោល។



A—ឆ្នុកបង្ហូរ **B—តម្របតម្រង**

3. បង្ហូរសារធាតុរាវ DEF ចូលទៅក្នុងធុង។
4. ដោះគម្របតម្រង (B) ចេញ។

OUO6075,0004BBA-KM-30MAY19-2/6

5. ទាញបង្គុំតម្រង (A) ចុះក្រោមចេញពីតួ DEF ។

កំណត់ចំណាំ៖ បើចាំបាច់ ចូរគោះតម្រងដើម្បីបន្ធូរ។ បន្ទះផ្លាស្ទិចនៅខាងក្នុងគម្របតម្រងចាក់ខ្ទាស់តម្រងឲ្យនៅនឹងកន្លែង។

6. ដោះនិងបោះចោលតម្រង (B) ពីគម្របតម្រង។
7. សម្អាតធ្មេញស្នែបង្គុំ និងផ្ទៃបន្ទប់ដោយប្រើទឹកបរិសុទ្ធ។

A—បង្គុំតម្រង **B—តម្រង**



OUO6075,0004BBA-KM-30MAY19-3/6

8. ដោះនិងបោះចោលប្រដាប់ញែកពពុះ (A) បោះចោលហ្វឺត (B) ដែលដោះចេញពីគម្របតម្រង(C)។
9. ដំឡើងប្រដាប់ញែកពពុះថ្មី ហើយដាក់ហ្វឺតថ្មីចូលទៅក្នុងគម្រងតម្រងដែលបានដោះចេញកន្លងមក។

A—ប្រដាប់ញែកពពុះ **C—គម្របតម្រង**
B—ហ្វឺត



តទៅទំព័របន្ទាប់

OUO6075,0004BBA-KM-30MAY19-4/6

កំណត់ចំណាំ៖ បន្ទុះផ្លាស្ទិចនៅខាងក្នុងគម្របចាក់ខ្ជាស់តម្រងឲ្យនៅនឹងកន្លែង។

10. សិកតម្រងថ្មី (A) ទៅក្នុងគម្របតម្រងដូចក្នុងរូប ហើយបន្ទាប់មកសិកចូលក្នុងតួ DEF (B)។
11. ដាក់គម្របតម្រងចូល រួចរឹតបន្តឹងវាឲ្យត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស៖

លក្ខណៈបច្ចេកទេស

គម្របតម្រង—កម្លាំងបង្វិល	25 ញូតុនម៉ែត្រ (221 ផោនអ៊ីញ)

A—តម្រង **B—តួ DEF**



H125464—UN—06DEC18

OUO6075,0004BBA-KM-30MAY19-5/6

12. ដាក់រ៉ងមូល (A) ចូលទៅក្នុងគន្លាក់ (B) នៅលើឆ្នុលបង្ហូរថ្មី។
13. ជូរដាក់ឆ្នុកបង្ហូរចូលទៅក្នុងគម្របតម្រង រួចរឹតបន្តឹងវាទៅតាមលក្ខណៈបច្ចេកទេស។

លក្ខណៈបច្ចេកទេស

ឆ្នុកបង្ហូរប្រេង—កម្លាំងបង្វិល	4 ញូតុនម៉ែត្រ (35 ផោនអ៊ីញ)

A—កងមូល **B—គន្លាក់**




H125465—UN—06DEC18

OUO6075,0004BBA-KM-30MAY19-6/6

តារាងចន្លោះពេលផ្តល់សេវាថែទាំ— រៀងរាល់ 4500 ម៉ោង ឬប្រាំឆ្នាំ

OUO6075,1657722111062-KM-13JUL22-1/2



H120324—UN—22DEC16

មាត្រដ្ឋាន	សេវាថែទាំ	រាល់ 4500 ម៉ោង ឬ ៥ ឆ្នាំ ម្តង
A	ផ្លាស់ប្តូរគ្រឿងសម្រួបប្រអប់រវៃម៉ាស៊ីនខាងមុខ (ចំណាត់ថ្នាក់ 2/ដំណាក់កាល II)	•


OUO6075,1657722111062-KM-13JUL22-2/2

ផ្លាស់ប្តូរគ្រឿងសម្រួបប្រអប់រវៃម៉ាស៊ីន (ចំណាត់ថ្នាក់ 2/ដំណាក់កាល II)

OUO6075,1653323944771-KM-13JUL22-1/2

សំខាន់៖ បង្គុំសម្រួបរំញ័រមិនអាចជួសជុលបានឡើយ ហើយគួរតែប្តូរចេញរាល់ ៥ ឆ្នាំម្តង ឬ 4500 ម៉ោងម្តង ទោះជាអ្វីកើតឡើងមុនក៏ដោយ។

ចូរឲ្យអ្នកចែកចាយក្រុមហ៊ុន John Deere ប្តូរគ្រឿងសម្រួបប្រអប់ស្តីម៉ាស៊ីនខាងមុខចេញ។




H120325—UN—22DEC16

ចំណាត់ថ្នាក់ *2*/ដំណាក់កាល *II* បុំណ្ណោះ *(*បែប *A* / បែប *B)*

OUO6075,1653323944771-KM-13JUL22-2/2

តារាងចន្លោះពេលផ្តល់សេវាថែទាំ— រៀងរាល់ 6000 ម៉ោង ឬប្រាំមួយឆ្នាំ

OUO6075,0004465-KM-20DEC16-1/2



H119645—UN—13OCT16

កំណត់ចំណាំ៖ ចន្លោះពេលប្តូរទឹកថ្នាំស្អុំដែលបានកំណត់ពេល 6ឆ្នាំ ឬ 6000 ម៉ោង ប្រសិនបើ *John Deere Cool-Gard™ II* ឬ *Cool-Gard™ II PG* ត្រូវបានប្រើប្រាស់។

មាត្រដ្ឋាន	សេវាថែទាំ	រៀងរាល់ 6000 ម៉ោង ឬប្រាំមួយឆ្នាំ
A និង B	បង្ហូរ លាងសម្អាត និងចាក់បំពេញប្រព័ន្ធបញ្ចុះកម្តៅម៉ាស៊ីន	•

Cool-Gard គឺជានិក្ខិត្តសញ្ញារបស់ *Deere & Company*

OUO6075,0004465-KM-20DEC16-2/2

ប្រព័ន្ធបញ្ចុះកម្តៅម៉ាស៊ីន

តទៅទំព័របន្ទាប់

OUO6075,00047FF-KM-13NOV17-1/2

កំណត់ចំណាំ៖ នៅពេល *Cool-Gard™ II* ឬ *Cool-Gard™ II PG* ត្រូវបានប្រើប្រាស់ ចន្លោះពេលបង្ហូរគឺ *6* ឬ *6000* ម៉ោង ប្រតិបត្តិការ។


ប្រសិនបើទឹកស្អុំម៉ាស៊ីនផ្សេងទៀតក្រៅពី *Cool-Gard II* ឬ *Cool-Gard II PG* ត្រូវបានប្រើ នោះចន្លោះនៃពេលនៃការបង្ហូរចេញគឺមានរយៈពេល *2*ឆ្នាំ ឬ*2000*ម៉ោងនៃដំណើរការ។

បើកឆ្នុកបង្ហូរ (A) ដើម្បីដោះទឹកថ្នាំស្អុំចេញពីរ៉ាឌីយ៉ាទ័រ។


លាងសម្អាត ហើយចាក់បំពេញធុងខ្ចោលឡើង (B) ជាមួយនឹងទឹកថ្នាំស្អុំដែលត្រឹមត្រូវ និងម៉ាស៊ីនត្រជាក់។ មើលការថែទាំប្រេងឥន្ធនៈ— តាមការចាំបាច់ ផ្នែក(សារធាតុរាវរបស់ម៉ាស៊ុន និងតម្រង) សម្រាប់ព័ត៌មានបន្ថែម។ សូមអានផ្នែក "ប្រេងឥន្ធនៈ និងប្រេងរំអិលសម្រាប់ការណែនាំអំពីប្រេង។

ពិនិត្យមើលកម្រិតទឹកថ្នាំស្អុំម៉ាស៊ីនក្នុងធុងខ្ចោលឡើងដោយទុកឲ្យម៉ាស៊ីនត្រជាក់។ កម្រិតត្រូវតែឡើងដល់បន្ទាត់ "ត្រជាក់អតិបរមា" ។

A—បង្ហូរ **B—ធុងខ្ចោលឡើង**



ចំណាត់ថ្នាក់ *2*/ដំណាក់កាល *II* (ប្រភេទ *A)*




ចំណាត់ថ្នាក់ *2*/ដំណាក់កាល *II* (ប្រភេទ *B)*និងចំណាត់ថ្នាក់ចុងក្រោយង *4*/ដំណាក់កាល *V*

Cool-Gard គឺជាពាណិជ្ជសញ្ញារបស់ *Deere & Company*

OUO6075,00047FF-KM-13NOV17-2/2

តារាងចន្លោះពេលផ្តល់សេវា— តាមការចាំបាច់

OUO6075,1654116701723-KM-01JUN22-1/2



H124383—UN—29MAY18

មាត្រដ្ឋាន	សេវាថែទាំ	តាមចាំបាច់
A	សម្អាត/ប្តូរតម្រងវិលឡើងវិញ	•
B	សម្អាត/ប្តូរតម្រងខ្យល់បរិសុទ្ធកាប៊ីន	•
C	ចាក់បំពេញធុងទឹកប្រដាប់សម្អាតកញ្ចក់	•
D	សម្អាតអេក្រង់គ្រឿងបម្លែងអគ្គិសនី	•
E	អង្កញ្ញាណសំណើមស្អាត (បើមាន) សម្អាតប្រដាប់បួងឆ្លងកាត់អង្កញ្ញាណសំណើម សម្អាតកាមេរ៉ាឧបករណ៍លើកគ្រាប់ធញ្ញជាតិស្អាត ActiveVision (បើមាន) ប្តូរបំពង់សារធាតុការពារសំណើមកាមេរ៉ាស្អាត ActiveVision (បើមាន)[a]	•
F	សម្អាតកាមេរ៉ាប្រព័ន្ធសណ្តោង ActiveVision (បើមាន) ប្តូរបំពង់សារធាតុការពារសំណើមកាមេរ៉ាប្រព័ន្ធកាកសំណល់ ActiveVision (បើមាន)[a]	•
G	ពិនិត្យ/រឹតបន្តឹងខ្សែដែកកែងទម្របំពង់ពន្លត់អគ្គីភ័យ (បើមាន)	•

[a] ប្រសិនបើចប់រដូវច្រូតកាត់ហើយ ចូររង់ចាំរហូតដល់ដើមរដូវច្រូតកាត់បន្ទាប់ដើម្បីពង្រីកអាយុកាលរបស់បំពង់ដាក់សារធាតុការពារសំណើម។


OUO6075,1654116701723-KM-01JUN22-2/2

តម្រងវិលឡើងវិញ

OUO6075,0004468-KM-21DEC16-1/2

ដោះគម្របដើម្បីសម្អាត ឬប្តូរតម្រងវិលឡើងវិញចេញ (A) ។

A—តម្រងវិលឡើងវិញ



H115668—UN—28AUG15

OUO6075,0004468-KM-21DEC16-2/2


តម្រងខ្យល់បរិសុទ្ធក្នុងកាប៊ីន

OUO6075,0004469-KM-21DEC16-1/2

កំណត់ចំណាំ៖ តម្រងខ្យល់បរិសុទ្ធក្នុងកាប៊ីនអាចទាមទារឲ្យ
សម្អាតឲ្យបានកាន់តែឆាប់ក្នុងស្ថានភាពមានធូលី។

បង្វិលក្បាលមួល (A) ហើយបន្ទាបគម្របចូល។ ដោះតម្រងខ្យល់
បរិសុទ្ធចេញ (B) ដើម្បីសម្អាត ឬប្តូរ។

A—ក្បាលមួល **B—តម្រងខ្យល់បរិសុទ្ធ**




OUO6075,0004469-KM-21DEC16-2/2

ធុងទឹកប្រដាប់សម្អាតកញ្ចក់មុខ

OUO6075,000446A-KM-21DEC16-1/2

បើកគម្រប (A) ហើយចាក់បំពេញធុងទឹកប្រដាប់សម្អាតកញ្ចក់
មុខ។

A—គម្រប




OUO6075,000446A-KM-21DEC16-2/2

អេក្រង់បម្លែងអគ្គិសនី

OUO6075,000469C-KM-21MAR17-1/2

សម្អាតអេក្រង់នៅពេលវាមានកម្ទេចកម្ទី 50%



OUO6075,000469C-KM-21MAR17-2/2

អង្គញ្ជាណសំណើម (បើមាន)

OUO6075,1654116976282-KM-02JUN22-1/2


សំខាន់៖ ចរន្តអគ្គិសនីស្ថាទិកអាចធ្វើឲ្យខូចម៉ូឌុលអង្គញ្ជាណសំណើម។ ដើម្បីកុំឲ្យខូចខាត ចូរប្រាកដថាបានប៉ះផ្ទៃលោហៈនៅលើគ្រឿងចក្រដោយដៃម្ខាងយ៉ាងតិច មុននឹងបំពេញការងារនៅលើ ឬសម្អាត។

អង្គញ្ជាណសំណើមមានសមាសភាពគ្រឿងខាងក្នុងដែលអាចបន្ទរបាននៅពេលទម្លាក់ចុះ ដែលប្រហែលមិនអាចចាប់សញ្ញាបានភ្លាមៗ។ ចាត់ចែងអង្គញ្ជាណសំណើមដោយប្រុងប្រយ័ត្ននៅពេលធ្វើការឬសម្អាតនៅលើគ្រឿងចក្រ។

ដោះចេញ ហើយសម្អាតអង្គញ្ជាណសំណើម (A) នៅពេលប្រតិបត្តិការក្នុងស្មៅ ដំណាំបៃតង ឬគ្រាប់ធញ្ញជាតិតូចៗ (កាណូឡា)។

- ហាមប្រើសារធាតុរំលាយឬទឹកលាងសម្អាតផ្សេងទៀតនៅលើមុខអង្គញ្ជាណ។
- យកល្អគួរប្រើក្រណាត់សូត្រសម្រាប់ជូតសម្អាត។ ប្រសិនបើសម្អាតមិនជ្រះទេ ចូរប្រើក្រណាត់និងទឹកដុសខាត់ពីលើ។
- ហាមប្រើម្សៅសម្អាតមុខអង្គញ្ជាណសំណើម។

ដំឡើងអង្គញ្ជាណសំណើមនិងក្រិតវាតាមខ្នាត។ មើលដំនួយ



A—អង្គញ្ជាណសំណើម

អនុវត្តទិដ្ឋភាពរួមនៃគ្រឿងច្រូកកាត់ ឬជំនួយស្ថានីយប្រតិបត្តិការសម្រាប់ព័ត៌មានបន្ថែម។


OUO6075,1654116976282-KM-02JUN22-2/2

ប្រដាប់បួងឆ្លងកាត់អង្គញ្ជាណសំណើម (បើចាំបាច់)

OUO6075,1654117011682-KM-09JUN22-1/2

1. ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។
2. ដោះដែកស៊ក (A) និងគម្របខាងចុង (B) ចេញ។
3. ដោះប្រដាប់បួង (C) ចេញពេញប្រដាប់ឆ្លងកាត់អង្គញ្ជាណសំណើម។
4. សម្អាតប្រដាប់បួង និងតំបន់នៅក្នុងប្រដាប់ឆ្លងកាត់អង្គញ្ជាណសំណើម។
5. ដំឡើងនិងលៃតម្រូវប្រដាប់បួង។
6. ដាក់គម្របខាងចុង និងរឹតបន្តឹងដោយដែកស៊ក។

A—កន្លាស់ (ប្រើ 2)
B—គម្របខាងចុង
C—ប្រដាប់បួង



OUO6075,1654117011682-KM-09JUN22-2/2

សម្អាតកាមេរ៉ាឧបករណ៍លើកគ្រាប់ធញ្ញជាតិ ActiveVision (បើមាន)


តទៅទំព័របន្ទាប់

OUO6075,1654117083675-KM-02JUN22-1/2

កំណត់ចំណាំ៖ ការសម្អាតញឹកញាប់គឺអាស្រ័យលើកត្តាជាច្រើន ដែលរួមមានស្ថានភាពប្រតិបត្តិការ អាកាសធាតុ និង ស្ថានភាពដំណាំ។។ សម្អាតកញ្ចក់កាមេរ៉ាដោយប្រើប្រាស់ ក្រណាត់ដែលទន់ ស្អាត និងសើម។

បើកគន្លឹះ ហើយសម្អាតកាមេរ៉ាឧបករណ៍លើកគ្រាប់ធញ្ញជាតិ ស្អាត ActiveVision (A) ។

A—សម្អាតកាមេរ៉ាឧបករណ៍លើក គ្រាប់ធញ្ញជាតិ ActiveVision



OUO6075,1654117083675-KM-02JUN22-2/2


កាមេរ៉ាប្រព័ន្ធសណ្តោងរបស់ ActiveVision (បើមាន)

OUO6075,1654117168464-KM-02JUN22-1/2

កំណត់ចំណាំ៖ ការសម្អាតញឹកញាប់គឺអាស្រ័យលើកត្តាជាច្រើន ដែលរួមមានស្ថានភាពប្រតិបត្តិការ អាកាសធាតុ និង ស្ថានភាពដំណាំ។។ សម្អាតកញ្ចក់កាមេរ៉ាដោយប្រើប្រាស់ ក្រណាត់ដែលទន់ ស្អាត និងសើម។

បើកគន្លឹះ ហើយសម្អាតកាមេរ៉ាប្រព័ន្ធកាកសំណល់ ActiveVision (A) ។

A—កាមេរ៉ាប្រព័ន្ធសណ្តោងរបស់ ActiveVision



រចនាប័ទ្ម A / រចនាប័ទ្ម B

OUO6075,1654117168464-KM-02JUN22-2/2

បំពង់សារធាតុការពារសំណើមកាមេរ៉ា ActiveVision (បើមាន)

តទៅទំព័របន្ទាប់

OUO6075,1654117298504-KM-09JUN22-1/4

សំខាន់៖ សម្ភារដើមដំណាំនិងកម្ទេចកម្ទីដទៃទៀតអាចកកកុញជុំវិញបំពង់សារធាតុការពារសំណើម។ ពិនិត្យនិងសម្អាតតំបន់ជុំវិញបំពង់សារធាតុការពារសំណើមមុននឹងដោះចេញ។


កំណត់ចំណាំ៖ កាមេរ៉ាប្រដាប់យោងគ្រាប់ធញ្ញជាតិស្អាត *ActiveVision* មានបង្ហាញជូន។ កាមេរ៉ាប្រព័ន្ធសណ្តោង *ActiveVision* គឺស្រដៀងគ្នា។

ប្តូរបំពង់សារធាតុការពារសំណើមតាមចាំបាច់នៅពេលសំណើមកកនៅផ្នែកខាងក្នុងកញ្ចក់ឡែនកាមេរ៉ា។

ប្រសិនបើចប់រដូវច្រូតកាត់ហើយ ចូររង់ចាំរហូតដល់ដើមរដូវច្រូតកាត់បន្ទាប់ដើម្បីពង្រីកអាយុកាលរបស់បំពង់ដាក់សារធាតុការពារសំណើម។

1. ពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។
2. ដោះខ្ចៅក្បាលខ្រុង (A) និងបបន្ទះគម្រប (B) ចេញ។

A—ខ្ចៅក្បាលឡូត (ប្រើ 4) **B—បន្ទះគម្រប**




OUO6075,1654117298504-KM-09JUN22-2/4

3. លៃតម្រឹមប្រអប់សារធាតុការពារសំណើម (A) ដែលដាក់បញ្ចូលជាមួយបំពង់សារធាតុការពារសំណើមថ្មីដែលមានគន្លាក់(B)។

សំខាន់៖ នៅពេលប្តូរបំពង់ដារធាតុការពារសំណើម ចូរកុំបណ្តោយឲ្យសម្ភារដំណាំចូលទៅក្នុងកាមេរ៉ា ActiveVision ។

4. ដោះបំពង់សារធាតុការពារសំណើម (C) ចេញពីកាមេរ៉ា ActiveVision ។
5. បោះបង់ចោលបំពង់សារធាតុការពារសំណើម។

A—ប្រអប់សារធាតុការពារសំណើម (ឧបករណ៍) **C—បំពង់សារធាតុការពារសំណើម**
B—គន្លាក់



តទៅទំព័របន្ទាប់


OUO6075,1654117298504-KM-09JUN22-3/4

6. ដោះប្រអប់សារធាតុការពារសំណើម (A) ចេញពីបំពង់សារធាតុការពារសំណើមថ្មី(B)។
7. ដំឡើងបំពង់ដាក់សារធាតុការពារសំណើមក្នុងកាមេរ៉ា ActiveVision ។
8. តម្រឹមឧបករណ៍សារធាតុការពារសំណើមជាមួយនឹងគន្លាក់។
9. រឹតបន្តឹងបំពង់សារធាតុការពារសំណើមទាល់តែវាណែន ឬទៅតាមលក្ខណៈបច្ចេកទេស។

លក្ខណៈបច្ចេកទេស

បំពង់សារធាតុការពារសំណើម—កម្លាំងបង្វិល	5 ញូតុនម៉ែត្រ (44 ផោនអ៊ីញ)

10. ដាក់បន្ទះគម្របពីលើបំពង់សារធាតុការពារសំណើម។
11. លាបការបង្ហាំស្នែខ្ចៅ (កម្លាំងមធ្យម) លើខ្ចៅក្បាលឲជ្រុង។
12. រឹតបន្តឹងប៊ូឡុងក្បាលឡុតឲជ្រុងទៅតាមលក្ខណៈពិសេសបច្ចេកទេស។



H130390—UN—01JUN20

ប្រអប់សារធាតុការពារសំណើម (ឧបករណ៍) និងបំពង់សារធាតុការពារសំណើម

A—ប្រអប់សារធាតុការពារសំណើម (ឧបករណ៍)

B—បំពង់សារធាតុការពារសំណើម

លក្ខណៈបច្ចេកទេស

ខ្ចៅក្បាលឡុត—កម្លាំងបង្វិល	2.5 ញូតុនម៉ែត្រ (22 ផោនអ៊ីញ)

OUO6075,1654117298504-KM-09JUN22-4/4

ខ្សែដែកកែងទម្របំពង់ពន្លត់អគ្គីភ័យ (បើមាន)

OUO6075,0004983-KM-29MAY18-1/2

⚠ ប្រយ័ត្ន៖ ត្រួតពិនិត្យខ្សែរឹតបំពង់ពន្លត់អគ្គីភ័យ និងគ្រឿងខ្ចៅចាប់ភ្ជាប់យ៉ាងតិចម្តងក្នុងមួយឆ្នាំ។ ប្រសិនបើខ្សែរឹតបំពង់ពន្លត់អគ្គីភ័យ ឬគ្រឿងខ្ចៅមានលេចនូវសញ្ញាខូចខាត ឬសឹករេចរឹលខុសប្រក្រតី ស្នែកពណ៌មានស្នាមរលាត់ លោកអ្នកគួរតែប្តូរខ្សែរឹតនឹងគ្រឿងខ្ចៅទាំងមូលចេញជាបន្ទាន់។ ដើម្បីសុវត្ថិភាពផ្ទាល់ខ្លួន ចូរផ្តាស់ប្តូរសមាសភាពបំពង់ពន្លត់អគ្គីភ័យចេញដាក់គ្រឿងបន្លាស់ទាំងឡាយណា ដែលមានការអនុញ្ញាតសម្រាប់គ្រឿងចក្ររបស់អ្នក។ ចូរពិគ្រោះជាមួយអ្នកចែកចាយ John Deere របស់អ្នក។

ពិនិត្យខ្សែរឹតដែកកែងទម្របំពង់ពន្លត់អគ្គីភ័យ។




H123657—UN—02MAR18

OUO6075,0004983-KM-29MAY18-2/2

សម្អាតបង្ហួច កញ្ចក់ និងអំពូលភ្លើង

ចូរប្រាកដថាមើលឃើញច្បាស់គ្រប់ទិសទាំងអស់។ សម្អាតបង្ហួច កញ្ចក់ និងអំពូលភ្លើងដើម្បីឲ្យមើលឃើញច្បាស់ល្អ។

- ហាមប្រើសារធាតុរំលាយឬទឹកលាងសម្អាតផ្សេង។ យកល្អគួរប្រើទឹកសម្អាតកញ្ចក់របស់ John Deere ឬសមមូល។
- គួរប្រើក្រណាត់ទន់គ្មានសរសៃគ្រើម ឬក្រមាពោះគោដើម្បីសម្អាត។

OUO6075,0004C88-KM-27FEB20-1/1

ការថែទាំ—តាមចាំបាច់ (ប្រេងម៉ាស៊ីន និងតម្រង)

ព័ត៌មានពាក់ព័ន្ធនឹងការបញ្ចេញផ្សែងដែលត្រូវការ

អ្នកផ្តល់សេវា

ហាងជួសជុល ឬអ្នកជួសជុលដែលមានគុណសម្បត្តិគ្រប់គ្រាន់តាមជម្រើសរបស់ម្ចាស់ អាចធ្វើការថែទាំ ផ្លាស់ថ្មី ឬជួសជុលឧបករណ៍ និងប្រព័ន្ធគ្រប់គ្រងការបញ្ចេញផ្សែងដោយគ្រឿងបន្លាស់ដើម ឬគ្រឿងបន្លាស់សម្រាប់ការផ្លាស់ថ្មីដែលសមមូល។ ទោះបីជាយ៉ាងណាក៏ដោយ ការធានា ការអនុវត្តឡើងវិញ និងសេវាផ្សេងទៀតទាំងអស់ដែលទូទាត់ប្រាក់ដោយ John Deere ត្រូវតែអនុវត្តនៅមជ្ឈមណ្ឌលផ្តល់សេវាដែលមានការអនុញ្ញាតណាមួយរបស់ John Deere។

DX,EMISSIONS,REQINFO-KM-12JUN15-1/1

ជណ្តើរខាងក្រោយនិងកន្លែងជាន់


OUO6075,0000588-KM-16FEB10-1/2

⚠ ប្រយ័ត្ន៖ ចូរពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។

ចុចលើដង (A) ហើយបើកជណ្តើរចេញរហូតទាល់តែទ្វារចាក់គន្លឹះ។

ប្រើដង (B) ដើម្បីទាញជណ្តើរមកក្រោយ។

A—ដងកាន់ **B—ដងកាន់**



H95325—UN—11FEB10

OUO6075,0000588-KM-16FEB10-2/2


គម្របច្រកលូកចូលទៅកាន់តម្រងម៉ាស៊ីន

OUO6075,000069B-KM-25AUG10-1/2

ទាញកន្លាស់ស៊ីកចាក់គន្លឹះ (A) ហើយត្រលប់ជណ្តើរ (B) ឡើងរហូតដល់ជណ្តើរចាក់គន្លឹះនឹងកន្លែង។

ទាញបើកគម្របច្រកលូកចូលតម្រង (C) ដើម្បីបន្ធូរចេញពីមេដែក។

A—កន្លាស់ស៊ីកចាក់ខ្ទាស់
B—ជណ្តើរ
C—គម្រប



H95353—UN—25AUG10

OUO6075,000069B-KM-25AUG10-2/2

គម្របច្រកលូកចូលម៉ាស៊ីន


គទៅទំព័របន្ទាប់

OUO6075,00042D3-KM-04MAY16-1/2

ទាញកន្លាស់ស៊ីកចាក់គន្លឹះ (A) ហើយត្រលប់បង្អាន់ដៃ (B) ឡើងរហូតដល់បង្អាន់ដៃចាក់គន្លឹះនឹងកន្លែង។

បើកគម្របច្រកលូកចូលម៉ាស៊ីន

A—កន្លាស់ស៊ីកចាក់គន្លឹះ **B—បង្អាន់ដៃ**



OUO6075,00042D3-KM-04MAY16-2/2

ការប្តូរកំប៉ុងសារធាតុរាវបញ្ចោះ

OUO6075,00041C6-KM-08JAN16-1/2


⚠ ប្រយ័ត្ន៖ សារធាតុជំនួយបញ្ចោះមានចំហេះខ្ពស់ ហើយអាចបង្ករបួសស្នាម ឬស្លាប់ជាក់បង់ជីវិត ប្រសិនវាឆាបឆេះដោយចៃដន្យ។ កុំប្រើវានៅជិតភ្លើង ផ្កាភ្លើង ឬអណ្តាតភ្លើង។ សូមអានព័ត៌មានបង្ហាញនៅលើកំប៉ុងនិងការពារកុំឲ្យខូចកំប៉ុង។

បើកទ្វារច្រកលូកចូលម៉ាស៊ីន។ ដោះគម្របសុវត្ថិភាពនិងប៊ូតុងជាប់ចេញពីកំប៉ុងសារធាតុជំនួយបញ្ចោះ (A)។ បន្ធូរកង់បង្វិលដោយម្រាមដៃឲ្យល្មមដើម្បីប្តូរកំប៉ុង ហើយបន្ទាប់មកវិតបន្តឹងវិញ។

សំខាន់៖ ដើម្បីការពារកុំឲ្យធូលីចូលក្នុងម៉ាស៊ីន ជានិច្ចកាលចូររក្សាទុកកំប៉ុងនៅនឹងកន្លែង។

ការពារកំប៉ុងសារធាតុរាវជំនួយបញ្ចោះកុំឲ្យកម្តៅខ្លាំង ឬខូចខាត។

ចូរពិនិត្យសារធាតុរាវនិងប្រតិបត្តិការវាល់ដោយដំឡើងនិងចុចក្បាលបាញ់។ ប្រសិនបើបាញ់មិនចេញទេ ចូរប្តូរកំប៉ុងចេញ។



A—កំប៉ុងសារធាតុរាវបញ្ចោះ

⚠ ប្រយ័ត្ន៖ ដើម្បីការពារការរងរបួសដោយថាហេតុដោយសារការផ្ទុះកំប៉ុង ចូរកុំរក្សាទុកប៉ុងបន្ថែម ឬកំប៉ុងទទេនៅក្នុងកាប៊ីន។

OUO6075,00041C6-KM-08JAN16-2/2

កុំផ្លាស់ប្តូរថាមពលម៉ាស៊ីនឬប្រព័ន្ធប្រេងឥន្ធនៈ/ខ្សល់

សំខាន់៖ ការបង្កើនកម្លាំងសេះ ឬកែប្រែទិដ្ឋភាពណាមួយនៃប្រេងឥន្ធនៈនិងការចែកចាយប្រេងនៅលើម៉ាស៊ីនដែលមានការបញ្ជាក់ពីការបំភាយឧស្ម័នពុលលើសពីការកំណត់របស់អោងចក្រ នឹងបង្កកម្រិតបំភាយឧស្ម័នលើសពីអ្វីដែលបទប្បញ្ញត្តិច្បាប់ស្តីពីការបំភាយឧស្ម័នពុលរបស់ម៉ាស៊ីនអនុញ្ញាត។ ការលែតម្រូវដែលមិនមានការអនុញ្ញាតគឺជាការរំលោភចំពោះបទប្បញ្ញត្តិស្តីពីការបំភាយឧស្ម័នពុលដែលអនុវត្តចំពោះម៉ាស៊ីននេះ ហើយអាចទទួលរងការផាកនិងពិន័យ។ ការធានាលើគ្រឿងចក្រនឹងលែងមានសុពលភាព ប្រសិនបើកម្រិតថាមពលត្រូវបានកែប្រែពីលក្ខណៈពិសេសបច្ចេកទេសរបស់អោងចក្រ។

កុំព្យាយាមផ្តល់សេវាថែទាំកូនជ្រូក ឬបិទបាញ់ប្រេងឥន្ធនៈឲ្យសោះ។ ទាមទារឲ្យមានការបណ្តុះបណ្តាលពិសេស និងឧបករណ៍ពិសេស។ សូមទៅជួបអ្នកចែកចាយ John Deere របស់អ្នក។

OUO6075,000058D-KM-11FEB10-1/1


ប្រព័ន្ធប្រេងឥន្ធនៈ:

តទៅទំព័របន្ទាប់

OUO6075,000058E-KM-11FEB10-1/2

⚠ ប្រយ័ត្ន៖ ប្រេងឥន្ធនៈដែលបាញ់ចេញនៅក្រោមសម្ពាធអាចចាក់ទម្លុះស្បែក ដោយបណ្តាលឲ្យរងរបួសធ្ងន់ធ្ងរ។ ចូរបន្ទរូសម្ពាធមុននឹងផ្តាច់បណ្តាញទុយោអ៊ីដ្រូលីក ឬបណ្តាញទុយោផ្សេងទៀត។ មូលបន្តឹងរាល់តំណភ្ជាប់ទាំងអស់មុនពេលប្រើសម្ពាធ។ ចូរកុំដាក់ដៃឬខ្លួនប្រាណនៅជិតរន្ធកន្លាស់ស៊កនិងក្បាលបាញ់ដែលបាញ់បញ្ចេញសារធាតុរាវក្រោមសម្ពាធខ្ពស់។ ចូរប្រើក្រដាសកាតុងឬក្រដាសដើម្បីរាវរកការលេចធ្លាយ។ ចូរកុំប្រើដៃទេ។

ប្រសិនបើសារធាតុរាវចាក់ចូលទៅក្នុងស្បែក ត្រូវតែរះយកចេញក្នុងរយៈពេលពីរ ឬបីម៉ោង បើពុំដូច្នោះទេ អាចបណ្តាលឲ្យកើតដំបៅរលួយ។



X9811—UN—23AUG88

OUO6075,000058E-KM-11FEB10-2/2


ធុងសារធាតុរាវបំពង់ស៊ីម៉ាំងម៉ាស៊ូត (DEF)—ការចាក់បំពេញ (ចំណាត់ថ្នាក់ចុងក្រោយទី 4 ឬដំណាក់កាល V)

OUO6075,0004A62-KM-04DEC18-1/2

⚠ ប្រយ័ត្ន៖ Diesel Exhaust Fluid (DEF) មានជាតិអ៊ុយរ៉ែ។ ចូរកុំឲ្យសារធាតុរាវនេះប៉ះចំភ្នែក។ ក្នុងករណីមានការប៉ះពាល់ ជាញឹកញាប់ក្នុងចំនួនច្រើនចូលក្នុងភ្នែកភ្លាមៗ ក្នុងរយៈពេលយ៉ាងតិច 15 នាទី។ ក្នុងករណីបានលេប DEF ចូលក្នុងពោះ ចូរទៅរកគ្រូពេទ្យជាបន្ទាន់។ ដើម្បីជ្រាបនូវព័ត៌មានបន្ថែម សូមអានតារាងទិន្នន័យសុវត្ថិភាពរបស់សម្ភារៈ (MSDS)។

សំខាន់៖ ការប្រើប្រាស់សមាសភាពគ្រឿងដែលមិនត្រឹមត្រូវ ឬមិនមានការយល់ព្រម អាចខូចដល់ប្រព័ន្ធប្រព្រឹត្តិកម្មគ្រឿងចក្រ និងកាត់បន្ថយសមត្ថភាពប្រព័ន្ធប្រព្រឹត្តិកម្មក្នុងការបំពេញមុខងារឲ្យបានត្រឹមត្រូវ។ ចូរកុំប្តូរគ្រឿងប្រព័ន្ធប្រព្រឹត្តិកម្មទៅមករវាងគ្រឿងចក្រដែលបំពាក់ចំណាត់ថ្នាក់បណ្តោះអាសន្នទី 4/ដំណាក់កាល III B និងចំណាត់ថ្នាក់ចុងក្រោយទី 4/ដំណាក់កាល V។

កំណត់ចំណាំ៖ ប្រសិនបើ *DEF* កំពប់ ឬប៉ះពាល់ផ្ទៃណាមួយក្រៅពីធុងស្តុក ចូរលាងសម្អាតផ្ទៃនោះភ្លាមៗដោយប្រើទឹកថ្លា។ *DEF* ធ្វើឲ្យផ្ទៃលោហធាតុដែលបានលាបថ្នាំពណ៌ និងមិនបានលាបថ្នាំពណ៌ច្រេះ និងអាចបំផ្លាញរូបរាងដើមរបស់សមាសធាតុផ្លាស្ទិច និងជ័រមួយចំនួន។



H125432—UN—04DEC18

A—គម្រប

B—វាល់ខ្សល់ចេញចូលធុងសារធាតុរាវបំពង់ស៊ីម៉ាំងម៉ាស៊ូត (DEF)

គម្រប (A) មិនមានរន្ធខ្សល់ចេញចូលឡើយ។ ខ្សល់ដែលលើសត្រូវចេញតាមវាល់ខ្សល់ចេញចូលធុង Diesel Exhaust Fluid (DEF) (B)។

ត្រួតពិនិត្យហ៊ីយដែលមើលឃើញ។ កុំឲ្យចំបើង ឬកម្ទេចកម្ទីកកកុញនៅលើវាល់ខ្សល់ចេញចូលច្រើនពេក។ ប្រសិនបើហ៊ីតត្រូវបានបិទជិតដោយកម្ទេចកម្ទី វាមិនឲ្យធុងមានខ្សល់ចេញចូលទេ។ ចូរដោះវាល់ខ្សល់ចេញចូលចេញពីទុយោ ហើយសម្អាតវា។

ចាក់បំពេញធុងនៅរាល់ពេលត្រូវចាក់ប្រេងចូលគ្រឿងចក្រ។ ប្រសិនបើវាមិនអាចរួចរាល់ ត្រួតពិនិត្យមើលសញ្ញាបង្ហាញកម្រិតសារធាតុរាវបំពង់ស៊ីម៉ាំងប្រេងឥន្ធនៈ (DEF) នៅលើអេក្រង់បង្ហាញនៅជ្រុង ហើយចាក់បំពេញបើចាំបាច់។ ដើម្បីចៀសវាងនូវបម្រែបម្រួលការអនុវត្តគ្រឿងចក្រ រក្សាកម្រិតសារធាតុរាវឲ្យនៅខាងលើសញ្ញាពណ៌ក្រហមនៅខាងលើបំផុតនៅលើទ្រនិចបង្ហាញកម្រិត។ មើលជំនួយអនុវត្តទិដ្ឋភាពទូទៅនៃឧបករណ៍ជ្រួកកាត់ ឬស្តានីយប្រតិបត្តិការសម្រាប់ព័ត៌មានបន្ថែម។

ដើម្បីចាក់បំពេញធុង៖

1. លាង និងសម្អាតកំប៉ុងជាមួយទឹកសុទ្ធដើម្បីជម្រះសារធាតុកខ្វក់ចេញមុននឹងបន្ថែមសារធាតុរាវចូល។
2. ជូតសម្អាតជុំវិញគម្របមុនពេលដោះចេញ ដើម្បីកាត់បន្ថយសារធាតុបំពុលផ្សេង។
3. ប្រើប្រាស់ជីរឡាវ ចាក់សារធាតុរាវដោយប្រុងប្រយ័ត្ននៅក្នុងធុង មើលកម្រិតតាមកញ្ចប់ផ្លាំ។
4. ចូរដាក់គម្របដែលបានដោះចេញកន្លងមកចូលវិញ។
5. ចូរសម្អាតការកំពប់ដោយប្រយ័ត្នប្រយែង ដោយប្រើទឹកបរិសុទ្ធ។

OUO6075,0004A62-KM-04DEC18-2/2

ធុងសារធាតុរាវបំពង់ស៊ីម៉ាំងម៉ាស៊ូត (DEF)—ការបង្ហូរចេញ (ចំណាត់ថ្នាក់ចុងក្រោយទី 4 ឬដំណាក់កាល V)


OUO6075,0004E1D-KM-07MAY20-1/2

⚠ ប្រយ័ត្ន៖ ចូរពន្លត់ម៉ាស៊ីន ដាក់ហ្វ្រាំងដៃ ហើយដកសោចេញ។

